ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩

## សេរីរបាយការណ៍រាជធានី ខេត្ត

# ២២- ខេត្ត ឧត្តរមានជ័យ

វិទ្យាស្ថានជាតិស្ថិតិ

ក្រសួងផែនការ

ខែកក្កដា ឆ្នាំ២០២១

## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

# ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩

## សេរីរបាយការណ៍រាជធានី ខេត្ត

# ២២- ខេត្ត ឧត្តរមានជ័យ

**វិទ្យាស្ថានជាតិស្ថិតិ**

**ក្រសួងផែនការ**

ខែកក្កដា ឆ្នាំ២០២១

# មាតិកា


ទំព័រ

បុព្វកថា........ii
អារម្ភកថា........iv
តួលេខសង្ខេបរបស់ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ខេត្តឧត្តរមានជ័យ........vi
ផ្នែក ១៖ របាយការណ៍ខេត្តឧត្តរមានជ័យ
  ជំពូក ១- សេចក្តីផ្តើម........១
  ជំពូក ២- ទំហំ កំណើន និងការបែងចែកប្រជាជន........៤
  ជំពូក ៣- សមាសភាពភេទ ការបែងចែកអាយុ និងស្ថានភាពអាពាហ៍ពិពាហ៍........៩
  ជំពូក ៤- អក្ខរភាព និងការអប់រំ........២១
  ជំពូក ៥- កម្លាំងពលកម្ម និងការងារ........៣២
  ជំពូក ៦- ទេសន្តប្រវេសន៍........៥៥
  ជំពូក ៧- លទ្ធភាពបង្កើតកូន........៦១
  ជំពូក ៨- មរណភាព........៦៤
  ជំពូក ៩- ពិការភាព........៦៨
  ជំពូក ១០- លំនៅដ្ឋាន ចរិតលក្ខណៈគ្រួសារ និងសម្ភារៈប្រើប្រាស់ក្នុងគ្រួសារ........៧៥
  ជំពូក ១១- សេចក្តីសង្ខេប និងការសន្និដ្ឋាន........៨៧
សន្ទានុក្រម........៩៥
ផ្នែក ២៖ លទ្ធផលសរុប តាម ស្រុក ក្រុង........១០៦
ផ្នែក ៣៖ ឧបសម្ព័ន្ធ........១១០
  ឧបសម្ព័ន្ធ ១ សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មាធិការជំរឿនទូទៅប្រជាជននៅខេត្តឧត្តរមានជ័យ........១១១
  ឧបសម្ព័ន្ធ ២ តារាង ក តារាងសំណួរបញ្ជីផ្ទះ........១១៧
  ឧបសម្ព័ន្ធ ៣ តារាង ខ តារាងសំណួរតាមគ្រួសារ........១១៨

# បុព្វកថា

ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ បានផ្តល់កាលានុវត្តភាពយ៉ាងសំខាន់ដល់ការវាយតម្លៃសមិទ្ធផលនានាដែលសម្រេចបានក្នុងអតីតកាល និងបានចង្អុលបង្ហាញនូវប្រសិទ្ធភាពនៃការអនុវត្តផែនការ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ទាំងឡាយសម្រាប់អនាគត។ ដោយមើលឃើញអំពីសារៈសំខាន់យ៉ាងធំធេងនៃការងារជំរឿន រាជរដ្ឋាភិបាលកម្ពុជាក្នុងភាពជាម្ចាស់បានបង្កើនការប្រើប្រាស់ថវិកាជាតិដ៏ច្រើន ដែលការធ្វើជំរឿនរយៈកាលកន្លងមកពឹងផ្អែកជំនួយហិរញ្ញវត្ថុស្ទើរទាំងស្រុងពីដៃគូអភិវឌ្ឍន៍។

ខ្ញុំពិតជាមានសេចក្តីរីករាយ ដែលជំរឿននេះបានអនុវត្តដោយជោគជ័យ និងបានផ្តល់ទិន្នន័យប្រកបដោយភាពជឿទុកចិត្ត និងទាន់ពេលវេលា សម្រាប់អ្នកតាក់តែងគោលនយោបាយ និងអ្នកធ្វើសេចក្តីសម្រេចនានារបស់រាជរដ្ឋាភិបាល និងសម្រាប់អ្នកប្រើប្រាស់ទូទៅ។ ខ្ញុំសូមបង្ហាញជូននូវរបាយការណ៍របស់ខេត្តឧត្តរមានជ័យ ដែលរួមមានតួលេខចំនួនប្រជាជន និងលទ្ធផលសំខាន់ៗដទៃទៀតដែលទាក់ទងនឹងខេត្តនេះរបស់ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩។ របាយការណ៍នេះ ជាផ្នែកមួយនៃស៊េរីរបាយការណ៍តាមខេត្ត ដែលបំបែកចេញជារបាយការណ៍ ដោយឡែកតាមខេត្តនិមួយៗនៃខេត្តទាំង២៤ និងរាជធានីភ្នំពេញ ដែលត្រូវបោះពុម្ពផ្សាយ ហើយខ្ញុំជឿជាក់ថា របាយការណ៍ទាំងអស់នេះនឹងផ្តល់ជូននូវព័ត៌មានអំពីប្រជាជន និងទិន្នន័យប្រជាជន ដល់មន្ត្រីរដ្ឋបាល និងមន្ត្រីផែនការខេត្តទាំងអស់។

ខ្ញុំសូមសម្តែងនូវកត្តញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុតជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលសម្តេចបានគាំទ្រយ៉ាងពេញទំហឹង និងបានណែនាំដ៏ថ្លៃថ្លាដល់ការអនុវត្តជំរឿនទូទៅប្រជាជននៅព្រះជាណាចក្រកម្ពុជាឆ្នាំ២០១៩ នេះទទួលបានជោគជ័យយ៉ាងត្រចះត្រចង់។ ខ្ញុំសូមគោរពថ្លែងអំណរគុណ ជូនចំពោះ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ ដែលសម្តេចបានផ្តល់អនុសាសន៍ចង្អុលបង្ហាញយ៉ាងច្បាស់លាស់គ្រប់ពេលវេលានៅក្នុងដំណើរការជំរឿនទូទៅនេះ។

ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយក្រៃលែង ក្នុងនាមក្រសួងផែនការ និងក្នុងនាមប្រធានគណៈកម្មការបច្ចេកទេសជំរឿន និងជាប្រធានគណៈកម្មការឃោសនាជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ និងសូមថ្លែងអំណរគុណផងដែរ ចំពោះសមាជិកនៃគណៈកម្មាធិការជំរឿនថ្នាក់កណ្តាល គណៈកម្មាធិការជំរឿនរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ទាំងអស់ ដែលបានបំពេញការងារយ៉ាងល្អរហូតទទួលបាននូវលទ្ធផលជាផ្លែផ្កាស្របទៅតាមពេលវេលាដែលបានគ្រោងទុក។

ខ្ញុំសូមថ្លែងអំណរគុណដល់មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ (GIZ) និងទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (Sida) ដែលបានរួមចំណែកផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបានផ្តល់ជំនួយផ្នែកបច្ចេកទេស ក្នុងការរៀបចំផែនការជំរឿន ការរៀបចំបណ្តាញវាយ

បញ្ចូលទិន្នន័យ និងសម្អាតទិន្នន័យ ការបណ្តុះបណ្តាលមន្ត្រីបច្ចេកទេសក្នុងការវិភាគទិន្នន័យ និងសរសេររបាយការណ៍ និងការរៀបចំរបាយការណ៍នេះ។

ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ដល់លោកបណ្ឌិត Ricardo Neupert ប្រធានទីប្រឹក្សាបច្ចេកទេសជំរឿនបានជួយដល់ផ្នែកបច្ចេកទេសជំរឿន ជាពិសេសការសរសេររបាយការណ៍តាមរាជធានី ខេត្ត លោកទីប្រឹក្សា Kjell Tambour បានផ្តល់ជំនួយបច្ចេកទេសខាងការកែច្នៃទិន្នន័យ និងលោកបណ្ឌិត Arij Dekker ទីប្រឹក្សាបច្ចេកទេសបានជួយដល់ការសម្អាតទិន្នន័យ និងតារាងអាទិភាពជំរឿន។

ខ្ញុំសូមថ្លែងអំណរគុណជាពិសេស ចំពោះរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ដែលបានផ្តល់ជំនួយជាសម្ភារៈ រួមមានរថយន្ត ទោចក្រយានយន្ត កុំព្យូទ័រលើតុ និងកំព្យូទ័រយួរដៃ ម៉ាស៊ីនព្រីនធ័រ ម៉ាស៊ីនថតចម្លង តាប្លេត (Tablet) ឧបករណ៍ផ្គត់ផ្គង់ព័ត៌មាន (Server) រួមទាំងឧបករណ៍អេឡិចត្រូនិកផ្សេងៗទៀត ដែលមានតម្លៃសរុបប្រមាណ ២,៥ លានដុល្លារសហរដ្ឋអាមេរិក ដើម្បីបម្រើដល់ការធ្វើជំរឿននេះ។

ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ ចំពោះមន្ត្រីវិទ្យាស្ថានជាតិស្ថិតិទាំងអស់ក្រោមការដឹកនាំរបស់លោកជំទាវ ហង់ លីណា ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ ដែលបានសម្របសម្រួលយ៉ាងយកចិត្តទុកដាក់នូវរាល់កិច្ចប្រតិបត្តិការជំរឿន ដោយមានជំនួយការពីអគ្គនាយករងមួយចំនួនគឺ ឯកឧត្តម សុក កុសល ឯកឧត្តម សាំង ឡង់ឌី និងឯកឧត្តម ចឺ ឃាម ទីប្រឹក្សាក្រសួង និងជាប្រធាននាយកដ្ឋានស្ថិតិប្រជាសាស្ត្រ ជំរឿន និងអង្កេត។ ខ្ញុំសូមអរគុណជាពិសេស ជូនចំពោះបងប្អូនជនរួមជាតិទាំងអស់ ដែលបានគាំទ្រ និង ចូលរួមសហការនៅក្នុងដំណើរការនៃប្រតិបត្តិការជំរឿនទូទៅនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ សម្រេចបានជោគជ័យ។

ខ្ញុំមានជំនឿយ៉ាងមុតមាំថា គ្រប់ក្រសួង ស្ថាប័នជាតិ ដៃគូអភិវឌ្ឍន៍ អង្គការជាតិ និងអន្តរជាតិគ្រឹះស្ថានសិក្សាស្រាវជ្រាវ វិស័យឯកជន និងសាធារណជនទូទៅ នឹងទទួលបាននូវអត្ថប្រយោជន៍ពីរបាយការណ៍នេះ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងផែនការ**

**កិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន**

# អារម្ភកថា

ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ ត្រូវបានដឹកនាំប្រតិបត្តិការដោយវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ។ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ គឺជាជំរឿនលើកទី ៤ នៅក្នុងការធ្វើជំរឿនជាបន្តបន្ទាប់នៅព្រះរាជាណាចក្រកម្ពុជា តាំងពីឆ្នាំ១៩៦២ ឆ្នាំ១៩៩៨ និងឆ្នាំ២០០៨។ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ បានធ្វើឡើងចាប់ពីថ្ងៃទី ៣ ដល់ថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០១៩ ហើយរបាយការណ៍ នេះបង្ហាញពីលទ្ធផលចុងក្រោយដែលរៀបចំដោយវិទ្យាស្ថានជាតិស្ថិតិ។ តារាងទិន្នន័យរួមមាន លម្អិតអំពីចំនួនប្រជាជនសរុប អត្រាកំណើនប្រចាំឆ្នាំ និងការបែងចែកប្រជាជន និងដង់ស៊ីតេប្រជាជន រចនាសម្ព័ន្ធអាយុនិងអាពាហ៍ពិពាហ៍ អក្ខរភាពនិងការអប់រំ កម្លាំងពលកម្មនិងការងារ លទ្ធភាពបង្កើតកូន មរណភាព ការផ្លាស់ប្តូរលំនៅដ្ឋាន ពិការភាព និងស្ថានភាពគ្រួសារ និងសម្ភារប្រើប្រាស់ក្នុងផ្ទះសម្បែង។

ខ្ញុំសូមថ្លែងអំណរគុណ ដ៏ជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានផ្តល់ការគាំទ្រស្ទើរតែទាំងស្រុងផ្នែកហិរញ្ញវត្ថុ។ ខ្ញុំសូមថ្លែងអំណរគុណ ចំពោះមូលនិធិសហប្រជាជាតិសម្រាប់ ប្រជាជន (UNFPA) ដែលបានដើរតួនាទី សម្របសម្រួលសម្រាប់ជំរឿន និងការគាំទ្រផ្នែកបច្ចេកទេសនិងថវិកាមួយចំណែក។ សូមថ្លែងអំណរគុណដល់សាធារណរដ្ឋប្រជាមានិតចិន ដែលបានផ្តល់សម្ភារៈចាំបាច់សម្រាប់ដំណើរការជំរឿនរួមមាន រថយន្ត ទោចក្រយានយន្ត កុំព្យូទ័រ ម៉ាស៊ីនព្រីនធ័រ ម៉ាស៊ីនថតចម្លង ជាដើម។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណដល់ ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត មន្ត្រីនៃវិទ្យាស្ថានជាតិស្ថិតិទាំងអស់ មន្ត្រីជំរឿនរាជធានី-ខេត្ត មន្ត្រីជំរឿនស្រុក-ខណ្ឌ-ក្រុង មន្ត្រីជំរឿនឃុំ-សង្កាត់ មេភូមិ មន្ត្រីត្រួតពិនិត្យ និងមន្ត្រីសម្ភាសន៍ ដែលបានខិតខំប្រឹងប្រែងក្នុងការប្រមូលទិន្នន័យតាមមូលដ្ឋាន ដែលអាចឱ្យយើងផលិតបាននូវទិន្នន័យដែលមានគុណភាពខ្ពស់។ ខ្ញុំសូមកោតសរសើរ ដល់សាធារណជនទូទៅ ដែលបានសហការល្អក្នុងការផ្តល់ព័ត៌មានដ៏មានសារសំខាន់បំផុតដោយគ្មានការលាក់លៀម។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ**

**ហាង់ លីណា**

# ផែនទី ខេត្តឧត្តរមានជ័យ



# ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩
# លទ្ធផលចុងក្រោយខេត្តឧត្តរមានជ័យ
## តួលេខសង្ខេប

| | | |
|---|---|---|
| ១. | ចំនួនរាជធានី | ០ |
| ២. | ចំនួនខេត្ត | ១ |
| ៣. | ចំនួនក្រុង | ១ |
| ៤. | ចំនួនខណ្ឌ | ០ |
| ៥. | ចំនួនស្រុក | ៤ |
| ៦. | ចំនួនសង្កាត់ | ៥ |
| ៧. | ចំនួនឃុំ | ១៩ |
| ៨. | ចំនួនភូមិ | ៣៣៩ |

៩. ចំនួនប្រជាជនតាមទីប្រជុំជន ជនបទ និងតាមភេទ

| តំបន់ | សរុប | ប្រុស | ស្រី |
|---|---|---|---|
| សរុប | ២៧៦.០៣៨ | ១៣៩.៣៧៨ | ១៣៦.៦៦០ |
| ទីប្រជុំជន | ៩១.២៩៨ | ៤៥.៧០៣ | ៤៥.៥៩៥ |
| ជនបទ | ១៨៤.៧៤០ | ៩៣.៦៧៥ | ៩១.០៦៥ |

| | | |
|---|---|---|
| ១០. | ភាគរយប្រជាជននៅទីប្រជុំជន | ៣៣,១ |
| ១១. | អត្រាកំណើនប្រជាជនប្រចាំឆ្នាំ | ៣,៦ |
| ១២. | សរុបចំនួនគ្រួសារ | ៦០.៨៨៦ |

១៣. ទំហំគ្រួសារមធ្យម (ផ្អែកលើគ្រួសារធម្មតា ឬគ្រួសារប្រក្រតី)

| | |
|---|---|
| សរុប | ៤,៤ |
| ទីប្រជុំជន | ៤,៥ |
| ជនបទ | ៤,៤ |

| | | |
|---|---|---|
| ១៤. | ភាគរយស្ត្រីជាមេគ្រួសារ | ១៧,៣ |
| ១៥. | ដង់ស៊ីតេប្រជាជនក្នុងមួយគីឡូម៉ែត្រការ៉េ | ៤៥ |

១៦. ភាគរយនៃប្រជាជនតាមក្រុមអាយុ

| | |
|---|---|
| ភាគរយប្រជាជនអាយុ ០-១៤ ឆ្នាំ | ៣៣,៧ |
| ភាគរយប្រជាជនអាយុ ១៥-៥៩ ឆ្នាំ | ៦០,៣ |
| ភាគរយប្រជាជនអាយុ ៦០ ឆ្នាំឡើង | ៥,៩ |

១៧. ផលធៀបអ្នកក្នុងបន្ទុក

| | |
|---|---|
| សរុប | ៦៥,៧ |
| ទីប្រជុំជន | ៦៤,៣ |
| ជនបទ | ៦៦,៥ |

១៨. ផលធៀបភេទ

| | |
|---|---|
| សរុប | ១០២,០ |
| ទីប្រជុំជន | ១០០,២ |
| ជនបទ | ១០២,៩ |

១៩ មេដ្យានអាយុ

| | |
|---|---|
| សរុប | ២៣ |
| ទីប្រជុំជន | ២៣ |
| ជនបទ | ២៣ |

២០. ភាគរយប្រជាជនអាយុ ១៥ ឆ្នាំឡើង តាមស្ថានភាពអាពាហ៍ពិពាហ៍(ភាគរយ)

| | ស្ថានភាពអាពាហ៍ពិពាហ៍ (ភាគរយ) | | | | |
|---|---|---|---|---|---|
| ភេទ | មិនដែលរៀបការ | រៀបការហើយ | មេម៉ាយពោះម៉ាយ | លែងលះ | រស់នៅផ្សេងគ្នា |
| សរុប | ២៤,៧ | ៧០,៧ | ២,៨ | ១,៧ | ០,១ |
| ប្រុស | ២៩,០ | ៦៨,៩ | ១,០ | ១,០ | ០,១ |
| ស្រី | ២០,៤ | ៧២,៥ | ៤,៦ | ២,៣ | ០,១ |

២១. អាយុមធ្យមរៀបអាពាហ៍ពិពាហ៍ដំបូង

| តំបន់ | ប្រុស | ស្រី |
|---|---|---|
| សរុប | ២៥ | ២២ |
| ទីប្រជុំជន | ២៦ | ២៣ |
| ជនបទ | ២៥ | ២២ |

២២. ភាគរយអក្ខរភាពមនុស្សពេញវ័យ(ប្រជាជនអាយុ ១៥ ឆ្នាំឡើង)

| តំបន់ | សរុប | ប្រុស | ស្រី |
|---|---|---|---|
| សរុប | ៧៩,៦ | ៨៤,៨ | ៧៤,៣ |
| ទីប្រជុំជន | ៨១,៨ | ៨៦,៣ | ៧៧,២ |
| ជនបទ | ៧៨,៥ | ៨៤,១ | ៧២,៨ |

២៣. ភាគរយអក្ខរភាពតាមកម្រិតសិក្សាអប់រំ (ប្រជាជនអាយុ ៧ ឆ្នាំឡើង)

| កម្រិតសិក្សា | សរុប | ប្រុស | ស្រី |
|---|---|---|---|
| មិនបានបញ្ចប់ថ្នាក់ណាមួយ | ១,០ | ១,០ | ១,០ |
| មិនបានបញ្ចប់ថ្នាក់បឋមសិក្សា | ៥០,២ | ៤៧,៨ | ៥៣,០ |
| បានបញ្ចប់ថ្នាក់បឋមសិក្សា | ២៨,៥ | ២៨,៨ | ២៨,២ |
| បានបញ្ចប់ថ្នាក់មធ្យមសិក្សាបឋមភូមិ | ១៧,៧ | ១៩,៣ | ១៦,០ |
| បានបញ្ចប់ថ្នាក់មធ្យមសិក្សា/មានសញ្ញាបត្រទុតិយភូមិ បានបញ្ចប់ថ្នាក់មធ្យមសិក្សាបឋមភូមិមានសញ្ញាបត្របច្ចេកទេស វិជ្ជាជីវៈ/សញ្ញាបត្រទុតិយភូមិមានសញ្ញាបត្របច្ចេកទេសវិជ្ជាជីវៈ | ១,៧ | ២,០ | ១,៤ |
| សញ្ញាបត្រមហាវិទ្យាល័យ សញ្ញាបត្រអនុបណ្ឌិត/សញ្ញាបត្របណ្ឌិត | ០,៨ | ១,១ | ០,៥ |

២៤. ភាគរយកំពុងសិក្សានៅសាលា ឬគ្រឹះស្ថានសិក្សា

| ក្រុមអាយុ | សរុប | ប្រុស | ស្រី |
|---|---|---|---|
| ០៦-១១ | ៩១,១ | ៩០,៣ | ៩២,១ |
| ១២-១៤ | ៩០,៨ | ៨៩,៦ | ៩២,០ |
| ១៥-១៧ | ៥៨,៥ | ៥៨,៧ | ៥៨,៤ |
| ១៨-២៤ | ១២,៦ | ១៣,៥ | ១១,៦ |
| ២៥ ឆ្នាំឡើង | ០,៣ | ០,៤ | ០,៣ |

២៥. ភាគរយប្រជាជនពិការ ធៀបប្រជាជនសរុប

| កម្រិតនៃពិការភាព | សរុប | ប្រុស | ស្រី |
|---|---|---|---|
| លំបាកខ្លះ | ៣,៩ | ៣,៥ | ៤,២ |
| លំបាកខ្លាំង និងមិនអាចធ្វើអ្វីទាំងអស់ | ១,០ | ១,០ | ១,០ |

២៦. ប្រភេទពិការភាព

| ប្រភេទពិការភាព<br>លំបាកក្នុងការមើល | សរុប | ប្រុស | ស្រី |
|---|---|---|---|
| លំបាកខ្លះ | ៣,១ | ២,៧ | ៣,៤ |
| លំបាកខ្លាំង និងមិនអាចធ្វើអ្វីទាំងអស់ | ០,៦ | ០,៥ | ០,៦ |
| **លំបាកក្នុងការស្តាប់** | | | |
| លំបាកខ្លះ | ២,៣ | ១,៩ | ២,៦ |
| លំបាកខ្លាំង និងមិនអាចធ្វើអ្វីទាំងអស់ | ០,៤ | ០,៤ | ០,៥ |
| **លំបាកក្នុងការផ្លាស់ទី ឬឡើងជណ្តើរ** | | | |
| លំបាកខ្លះ | ២,០ | ១,៧ | ២,៣ |

| | | | |
|---|---|---|---|
| លំបាកខ្លាំង និងមិនអាចធ្វើអ្វីទាំងអស់ | ០,៥ | ០,៥ | ០,៥ |
| លំបាកក្នុងការចងចាំ ឬការគិត | | | |
| លំបាកខ្លះ | ២,០ | ១,៧ | ២,២ |
| លំបាកខ្លាំង និងមិនអាចធ្វើអ្វីទាំងអស់ | ០,៤ | ០,៣ | ០,៥ |
| លំបាកក្នុងការថែទាំខ្លួន និងស្លៀកពាក់ | | | |
| លំបាកខ្លះ | ១,៥ | ១,៣ | ១,៧ |
| លំបាកខ្លាំង និងមិនអាចធ្វើអ្វីទាំងអស់ | ០,៣ | ០,២ | ០,៤ |
| លំបាកក្នុងការនិយាយ | | | |
| លំបាកខ្លះ | ១,៥ | ១,២ | ១,៧ |
| លំបាកខ្លាំង និងមិនអាចធ្វើអ្វីទាំងអស់ | ០,៤ | ០,៣ | ០,៤ |

២៧. ប្រជាជនអាយុ ១៥ ឆ្នាំឡើង តាមស្ថានភាពការងារជាក់ស្តែង

| សកម្មភាពសេដ្ឋកិច្ច | សរុប | ប្រុស | ស្រី |
|---|---|---|---|
| អត្រាចូលរួមកម្លាំងពលកម្ម | ៨៦,៧ | ៨៩,៧ | ៨៣,៧ |
| អត្រាមានការងារធ្វើ | ៩៩,៧ | ៩៩,៧ | ៩៩,៦ |
| អត្រាគ្មានការងារធ្វើ | ០,៣ | ០,៣ | ០,៤ |
| អសកម្មជនសេដ្ឋកិច្ច | ១៣,៣ | ១០,៣ | ១៦,៣ |

២៨. ភាគរយប្រជាជនផ្លាស់លំនៅដ្ឋាន តាមតំបន់

| ការផ្លាស់លំនៅដ្ឋាន | សរុប | ប្រុស | ស្រី |
|---|---|---|---|
| ជនបទ ទៅជនបទ | ៥៣,០ | ៥៣,២ | ៥២,៨ |
| ជនបទ ទៅ ទីប្រជុំជន | ២៦,៤ | ២៥,៧ | ២៧,០ |
| ទីប្រជុំជន ទៅជនបទ | ១១,០ | ១១,៥ | ១០,៥ |
| ទីប្រជុំជន ទៅទីប្រជុំជន | ៩,៦ | ៩,៥ | ៩,៧ |

២៩. ភាគរយអាគារ តាមលក្ខណៈសំណង់

| លក្ខណៈសំណង់ | សរុប | ទីប្រជុំជន | ជនបទ |
|---|---|---|---|
| អចិន្ត្រៃយ៍ | ៩៣,៧ | ៩២,៥ | ៩៤,៣ |
| ពាក់កណ្តាលអចិន្ត្រៃយ៍ | ៤,៩ | ៥,៤ | ៤,៧ |
| បណ្តោះអាសន្ន | ១,៤ | ២,១ | ១,០ |

៣០. ភាគរយគ្រួសារបែងចែកតាមប្រភពទឹកសម្រាប់ពិសា

| ប្រភេទប្រភពទឹក | សរុប | ទីប្រជុំជន | ជនបទ |
|---|---|---|---|
| ទឹកម៉ាស៊ីនបណ្តាញ | ៦,៧ | ១២,៩ | ៣,៦ |
| ទឹកបំពង់បណ្តាញក្នុងទីធ្លា/បរិវេណលំនៅដ្ឋាន | ២,០ | ២,១ | ១,៩ |
| ទឹកបំពង់សាធារណៈ | ១,០ | ១,០ | ១,០ |
| ទឹកអណ្តូងស្នប់ | ១៤,០ | ៥,១ | ១៨,២ |

| | | | |
|---|---|---|---|
| ទឹកអណ្តូងដីកមានគម្របការពារ | ៣,៦ | ៣,១ | ៣,៩ |
| ទឹកអណ្តូងដីកគ្មានគម្របការពារ | ៣,៦ | ៣,៣ | ៣,៨ |
| ទឹកចេញក្រោមដីមានការការពារ | ០,២ | ០,២ | ០,២ |
| ទឹកចេញក្រោមដីគ្មានការការពារ | ០,៣ | ០,៨ | ០,១ |
| ទឹកភ្លៀង | ១,២ | ១,៣ | ១,២ |
| ទឹកលើដី ( ទន្លេ អូរ បឹង ត្រពាំង.... ) | ២១,៣ | ២៣,៦ | ២០,២ |
| ទឹកទិញឡានស៊ីទែន | ១១,២ | ១២,៣ | ១០,៦ |
| ទឹកទិញធុងរទេះ | ២៤,៨ | ១៦,០ | ២៩,០ |
| ទឹកដប/ទឹកពិសាដប | ៩,៩ | ១៨,០ | ៦,០ |
| ប្រភពទឹកផ្សេងទៀត | ០,២ | ០,១ | ០,៣ |

៣១. ភាគរយគ្រួសារប្រើប្រាស់អគ្គិសនី ជាប្រភពសំខាន់សម្រាប់បំភ្លឺ

| | |
|---|---|
| សរុប | ៤៦,៣ |
| ទីប្រជុំជន | ៥០,៧ |
| ជនបទ | ៤៤,២ |

៣២. ភាគរយគ្រួសារបែងចែកតាមឥន្ធនៈចម្អិនអាហារ

| ប្រភេទឥន្ធនៈ | សរុប | ទីប្រជុំជន | ជនបទ |
|---|---|---|---|
| ឧស | ៤៥,៧ | ៣៩,២ | ៤៩,០ |
| ធ្យូង | ៤៣,៣ | ៤៣,៥ | ៤៣,២ |
| ប្រេងកាត | ០,៧ | ០,៩ | ០,៦ |
| ឧស្ម័ន ហ្គាស | ៨,៤ | ១៣,៤ | ៥,៩ |
| អគ្គិសនី | ១,៧ | ២,៨ | ១,១ |
| គ្មាន | ០,២ | ០,២ | ០,១ |
| ផ្សេងទៀត | ០,១ | ០,១ | ០,០ |

៣៣. ភាគរយគ្រួសារបានប្រើប្រាស់បង្គន់ និងប្រភេទបង្គន់

| ប្រភេទបង្គន់ | សរុប | ទីប្រជុំជន | ជនបទ |
|---|---|---|---|
| មិនប្រើបង្គន់ | ២៩,៥ | ២៧,៦ | ៣០,៤ |
| បង្គន់ចាក់ទឹក ឬ( ចុចបង្ហូរទឹក )តភ្ជាប់ទៅប្រព័ន្ធលូ | ៨,៥ | ១២,៦ | ៦,៥ |
| បង្គន់ចាក់ទឹក ឬ( ចុចបង្ហូរទឹក )តភ្ជាប់ទៅអាងស្តុក ឬរណ្តៅ | ៤៧,៣ | ៤៧,៣ | ៤៧,២ |
| បង្គន់ចាក់ទឹកឬ( ចុចបង្ហូរទឹក )បង្ហូរទៅកន្លែងផ្សេង | ៥,៧ | ៤,០ | ៦,៥ |
| បង្គន់រណ្តៅមានចានបង្គន់ | ៦,១ | ៦,៦ | ៥,៨ |
| បង្គន់រណ្តៅគ្មានចានបង្គន់ | ២,៦ | ១,៦ | ៣,១ |
| បង្គន់បត់ជើងទម្លាក់ ឬក្នុងទឹក ( ត្រពាំង/បឹង/ទន្លេ/សមុទ្រ ) | ០,២ | ០,២ | ០,២ |
| បង្គន់ផ្សេងទៀត | ០,២ | ០,១ | ០,៣ |

៣៤. ភាគរយគ្រួសារប្រើអ៊ីនធឺណិត

| ការប្រើអ៊ីនធឺណិត | |
|---|---|
| ប្រើអ៊ីនធឺណិត (ប្រើនៅផ្ទះ ឬទីសាធារណៈ) | ៥១,៦ |
| ប្រើនៅផ្ទះ | ២៧,៦ |
| ប្រើនៅទីសាធារណៈ | ១,៤ |
| ប្រើនៅផ្ទះ និងទីសាធារណៈ | ២២,៦ |

៣៥. អត្រាលទ្ធភាពបង្កើតកូន

| | |
|---|---|
| សរុប | ២,៩ |
| ទីប្រជុំជន | ៣,០ |
| ជនបទ | ២,៩ |

៣៦. អត្រាមរណភាពទារក ក្នុង ១.០០០ កំណើតរស់

| | |
|---|---|
| សរុប | ១៨,៩ |
| ទីប្រជុំជន | ២១,៨ |
| ជនបទ | ១៧,៤ |

៣៧. អត្រាមរណភាពកុមារអាយុក្រោម ៥ ឆ្នាំ ក្នុង ១.០០០ នាក់

| | |
|---|---|
| សរុប | ៣០,២ |
| ទីប្រជុំជន | ៣៤,៨ |
| ជនបទ | ២៧,៨ |

៣៨. អាយុសង្ឃឹមរស់

| តំបន់ | សរុប | ប្រុស | ស្រី |
|---|---|---|---|
| សរុប | ៧៣,៧ | ៧៣,១ | ៧៥,៨ |
| ទីប្រជុំជន | ៧៤,៣ | | |
| ជនបទ | ៧២,៦ | | |

# ផ្នែក ១

## របាយការណ៍ ខេត្ត ឧត្តរមានជ័យ


ជំពូក ១. សេចក្តីផ្តើម

ជំពូក ២. ទំហំ កំណើន និងការបែងចែករបាយប្រជាជន

ជំពូក ៣. សមាសភាពភេទ ការបែងចែកអាយុ និងស្ថានភាពអាពាហ៍ពិពាហ៍

ជំពូក ៤. អក្ខរកម្ម និងការអប់រំ

ជំពូក ៥. កម្លាំងពលកម្ម និងការងារ

ជំពូក ៦. ទេសន្តរប្រវេសន៍

ជំពូក ៧. លទ្ធភាពបង្កើតកូន

ជំពូក ៨. មរណភាព

ជំពូក ៩. ពិការភាព

ជំពូក ១០. លំនៅដ្ឋាន ចរិតលក្ខណៈគ្រួសារ និងសម្ភារៈប្រើប្រាស់ក្នុងគ្រួសារ

ជំពូក ១១. សេចក្តីសង្ខេប និងសន្និដ្ឋាន

# ជំពូក ១
# សេចក្តីផ្តើម

## ១.១. សាវតា

ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ គឺជាជំរឿនលើកទី៤ ដែលបានធ្វើជាបន្តបន្ទាប់នៅព្រះរាជាណាចក្រកម្ពុជា ហើយជំរឿនឆ្នាំ២០១៩ ស្ថិតនៅក្នុងជំរឿនវិលជុំទីដប់នៃជំរឿនពិភពលោកឆ្នាំ២០២០ ដែលផ្តល់អនុសាសន៍ដោយអង្គការសហប្រជាជាតិ។ ការធ្វើជំរឿនលើកដំបូងនៅកម្ពុជាបានធ្វើនៅឆ្នាំ១៩៦២ ជាមួយការអនុវត្តជាបន្តបន្ទាប់ ដែលត្រូវបានធ្វើឡើងនៅឆ្នាំ១៩៩៨ និងឆ្នាំ២០០៨។ ប្រទេសកម្ពុជានៅតែសម្រេចចិត្តប្រើកម្រងសំណួរជាក្រដាស និងខ្មៅដៃក្នុងការប្រមូលទិន្នន័យ។ កិច្ចការនេះតម្រូវឲ្យមានការរៀបចំយ៉ាងហ្មត់ចត់ លើការរៀបចំកម្រងសំណួរ សេចក្តីណែនាំផ្សេងៗ ការបណ្តុះបណ្តាលស្រង់ទិន្នន័យសាកល្បង ការធ្វើជំរឿននាំមុខជាដើម។ល។

ដំណើរការនៃការរៀបចំការងារជំរឿនជាផ្លូវការចាប់ផ្តើមនៅឆ្នាំ២០១៦ តាមរយៈការរៀបចំព្រាងឯកសារស្តីពីផែនការធ្វើជំរឿនដែលត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា និងគណៈកម្មាធិការជាតិជំរឿននៅឆ្នាំ២០១៧។ យុទ្ធសាស្ត្រនៃការធ្វើជំរឿនត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៧ ដែលសម្រេចអនុញ្ញាតអនុវត្តការប្រមូលទិន្នន័យចាប់ផ្តើមនៅថ្ងៃទី ០៣ ខែមីនា ឆ្នាំ២០១៩។ វិទ្យាស្ថានជាតិស្ថិតិបានគូសផែនទីជំរឿន ដោយប្រើផែនទីព្រាងដោយដៃនៅទូទាំងប្រទេសហើយបានកំណត់ជាមណ្ឌលជំរឿន ។

លទ្ធផលសម្រេចបានពីការធ្វើជំរឿនទាំងបីលើក បានផ្តល់ទិន្នន័យប្រជាសាស្ត្រដមានតម្លៃសម្រាប់ជំរឿនបានធ្វើឲ្យរាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាបន្តពង្រឹងសមត្ថភាពតាមរយៈការធ្វើជំរឿន ដែលហៅថា "ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩" ដោយបានដាក់បញ្ចូលទិន្នន័យទាក់ទងប្រជាជន និងលក្ខណៈផ្ទះសំបែងមួយចំនួន សម្រាប់ការវាយតម្លៃនិងរៀបចំផែនការ។

## ១.២. រចនាសម្ព័ន្ធចាត់តាំងជំរឿន

ដូចគ្នាទៅនឹងជំរឿនលើកមុនៗដែរ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ បានបង្កើតគណៈកម្មាធិការជំរឿនចំនួន ៣ (បី) គឺៈ គណៈកម្មាធិការជាតិជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ ដឹកនាំដោយ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** គណៈកម្មាធិការនេះ គឺជាស្ថាប័នកំពូលដែលមានសមាសភាពកម្រិតមន្ត្រីនយោបាយមកពីក្រសួងពាក់ព័ន្ធនានា មានភារៈទទួលខុសត្រូវក្នុងការសម្រេចចិត្តគ្រប់គោលនយោបាយទាំងអស់ ដែលទាក់ទងទៅនឹងការងារជំរឿន។ គណៈកម្មការបច្ចេកទេសជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ ដឹកនាំដោយ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិតឆាយ ថន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ** សម្រាប់ដោះស្រាយគ្រប់ភារៈកិច្ចទាំងឡាយណាដែលទាក់ទងនឹងការងារបច្ចេកទេស ដូចជាការរៀបចំកម្រងសំណួរ ឯកសារណែនាំអំពីតួនាទី ភារកិច្ចមន្ត្រីសម្ភាសន៍ និង

មន្ត្រីត្រួតពិនិត្យ វិធីសាស្ត្របង្រៀន សេចក្តីណែនាំសម្ភាសន៍ ដឹកនាំចុះធ្វើជំរឿននាំមុខ ការបណ្តុះបណ្តាល ដឹកនាំយុទ្ធនាការប្រតិបត្តិការប្រមូលទិន្នន័យ ការកែដៃ និងដាក់លេខកូដ ការបញ្ចូលទិន្នន័យក្នុងប្រព័ន្ធកុំព្យូទ័រ និងការវិភាគរបាយការណ៍។ គណៈកម្មាធិការមួយទៀត គឺគណៈកម្មការឃោសនាជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ ដឹកនាំដោយ **ឯកឧត្តមអភិសន្តិសេដ្ឋាបណ្ឌិត ឆាយ ថន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងផែនការ** គណៈកម្មការនេះមានតួនាទីពិនិត្យ និងផ្តល់យោបល់លើការផលិតសម្ភារៈឃោសនា រួមមាន Spot ទូរទស្សន៍ និងសម្ភារៈឃោសនាផ្សេងៗទៀត មានដូចជា បដា សន្លឹកព័ត៌មានជំរឿន អាវយឺត កាបូបជាដើម។

ក្រសួងផែនការទទួលខុសត្រូវរួមលើប្រតិបត្តិការជំរឿន ដែលមានវិទ្យាស្ថានជាតិស្ថិតិ ជាសេនាធិការអនុវត្តដូចដែលបានបញ្ជាក់ខាងដើម។

ដោយឡែកមន្ទីរផែនការរាជធានី ខេត្ត ដើរតួនាទីជាការិយាល័យជំរឿនខេត្តក្នុងអំឡុងពេលធ្វើជំរឿន ដែលប្រធានមន្ទីរផែនការរាជធានី ខេត្ត បំពេញតួនាទីជាមន្ត្រីជំរឿនខេត្ត។ មន្ត្រីជំរឿនខេត្តមានជំនួយការម្នាក់ ជាមន្ត្រីជំនួយការជំរឿនខេត្ត។ មន្ត្រីជំរឿនខេត្ត ជាមន្ត្រីជំរឿនដែលមានតួនាទីខ្ពស់ជាងគេ ទទួលបន្ទុកប្រតិបត្តិការជំរឿនក្នុងខេត្ត។ មន្ត្រីជំរឿនថ្នាក់ក្រុង ខណ្ឌ ស្រុក ឃុំ សង្កាត់ និងភូមិ ស្ថិតក្រោមការត្រួតពិនិត្យរួមរបស់មន្ត្រីជំរឿនខេត្ត។ អភិបាលរាជធានី ខេត្ត គឺជាប្រធានគណៈកម្មាធិការជំរឿនថ្នាក់រាជធានី ខេត្ត ដែលមានភារកិច្ចដឹកនាំមន្ត្រីជំរឿនខេត្ត។ មន្ត្រីជំរឿនតំបន់ពីវិទ្យាស្ថានជាតិស្ថិតិ ផ្តល់ជំនួយបច្ចេកទេសដល់មន្ត្រីជំរឿនខេត្ត។

## ១.៣. ដំណាក់កាលរាប់សម្ភាសន៍

ជំរឿនឆ្នាំ២០១៩ បានរាប់សម្ភាសគ្រួសារធម្មតាចំនួន ៣,៦ លានគ្រួសារទូទាំង ២៥ រាជធានី ខេត្ត ដោយបើកយុទ្ធនាការប្រតិបត្តិការចុះបញ្ជីផ្ទះ ពីថ្ងៃទី២៨ រហូតដល់ថ្ងៃទី ២ ខែមីនា ឆ្នាំ២០១៩ និងរាប់សម្ភាសគ្រួសារ (តារាង២) ម៉ោង ០០ ឈានចូលថ្ងៃទី ៣ រហូតដល់ថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០១៩ ដោយមានមន្ត្រីសម្ភាសន៍បួនម៉ឺននាក់ និងមន្ត្រីត្រួតពិនិត្យមួយម៉ឺននាក់ បានចុះស្រង់ទិន្នន័យនៅគ្រប់មណ្ឌលជំរឿន ក្នុងភូមិទាំងអស់ ១៤.៥៤៥ ភូមិ និង ៣៨.៤៧ មណ្ឌលជំរឿន ហើយនិងមណ្ឌលជំរឿនពិសេស ដូចជាបន្ទាយយោធា បន្ទាយនគរបាល សាលាយោធា សាលានគរបាល ពន្ធនាគារ មន្ទីរពេទ្យយោធា មន្ទីរពេទ្យនគរបាល មជ្ឈមណ្ឌលអប់រំកែប្រែ មណ្ឌលថែទាំកុមារកំព្រា ដោយប្រើមន្ត្រីពិសេសចំនួន ៣.៥០០ នាក់ ។

គ្រួសារនៅទូទាំងប្រទេសត្រូវបានរាប់សម្ភាសក្នុងរយៈពេល ១១ ថ្ងៃ។ ខេត្តចំនួន ២៣ ការរាប់សម្ភាសគ្រួសារ (តារាង២) ប្រព្រឹត្តទៅដោយរលូន និងបញ្ចប់ទៅប្រកបដោយជោគជ័យតាមផែនការគ្រោងទុក គឺថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០១៩។ ដោយឡែក ខេត្តព្រះសីហនុត្រូវបានពន្យារយៈពេលរាប់សម្ភាសចំនួនបីថ្ងៃ ដោយប្រើកម្លាំងពិសេសរបស់វិទ្យាស្ថានជាតិស្ថិតិដែលបានបញ្ចប់ពីរាជធានី ខេត្តផ្សេង ដោយសារចំនួនគ្រួសារកើនច្រើនលើសលប់ ជាពិសេសជនជាតិចិន និងគ្រួសារថ្មី។ ដោយឡែក រាជធានីភ្នំពេញក៏ត្រូវបានពន្យាពេលរហូតដល់ថ្ងៃទី ២០ ខែមីនា ឆ្នាំ២០១៩ ដោយសារចំនួនគ្រួសារកើនច្រើនលើសលប់មិនអាចគ្រប់គ្រងបាន ដូចជាសំណង់អាគារ បុរី និងផ្ទះល្វែងរីកលូតលាស់មិនអាចគ្រប់គ្រងបាន។ បន្ថែមលើគ្រួសារដែលមានរស់នៅក្នុងលំនៅដ្ឋានធម្មតា អ្នកដែលស្នាក់នៅក្នុងគ្រួសារស្ថាប័ន

ដូចជាផ្ទះសំណាក់ សណ្ឋាគារ វត្តអារាម មន្ទីរពេទ្យ ពន្ធនាគារ។ល។ ត្រូវបានរាប់សម្ភាសផងដែរ។ ប្រជាជនដែលគ្មានផ្ទះសំបែង រស់នៅលើទូកក៏ត្រូវបានរាប់សម្ភាសនៅយប់ជំរឿនផងដែរ។

ទោះជាយ៉ាងណាក៏ដោយ ផ្នែកខ្លះនៃតំបន់ដាច់ស្រយាល និងតំបន់ព្រៃភ្នំ មន្ត្រីសម្ភាសន៍ត្រូវធ្វើដំណើរថ្មើរជើងក្នុងចម្ងាយផ្លូវយ៉ាងឆ្ងាយ។ ក្នុងករណីចាំបាច់ រថយន្ត យោចក្រយានយន្ត កង់ និងទូក ត្រូវប្រើប្រាស់ដោយមន្ត្រីមូលដ្ឋាន។ ទូរស័ព្ទចល័តបានផ្តល់សារប្រយោជន៍ក្នុងអំឡុងពេលធ្វើជំរឿនឆ្នាំ២០១៩។ ទូរស័ព្ទចល័តបានជួយសម្រួលដល់គ្រូបង្គោល មន្ត្រីត្រួតពិនិត្យ និងមន្ត្រីសម្ភាសន៍អាចទាក់ទងគ្នាបានឆាប់រហ័ស នៅពេលមន្ត្រីសម្ភាស៍ត្រូវការបកស្រាយបញ្ជាក់រាល់កិច្ចការជំរឿន។

## តារាងកាលវិភាគនៃសកម្មភាពជំរឿនសំខាន់ៗ

| កាលបរិច្ឆេទ | សកម្មភាព |
|---|---|
| ថ្ងៃទី ២៨ កុម្ភៈ ដល់ថ្ងៃទី ២ មីនា ឆ្នាំ២០១៩ (៣ថ្ងៃ) | ចុះបញ្ជីលំនៅដ្ឋានក្នុងមណ្ឌលជំរឿន និងធ្វើបច្ចុប្បន្នកម្មផែនទីមណ្ឌលជំរឿន |
| យប់ថ្ងៃទី ៣ មីនា ឆ្នាំ២០១៩ | រាប់សម្ភាសជនគ្មានផ្ទះសំបែង ប្រជាជនឆ្លងកាត់ |
| ថ្ងៃទី ៣ ដល់ថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០១៩ (១១ថ្ងៃ) | រាប់សម្ភាសជំរឿនឆ្នាំ២០១៩ នៅម៉ោង(00:00) ជាម៉ោងយោង |
| ថ្ងៃទី ១៣ ដល់ថ្ងៃទី ១៤ ខែមីនា ឆ្នាំ២០១៩ | ប្រមូលកម្រងសំណួរជំរឿនដែលបំពេញរួចនៅការិយាល័យមូលដ្ឋាន |
| ថ្ងៃទី ១៥ ដល់ថ្ងៃទី ២២ ខែមីនា ឆ្នាំ២០១៩ | ទទួលសំណួរជំរឿនដែលបំពេញរួចនៅវិទ្យាស្ថានជាតិស្ថិតិភ្នំពេញ |

# ជំពូក ២
# ទំហំ កំណើន និងការបែងចែកប្រជាជន

## ២.១. ចំនួនប្រជាជនសរុប

ប្រជាជនខេត្តឧត្តរមានជ័យរស់នៅទីប្រជុំជននៅឆ្នាំ២០០៨ មាន ១៨.៦៩៤ កើនទៅ ៩១.២៩៨ នាក់ នៅឆ្នាំ២០១៩។ និន្នាការដូចគ្នានេះប្រជាជនខេត្តឧត្តរមានជ័យរស់នៅជនបទបានថយចុះពី ១៦៧.១២៥ នាក់ នៅឆ្នាំ២០០៨ មក ១៨៤.៧៤០ នាក់ នៅឆ្នាំ២០១៩។ ភាគរយប្រជាជនរស់នៅទីប្រជុំជនបានកើនឡើងពី ១០,១ ភាគរយ នៅឆ្នាំ២០០៨ មក ៣៣,១ ភាគរយ នៅឆ្នាំ២០១៩ ដោយសារការរីកចំរើនខាងវិស័យការងារ កំណើនប្រជាជន និងនគរូបនីយកម្ម ។

បើតាមលទ្ធផលចុងក្រោយបង្ហាញថាក្នុងចំណោមក្រុង ស្រុកទាំង ៥ នៃខេត្តឧត្តរមានជ័យប្រជាជនខ្ពស់មាននៅក្រុងសំរោង (២៦,៤ ភាគរយ) នៅស្រុកត្រពាំងប្រាសាទ (២២,៥ ភាគរយ) នៅស្រុកអន្លង់វែង (២១,២ ភាគរយ) និងស្រុកបន្ទាយអំពិល (១៩,៨ ភាគរយ) ។ ស្រុកទាំងនេះមានអត្រាលទ្ធភាពបង្កើតកូនខ្ពស់ និងស្រូបយកការធ្វើចំណាកស្រុកមកពីបណ្ដាស្រុក និងខេត្តផ្សេងទៀតសម្រាប់ការតាំងលំនៅថ្មី និងធ្វើកសិកម្ម ឱកាសសេដ្ឋកិច្ច និងការអភិវឌ្ឍ។ ដោយឡែកស្រុកចុងកាល់មានភាគរយប្រជាជនប្រជាជនតិចជាងគេ (៩,៨)។

រូប ២.១.២. ចំនួនប្រជាជនសរុប ខេត្តឧត្តរមានជ័យ ឆ្នាំ២០១៩



## ២.២. កំណើនប្រជាជនប្រចាំឆ្នាំ

កំណើនចំនួនប្រជាជនត្រូវបានប្រើក្នុងន័យទូលំទូលាយ ដើម្បីគ្របដណ្ដប់លើការបំរែបំរួលចំនួនប្រជាជនដែលរស់នៅក្នុងប្រទេស ឬតំបន់ ក្នុងអំឡុងពេលជាក់លាក់ដោយមិនគិតការបំរែបំរួលផ្លាស់ប្ដូរវិជ្ជមាន ឬអវិជ្ជមាន។ បំរែបំរួលនេះត្រូវបានវាស់វែង ដោយគិតជាភាគរយ។

លទ្ធផលចុងក្រោយនៃជំរឿនទូទៅប្រជាជននៅខេត្តឧត្តរមានជ័យ ឆ្នាំ២០១៩ តាមវិធីសាស្ត្រឃើញរាប់ ចំនួនប្រជាជនខេត្តឧត្តរមានជ័យសរុបកើនឡើងត្រឹមតែ ៩.២១៩ នាក់ ត្រូវនឹង ៤៨,៦ ភាគរយ ក្នុងរយៈពេល ១១ ឆ្នាំ ចន្លោះឆ្នាំ២០០៨ និង ២០១៩ ក្នុងអត្រាកំណើនប្រចាំឆ្នាំ ៣,៦ ភាគរយ។ អត្រាកំណើនប្រជាជនប្រចាំឆ្នាំបានកើនឡើងអាចដោយសារលទ្ធភាពបង្កើតកូន និងការធ្វើចំណាកស្រុករបស់ប្រជាជនខេត្តឧត្តរមានជ័យទៅមកពីខេត្តនានា ។

តាមលទ្ធផលចុងក្រោយនៃជំរឿនទូទៅប្រជាជនខេត្តឧត្តរមានជ័យឆ្នាំ២០១៩ (កំណើនប្រជាជន ៣,៦ ភាគរយ) អត្រាកំណើនប្រជាជនមានកម្រិតខ្ពស់នៅស្រុកត្រពាំងប្រាសាទ (៥,៩ ភាគរយ) នៅស្រុកអន្លង់វែង (៣,៧ ភាគរយ) នៅក្រុងសំរោង (៣,២ ភាគរយ) ស្រុកបន្ទាយអំពិល (២,៦ ភាគរយ) និងចុងកាល់(២,៣ ភាគរយ) ។ ស្រុកទាំងនេះមានអត្រាលទ្ធភាពបង្កើតកូនទាប និងស្រូបយកការធ្វើចំណាកស្រុកមកពីបណ្ដាស្រុក និងខេត្តផ្សេងទៀតសម្រាប់ការតាំងលំនៅថ្មី និងធ្វើកសិកម្ម ឱកាសសេដ្ឋកិច្ច និងការអភិវឌ្ឍខ្ពស់។

តារាង ២.២.១. អត្រាកំណើនប្រជាជនប្រចាំឆ្នាំ តាមក្រុង ស្រុក ខេត្តឧត្តរមានជ័យ ឆ្នាំ២០០៨-២០១៩

| ក្រុង ស្រុក | ចំនួនប្រជាជនសរុប | | |
|---|---|---|---|
| | ២០០៨ | ២០១៩ | ២០០៨-២០១៩ |
| (១) | (២) | (៣) | (៥) |
| **សរុប** | ១៨៥.៨១៩ | ២៧៦.០៣៨ | ៣,៦ |
| **ទីប្រជុំជន** | ១៨.៦៩៤ | ៩១.២៩៨ | ១៤,៤ |
| **ជនបទ** | ១៦៧.១២៥ | ១៨៤.៧៤០ | ០,៩ |
| អន្លង់វែង | ៣៩.០៤៥ | ៥៨.៣៨៩ | ៣,៧ |
| បន្ទាយអំពិល | ៤១.០០៥ | ៥៤.៧១៦ | ២,៦ |
| ចុងកាល់ | ២១.៧៤៩ | ២៧.៩១០ | ២,៣ |
| ក្រុងសំរោង | ៥១.៤១៤ | ៧២.៨០៣ | ៣,២ |
| ត្រពាំងប្រាសាទ | ៣២.៦០៦ | ៦២.២២០ | ៥,៩ |

**សម្គាល់ ៖** តួលេខនេះមិនរាប់បញ្ចូលពលករចំណាកស្រុកទៅក្រៅប្រទេស

## ២.៣. ការបែងចែករបាយប្រជាជន

តារាង ២.៣.១ បង្ហាញភាគរយប្រជាជនសរុបចុងក្រោយ តាមស្រុក ក្រុង និងភេទ ខេត្តឧត្តរមានជ័យប្រជាជនខ្ពស់មាននៅក្រុងសំរោង (២៦,៤ ភាគរយ) នៅស្រុកត្រពាំងប្រាសាទ (២២,៥ ភាគរយ) នៅស្រុកអន្លង់វែង (២១,២ ភាគរយ) និងស្រុកបន្ទាយអំពិល (១៩,៨ ភាគរយ) ។ ស្រុកទាំងនេះមានអត្រាលទ្ធភាពបង្កើតកូនខ្ពស់ និងស្រូបយក

ការធ្វើចំណាកស្រុកមកពីបណ្តាស្រុក និងខេត្តផ្សេងទៀតសម្រាប់ការតាំងលំនៅថ្មី និងធ្វើកសិកម្ម ឱកាសសេដ្ឋកិច្ច និងការអភិវឌ្ឍ។ ដោយឡែកស្រុកចុងកាល់មានភាគរយប្រជាជនប្រជាជនតិចជាងគេ (៩,៨)។

បើប្រៀបធៀបទៅនឹងឆ្នាំ២០០៨របាយប្រជាជនខេត្តឧត្តរមានជ័យមានទម្រង់ប្រហាក់ប្រហែលគ្នាទៅនឹងឆ្នាំ២០១៩ដែរ។ ភាគរយនៃរបាយប្រជាជនក្នុងស្រុក ក្រុង កើនឡើងស្ទើរតែទាំងអស់លើកលែងតែលើកលែងតែក្រុងក្រុងសំរោង ស្រុកចុងកាល់ និងស្រុកបន្ទាយអំពិលមានភាគរយនៃរបាយប្រជាជនបានថយចុះ។

### តារាង ២.៣.១. ភាគរយប្រជាជនសរុប តាមភេទ តំបន់ ក្រុង ស្រុក ខេត្តឧត្តរមានជ័យ ឆ្នាំ២០០៨-២០១៩

| រាជធានី ខេត្ត | ឆ្នាំ ២០០៨ | | | ឆ្នាំ ២០១៩ | | |
|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) |
| **សរុប** | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |
| **ទីប្រជុំជន** | ១០,១ | ១០,១ | ១០,០ | ៣៣,១ | ៣២,៨ | ៣៣,៤ |
| **ជនបទ** | ៨៩,៩ | ៨៩,៩ | ៩០,០ | ៦៦,៩ | ៦៧,២ | ៦៦,៦ |
| អន្លង់វែង | ២១,០ | ២១,៣ | ២០,៧ | ២១,២ | ២១,៥ | ២០,៨ |
| បន្ទាយអំពិល | ២២,១ | ២១,៨ | ២២,៣ | ១៩,៨ | ១៩,៩ | ១៩,៧ |
| ចុងកាល់ | ១១,៧ | ១១,១ | ១២,៤ | ១០,១ | ៩,៨ | ១០,៥ |
| ក្រុងសំរោង | ២៧,៧ | ២៧,៦ | ២៧,៧ | ២៦,៤ | ២៦,២ | ២៦,៦ |
| ត្រពាំងប្រាសាទ | ១៧,៥ | ១៨,១ | ១៦,៩ | ២២,៥ | ២២,៧ | ២២,៤ |

**សម្គាល់ ៖** តួលេខនេះមិនរាប់បញ្ចូលពលករចំណាកស្រុកទៅក្រៅប្រទេស

## ២.៤. ដង់ស៊ីតេប្រជាជន

យោងតាមលទ្ធផលចុងក្រោយនៃជំរឿនទូទៅប្រជាជននៅខេត្តឧត្តរមានជ័យ ឆ្នាំ២០១៩ តាមវិធីសាស្ត្រឃើញរាប់ ដង់ស៊ីតេប្រជាជនខេត្តឧត្តរមានជ័យមាន ៤៥ នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េកើនឡើង ១៥ នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ ពី ៣០ នាក់ នៅឆ្នាំ ២០០៨ ។

ដង់ស៊ីតេប្រជាជនតាមតំបន់សម្រាប់ឆ្នាំ២០០៨ និងឆ្នាំ២០១៩ លទ្ធផលចុងក្រោយបានបង្ហាញថាដង់ស៊ីតេប្រជាជនមានការប្រែប្រួលយ៉ាងខ្លាំងនៅតាមតំបន់ភូមិសាស្ត្រនៃខេត្តឧត្តរមានជ័យ។ ដង់ស៊ីតេប្រជាជននៅតំបន់ទន្លេសាប មាន ៦២ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េខ្ពស់ជាងខេត្តឧត្តរមានជ័យ (៤៥ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ) ។ បើធៀបទៅនឹងឆ្នាំ២០០៨ ដង់ស៊ីតេប្រជាជនតំបន់ទន្លេសាបកើន ៦ នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ ។ ដង់ស៊ីតេប្រជាជនស្រុកអន្លង់វែងមានខ្ពស់ជាងគេ (១៤២ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ) ក្រុងសំរោង (៧៥ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ) ស្រុកត្រពាំងប្រាសាទ (៤៤ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ) ស្រុកបន្ទាយមាស (១៩៧ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ) ស្រុកបន្ទាយអំពិល (៣៦ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ) ដោយឡែកស្រុកចុងកាល់មានដង់ស៊ីតេប្រជាជនទាបជាងគេ (២៣ នាក់និង៧៧ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ)

តារាង ២.៤.១ បង្ហាញពីដង់ស៊ីតេប្រជាជនតាមស្រុក ក្រុង ខេត្តឧត្តរមានជ័យ ឆ្នាំ២០០៨ និងឆ្នាំ២០១៩ ។ ដង់ស៊ីតេប្រជាជនក្នុងស្រុក ក្រុងខេត្តឧត្តរមានជ័យកើនឡើងទាំងអស់ ។

**តារាង ២.៤.១. ការបែងចែករបាយផ្ទៃដី និងដង់ស៊ីតេប្រជាជន តាមស្រុក ក្រុងខេត្តឧត្តរមានជ័យ ឆ្នាំ២០០៨-២០១៩**

| រាជធានី/ខេត្ត | ចំនួនប្រជាជនសរុប | | ដង់ស៊ីតេប្រជាជន/គម² | |
|---|---|---|---|---|
| | ២០០៨ | ២០១៩ | ២០០៨ | ២០១៩ |
| (១) | (២) | (៣) | (៥) | (៦) |
| **សរុប** | ១៨៥.៨១៩ | ២៧៦.០៣៨ | ៣០ | ៤៥ |
| អន្លង់វែង | ៣៩.០៤៥ | ៥៨.៣៨៩ | ៩៥ | ១៤២ |
| បន្ទាយអំពិល | ៤១.០០៥ | ៥៤.៧១៦ | ២៧ | ៣៦ |
| ចុងកាល់ | ២១.៧៤៩ | ២៧.៩១០ | ១៨ | ២៣ |
| ក្រុងសំរោង | ៥១.៤១៤ | ៧២.៨០៣ | ៥៣ | ៧៥ |
| ត្រពាំងប្រាសាទ | ៣២.៦០៦ | ៦២.២២០ | ២៣ | ៤៤ |

**សម្គាល់ ៖** តួលេខនេះមិនរាប់បញ្ចូលពលករចំណាកស្រុកទៅក្រៅប្រទេស

## ២.៥. ការបែងចែកប្រជាជនតាមសាសនា

នៅខេត្តឧត្តរមានជ័យប្រមាណ ៩៩,៥ ភាគរយ កាន់ព្រះពុទ្ធសាសនា។ ក្រុមសាសនាដែលធំជាងគេបន្ទាប់ គឺអ្នកកាន់សាសនាឥស្លាមមានប្រមាណជា ០,២ ភាគរយ។ សាសនាគ្រឹស្ទ និងសាសនាផ្សេងទៀតមាន ០,៣ ភាគរយ។ អ្នកកាន់សាសនាគ្រឹសាសនាផ្សេងទៀតមានតិចក្នុងចំណោមប្រជាជនសរុបខេត្តឧត្តរមានជ័យ ។ ទម្រង់នៃការបែងចែកប្រជាជនតាមសាសនា មានច្រើន ឬតិចនៅឆ្នាំ ២០០៨ និងឆ្នាំ២០១៩។

**តារាង ២.៥.១. ការបែងចែកភាគរយប្រជាជនតាមសាសនា ខេត្តឧត្តរមានជ័យ ២០០៨-២០១៩**

| រាជធានី/ខេត្ត | ឆ្នាំ ២០០៨ | | | | ឆ្នាំ ២០១៩ | | | |
|---|---|---|---|---|---|---|---|---|
| | ព្រះពុទ្ធ | ឥស្លាម | គ្រឹស្ទ | សាសនាផ្សេង | ព្រះពុទ្ធ | ឥស្លាម | គ្រឹស្ទ | សាសនាផ្សេង |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨ | (៨) |
| **សរុប** | ៩៩,៨ | ០,១ | ០,១ | ០,០ | ៩៩,៥ | ០,២ | ០,៣ | ០,០ |
| **ទីប្រជុំជន** | ៩៩,៩ | ០,០ | ០,០ | ០,០ | ៩៩,៥ | ០,២ | ០,៤ | ០,០ |
| **ជនបទ** | ៩៩,៨ | ០,១ | ០,១ | ០,០ | ៩៩,៦ | ០,២ | ០,២ | ០,០ |

**សម្គាល់ ៖** តួលេខនេះមិនរាប់បញ្ចូលពលករចំណាកស្រុកទៅក្រៅប្រទេស

## ២.៦. ការបែងចែកប្រជាជនតាមភាសាកំណើត

នៅក្នុងជំរឿន គ្រប់សមាជិកទាំងអស់នៅក្នុងគ្រួសារត្រូវបានសាកសួរ ដើម្បីឆ្លើយប្រាប់អំពីភាសាកំណើតរបស់ខ្លួន។ ព័ត៌មានបានបង្ហាញក្នុងតារាង ២.៦.១ បានឲ្យដឹងថា ភាសាខ្មែរគឺជាភាសាកំណើតច្រើនលើសលុបនៅក្នុងខេត្ត

ឧត្តរមានជ័យ (៩៩,២ ភាគរយ) ឆ្នាំ២០១៩។ អ្នកនិយាយភាសាកំណើតជនជាតិដើមភាគតិចមាន ០,៤ ភាគរយ។ អ្នកដែលមានភាសាបរទេសជាភាសាកំណើត រួមមាន ០,៤ ភាគរយ។

## តារាង ២.៦.១. ការបែងចែកភាគរយនៃប្រជាជន តាមភាសាកំណើត ភេទ ខេត្តឧត្តរមានជ័យ ឆ្នាំ២០១៩

| ភាសាកំណើត | ២០០៨ | | | ២០១៩ | | |
|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) |
| **សរុប** | ១០០,០ | ១០០,០ | ១០០,០ | ១០០,០០ | ១០០,០០ | ១០០,០០ |
| ខ្មែរ | ៩៩,៧ | ៩៩,៧ | ៩៩,៧ | ៩៩,២ | ៩៩,២ | ៩៩,៣ |
| *វៀតណាម* | ០,០ | ០,០ | ០,០ | ០,១ | ០,១ | ០,១ |
| *ចិន* | ០,១ | ០,១ | ០,០ | ០,១ | ០,២ | ០,១ |
| *ឡាវ* | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ |
| *ថៃ* | ០,០ | ០,០ | ០,០ | ០,១ | ០,១ | ០,១ |
| ភាសាផ្សេងទៀត | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ |
| ភាសាជនជាតិភាគតិច | ០,២ | ០,២ | ០,២ | ០,៤ | ០,៤ | ០,៤ |

**សម្គាល់ ៖** តួលេខនេះមិនរាប់បញ្ចូលពលករចំណាកស្រុកទៅក្រៅប្រទេស

# ជំពូក ៣
# សមាសភាពភេទ ការបែងចែកក្រុមអាយុ និង ស្ថានភាពអាពាហ៍ពិពាហ៍

## ៣.១. ទស្សនទាន

ដោយយោងតាមនិយមន័យរបស់អង្គការសហប្រជាជាតិ អាយុរបស់មនុស្សដែលបានកត់ត្រាក្នុងជំរឿន គឺតាម "ចន្លោះឃ្លាតនៃកាលបរិច្ឆេទកំណើត និងកាលបរិច្ឆេទនៃជំរឿនគិតជាឆ្នាំសុរិយគតិពេញលេញ"។ ក្នុងនោះក៏បានចែងថា ព័ត៌មានអំពីអាយុអាចគិតតាមកាលបរិច្ឆេទកំណើត (ថ្ងៃ ខែ ឆ្នាំកំណើត) ឬសួរដោយផ្ទាល់អំពីអាយុនៅខួបកំណើតចុងក្រោយ។

អនុសាសន៍ទាំងនេះ ត្រូវបានអនុវត្តក្នុងការប្រមូលទិន្នន័យនៃអាយុនៅក្នុងជំរឿនមុនៗ និងអង្កេតបច្ចុប្បន្ននៅប្រទេសខេត្តឧត្តរមានជ័យ។ ព័ត៌មានអាយុគិតជាឆ្នាំពេញដោយផ្អែកលើខួបកំណើតចុងក្រោយដែលបានទទួលពីអ្នកឆ្លើយ។ ដូច្នេះវាមានការងាយស្រួលក្នុងការសួរពីព័ត៌មានអាយុនេះ ប៉ុន្តែពេលខ្លះពិបាកក្នុងការប្រមូលទិន្នន័យបានត្រឹមត្រូវអំពីអាយុ ចំពោះអ្នកមិនចេះអក្សរ ឬចាស់ជរា។ ជំហានដសមស្របមួយសម្រាប់ប្រមូលទិន្នន័យអំពីអាយុឲ្យមានភាពសុក្រិតនឹងអាចធ្វើទៅបានចំពោះអ្នកឆ្លើយ។ ប្រតិទិនខ្មែរត្រូវបានយកមកប្រើប្រាស់ដោយមន្ត្រីសម្ភាសន៍ ដើម្បីសួរឲ្យបាននូវអាយុពេញលេញពីអ្នកឆ្លើយ ចំពោះអ្នកដែលមិនអាចប្រាប់អាយុរបស់ពួកគេបាន។ មន្ត្រីសម្ភាសន៍ត្រូវបានផ្ដល់ឲ្យនូវតារាងព្រឹត្តិការណ៍ជាតិ និងអន្តរជាតិសំខាន់ៗក៏ត្រូវបានប្រើប្រាស់ ដើម្បីជួយឲ្យអ្នកឆ្លើយនឹកឃើញពីអាយុរបស់ពួកគាត់ឡើង វិញ។

## ៣.២. រចនាសម្ព័ន្ធអាយុ

រចនាសម្ព័ន្ធអាយុត្រូវបានកំណត់ដោយកត្តា ៣ ដែលធ្វើឲ្យប៉ះពាល់អត្រាកំណើនប្រជាជន ដូចជាលទ្ធភាពបង្កើតកូន មរណភាព និងការផ្លាស់ប្តូរលំនៅដ្ឋាន។ ការសិក្សារចនាសម្ព័ន្ធប្រជាជនតាមការបែងចែកភាគរយប្រជាជនតាមក្រុមអាយុ និងការបង្ហាញតាមក្រាហ្វិកពីរ៉ាមីតអាយុ គឺជាការសង្ខេបខ្លីនៃប្រវត្តិប្រជាសាស្ត្ររបស់ប្រជាជន។

តារាង ៣.៣.១. ការបែងចែកតាមក្រុមអាយុរាយ តាមភេទ តំបន់ ខេត្តឧត្តរមានជ័យ ឆ្នាំ២០១៩

| អាយុ | សរុប | | | ទីប្រជុំជន | | | ជនបទ | | |
|---|---|---|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) | (៩) | (១០) |
| សរុប | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ |
| ០ | ១,៩ | ១,៩ | ១,៨ | ២,០ | ២,០ | ១,៩ | ១,៨ | ១,៨ | ១,៨ |
| ១ | ១,៩ | ១,៩ | ២,០ | ១,៨ | ១,៩ | ១,៨ | ២,០ | ២,០ | ២,០ |
| ២ | ២,៣ | ២,៣ | ២,៣ | ២,១ | ២,០ | ២,២ | ២,៣ | ២,៤ | ២,៣ |
| ៣ | ២,៤ | ២,៤ | ២,៣ | ២,២ | ២,២ | ២,២ | ២,៤ | ២,៥ | ២,៣ |
| ៤ | ២,៤ | ២,៤ | ២,៣ | ២,៣ | ២,៣ | ២,៣ | ២,៤ | ២,៤ | ២,៣ |

| អាយុ | សរុប | | | ទីប្រជុំជន | | | ជនបទ | | |
|---|---|---|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) | (៩) | (១០) |
| ៥ | ២,៣ | ២,៤ | ២,៣ | ២,៣ | ២,២ | ២,៣ | ២,៤ | ២,៥ | ២,៣ |
| ៦ | ២,៤ | ២,៥ | ២,៣ | ២,៤ | ២,៥ | ២,២ | ២,៤ | ២,៤ | ២,៣ |
| ៧ | ២,២ | ២,៣ | ២,១ | ២,២ | ២,៤ | ២,១ | ២,២ | ២,៣ | ២,១ |
| ៨ | ២,១ | ២,១ | ២,១ | ១,៩ | ១,៩ | ១,៩ | ២,១ | ២,១ | ២,១ |
| ៩ | ២,១ | ២,១ | ២,១ | ២,២ | ២,២ | ២,២ | ២,១ | ២,១ | ២,១ |
| ១០ | ២,៥ | ២,៦ | ២,៤ | ២,៦ | ២,៧ | ២,៥ | ២,៥ | ២,៥ | ២,៤ |
| ១១ | ២,៤ | ២,៤ | ២,៣ | ២,៤ | ២,៤ | ២,៤ | ២,៣ | ២,៤ | ២,៣ |
| ១២ | ២,៥ | ២,៥ | ២,៦ | ២,៦ | ២,៦ | ២,៧ | ២,៥ | ២,៥ | ២,៥ |
| ១៣ | ២,៣ | ២,៤ | ២,៣ | ២,៤ | ២,៤ | ២,៣ | ២,៣ | ២,៣ | ២,៣ |
| ១៤ | ២,១ | ២,១ | ២,១ | ២,១ | ២,០ | ២,១ | ២,១ | ២,២ | ២,១ |
| ១៥ | ២,២ | ២,៣ | ២,១ | ២,២ | ២,៣ | ២,២ | ២,២ | ២,២ | ២,១ |
| ១៦ | ១,៨ | ១,៨ | ១,៨ | ១,៨ | ១,៨ | ១,៨ | ១,៨ | ១,៨ | ១,៨ |
| ១៧ | ១,៩ | ១,៩ | ១,៩ | ១,៩ | ១,៩ | ១,៩ | ១,៩ | ១,៩ | ១,៩ |
| ១៨ | ២,០ | ២,០ | ២,០ | ២,១ | ២,១ | ២,១ | ១,៩ | ១,៩ | ២,០ |
| ១៩ | ១,៩ | ១,៩ | ២,០ | ២,០ | ២,០ | ២,០ | ១,៩ | ១,៩ | ១,៩ |
| ២០ | ១,៧ | ១,៧ | ១,៧ | ១,៧ | ១,៨ | ១,៧ | ១,៧ | ១,៧ | ១,៧ |
| ២១ | ១,៦ | ១,៦ | ១,៥ | ១,៧ | ១,៧ | ១,៦ | ១,៥ | ១,៥ | ១,៥ |
| ២២ | ១,៥ | ១,៥ | ១,៥ | ១,៦ | ១,៥ | ១,៦ | ១,៥ | ១,៥ | ១,៥ |
| ២៣ | ១,៧ | ១,៨ | ១,៦ | ១,៧ | ១,៧ | ១,៧ | ១,៧ | ១,៨ | ១,៦ |
| ២៤ | ១,៦ | ១,៦ | ១,៦ | ១,៦ | ១,៦ | ១,៦ | ១,៦ | ១,៦ | ១,៦ |
| ២៥ | ១,៩ | ២,០ | ១,៩ | ១,៩ | ១,៩ | ១,៩ | ១,៩ | ២,០ | ១,៩ |
| ២៦ | ១,៨ | ១,៨ | ១,៨ | ១,៨ | ១,៨ | ១,៨ | ១,៨ | ១,៨ | ១,៨ |
| ២៧ | ១,៨ | ១,៨ | ១,៨ | ១,៧ | ១,៨ | ១,៧ | ១,៨ | ១,៨ | ១,៨ |
| ២៨ | ១,៧ | ១,៧ | ១,៧ | ១,៧ | ១,៨ | ១,៧ | ១,៧ | ១,៧ | ១,៧ |
| ២៩ | ១,៧ | ១,៧ | ១,៧ | ១,៦ | ១,៦ | ១,៦ | ១,៧ | ១,៧ | ១,៨ |
| ៣០ | ១,៨ | ១,៨ | ១,៨ | ១,៨ | ១,៨ | ១,៨ | ១,៨ | ១,៨ | ១,៨ |
| ៣១ | ១,៨ | ១,៨ | ១,៧ | ១,៧ | ១,៨ | ១,៧ | ១,៨ | ១,៨ | ១,៨ |
| ៣២ | ១,៧ | ១,៧ | ១,៧ | ១,៦ | ១,៦ | ១,៧ | ១,៧ | ១,៧ | ១,៧ |
| ៣៣ | ១,៦ | ១,៦ | ១,៦ | ១,៦ | ១,៧ | ១,៥ | ១,៦ | ១,៦ | ១,៦ |
| ៣៤ | ១,៤ | ១,៥ | ១,៤ | ១,៤ | ១,៤ | ១,៥ | ១,៥ | ១,៥ | ១,៤ |
| ៣៥ | ១,៧ | ១,៧ | ១,៧ | ១,៧ | ១,៧ | ១,៧ | ១,៧ | ១,៦ | ១,៧ |
| ៣៦ | ១,៤ | ១,៥ | ១,៤ | ១,៤ | ១,៤ | ១,៥ | ១,៥ | ១,៥ | ១,៤ |
| ៣៧ | ១,៥ | ១,៥ | ១,៥ | ១,៥ | ១,៥ | ១,៦ | ១,៥ | ១,៥ | ១,៤ |
| ៣៨ | ១,៦ | ១,៥ | ១,៦ | ១,៥ | ១,៥ | ១,៥ | ១,៦ | ១,៦ | ១,៦ |
| ៣៩ | ១,៥ | ១,៦ | ១,៤ | ១,៦ | ១,៨ | ១,៤ | ១,៥ | ១,៦ | ១,៤ |
| ៤០ | ១,៣ | ១,៤ | ១,៣ | ១,៤ | ១,៤ | ១,៣ | ១,៣ | ១,៤ | ១,៣ |
| ៤១ | ០,៩ | ០,៩ | ០,៨ | ០,៨ | ០,៩ | ០,៨ | ០,៩ | ០,៩ | ០,៨ |
| ៤២ | ០,៨ | ០,៨ | ០,៨ | ០,៨ | ០,៨ | ០,៨ | ០,៨ | ០,៨ | ០,៨ |
| ៤៣ | ០,៧ | ០,៧ | ០,៧ | ០,៧ | ០,៧ | ០,៦ | ០,៧ | ០,៧ | ០,៧ |
| ៤៤ | ០,៧ | ០,៧ | ០,៨ | ០,៨ | ០,៧ | ០,៨ | ០,៧ | ០,៧ | ០,៧ |
| ៤៥ | ០,៨ | ០,៨ | ០,៩ | ០,៩ | ០,៩ | ០,៩ | ០,៨ | ០,៨ | ០,៨ |
| ៤៦ | ០,៨ | ០,៨ | ០,៨ | ០,៨ | ០,៨ | ០,៨ | ០,៨ | ០,៨ | ០,៨ |
| ៤៧ | ០,៩ | ០,៩ | ១,០ | ១,០ | ១,០ | ១,០ | ០,៩ | ០,៩ | ០,៩ |
| ៤៨ | ១,០ | ១,០ | ១,០ | ១,០ | ១,០ | ១,១ | ១,០ | ០,៩ | ១,០ |

| អាយុ | សរុប | | | ទីប្រជុំជន | | | ជនបទ | | |
|---|---|---|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) | (៩) | (១០) |
| ៤៩ | ១,០ | ១,១ | ១,០ | ១,១ | ១,១ | ១,០ | ១,០ | ១,០ | ១,០ |
| ៥០ | ១,០ | ០,៩ | ១,១ | ១,០ | ០,៩ | ១,១ | ១,០ | ០,៩ | ១,១ |
| ៥១ | ០,៨ | ០,៨ | ០,៨ | ០,៩ | ០,៩ | ០,៨ | ០,៨ | ០,៨ | ០,៨ |
| ៥២ | ០,៨ | ០,៨ | ០,៩ | ០,៩ | ០,៩ | ០,៩ | ០,៨ | ០,៨ | ០,៩ |
| ៥៣ | ០,៩ | ០,៨ | ១,០ | ០,៩ | ០,៨ | ០,៩ | ០,៩ | ០,៨ | ១,០ |
| ៥៤ | ០,៨ | ០,៨ | ០,៨ | ០,៨ | ០,៨ | ០,៩ | ០,៨ | ០,៨ | ០,៨ |
| ៥៥ | ១,០ | ០,៩ | ១,០ | ១,០ | ០,៩ | ១,០ | ១,០ | ០,៩ | ១,១ |
| ៥៦ | ០,៩ | ០,៩ | ០,៩ | ០,៩ | ១,០ | ០,៩ | ០,៩ | ០,៨ | ០,៩ |
| ៥៧ | ០,៨ | ០,៨ | ០,៨ | ០,៧ | ០,៨ | ០,៧ | ០,៨ | ០,៨ | ០,៩ |
| ៥៨ | ០,៨ | ០,៧ | ០,៨ | ០,៨ | ០,៨ | ០,៧ | ០,៨ | ០,៧ | ០,៩ |
| ៥៩ | ០,៧ | ០,៧ | ០,៨ | ០,៨ | ០,៧ | ០,៨ | ០,៧ | ០,៧ | ០,៧ |
| ៦០ | ០,៧ | ០,៦ | ០,៧ | ០,៦ | ០,៦ | ០,៦ | ០,៧ | ០,៦ | ០,៨ |
| ៦១ | ០,៦ | ០,៥ | ០,៦ | ០,៥ | ០,៥ | ០,៥ | ០,៦ | ០,៥ | ០,៦ |
| ៦២ | ០,៥ | ០,៥ | ០,៥ | ០,៥ | ០,៤ | ០,៥ | ០,៥ | ០,៥ | ០,៥ |
| ៦៣ | ០,៥ | ០,៥ | ០,៦ | ០,៥ | ០,៥ | ០,៦ | ០,៥ | ០,៥ | ០,៦ |
| ៦៤ | ០,៤ | ០,៤ | ០,៥ | ០,៤ | ០,៤ | ០,៥ | ០,៤ | ០,៤ | ០,៤ |
| ៦៥ | ០,៥ | ០,៤ | ០,៥ | ០,៤ | ០,៥ | ០,៤ | ០,៥ | ០,៤ | ០,៥ |
| ៦៦ | ០,៣ | ០,៣ | ០,៣ | ០,៣ | ០,៣ | ០,៣ | ០,៤ | ០,៣ | ០,៤ |
| ៦៧ | ០,៣ | ០,៣ | ០,៣ | ០,៣ | ០,៣ | ០,៤ | ០,៣ | ០,៣ | ០,៣ |
| ៦៨ | ០,៣ | ០,២ | ០,៣ | ០,៣ | ០,៣ | ០,៣ | ០,៣ | ០,២ | ០,៣ |
| ៦៩ | ០,២ | ០,២ | ០,២ | ០,២ | ០,២ | ០,២ | ០,២ | ០,២ | ០,២ |
| ៧០ | ០,២ | ០,២ | ០,២ | ០,២ | ០,២ | ០,២ | ០,២ | ០,២ | ០,២ |
| ៧១ | ០,២ | ០,១ | ០,២ | ០,២ | ០,២ | ០,២ | ០,២ | ០,១ | ០,២ |
| ៧២ | ០,២ | ០,១ | ០,២ | ០,២ | ០,២ | ០,២ | ០,២ | ០,១ | ០,២ |
| ៧៣ | ០,១ | ០,១ | ០,២ | ០,១ | ០,១ | ០,១ | ០,១ | ០,១ | ០,២ |
| ៧៤ | ០,១ | ០,១ | ០,១ | ០,១ | ០,១ | ០,១ | ០,១ | ០,១ | ០,២ |
| **៧៥+** | ០,៩ | ០,៧ | ១,១ | ០,៨ | ០,៦ | ១,១ | ០,៩ | ០,៧ | ១,១ |

រចនាសម្ព័ន្ធអាយុរបស់ប្រជាជនខេត្តឧត្ដរមានជ័យវ័យក្មេងនៅឡើយដែលប្រជាជនអាយុក្រោម ១៥ ឆ្នាំ មានរហូតដល់ ៣៣,៧ ភាគរយ និងអាយុ ៦០ ឆ្នាំឡើង មានប្រមាណ ៥,៩ ភាគរយ។ តារាងបង្ហាញអំពីមេដ្យានអាយុ ២៣ ឆ្នាំ នៅឆ្នាំ២០១៩ (តារាង ៣.៣.២)។ មេដ្យានអាយុនៃជំរឿនឆ្នាំ២០០៨ មានតែ ១៩ ឆ្នាំ ដូច្នេះមេដ្យានអាយុប្រជាជនមានអាយុកើនឡើង ៤ ឆ្នាំ ក្នុងរយៈពេល ១១ ឆ្នាំ។ នេះជាលទ្ធផលនៃការថយចុះតិត្តចអត្រានៃប្រជាជនអាយុ ០-១៤ ឆ្នាំ ចន្លោះឆ្នាំ២០០៨ និង ២០១៩ (ដោយសារការធ្លាក់ចុះចំនួនមធ្យមនៃកំណើតក្នុងស្ត្រីម្នាក់) ហើយជាមួយគ្នានេះដែរ ការកើនឡើងនៃអត្រាប្រជាជនអាយុ ១៥-៥៩ ឆ្នាំ។

ការបែងចែកតាមតំបន់ទីប្រជុំជន ជនបទ ក្រុមអាយុក្នុងកំលាំងពលកម្មនៅតំបន់ទីប្រជុំជន មានច្រើនជាងជនបទ ចំណែកឯក្រុមអាយុវ័យក្មេង និងវ័យចាស់ មានភាគរយតិចជាងជនបទ។ ទម្រង់នេះបង្ហាញអំពីភាពខុសគ្នានៃការរួមបញ្ចូលគ្នានៃការធ្លាក់ចុះអត្រាលទ្ធភាពបង្កើតកូននៅតំបន់ទីប្រជុំជន និងជនបទ ជាពិសេសការធ្វើបម្លាស់ទីរបស់ប្រជាជន។

### តារាង ៣.៣.២. ការបែងចែកប្រជាជនតាមក្រុមអាយុ ផលធៀបក្នុងបន្ទុក មេដ្យានអាយុ និងផលធៀបភេទ ២០០៨-២០១៩

| ចរិតលក្ខណៈ | ២០០៨ | | | ២០១៩ | | |
|---|---|---|---|---|---|---|
| | សរុប | ទីប្រជុំជន | ជនបទ | សរុប | ទីប្រជុំជន | ជនបទ |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) |
| សរុប | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ |
| ០-១៤ | ៣៧,៦ | ៣៦,១ | ៣៧,៨ | ៣៣,៧ | ៣៣,៤ | ៣៣,៩ |
| ១៥-៥៩ | ៥៩,១ | ៦០,៤ | ៥៨,៩ | ៦០,៣ | ៦០,៩ | ៦០,១ |
| ៦០ + | ៣,៣ | ៣,៥ | ៣,៣ | ៥,៩ | ៥,៧ | ៦,០ |
| ផលធៀបក្នុងបន្ទុក | ៦៩,២ | ៦៥,៦ | ៦៩,៧ | ៦៥,៧ | ៦៤,៣ | ៦៦,៥ |
| មេដ្យានអាយុ | ១៩ | ២០ | ១៩ | ២៣ | ២៣ | ២៣ |
| ផលធៀបភេទ | ១០១,៦ | ១០២,៨ | ១០១,៥ | ១០២,០ | ១០០,២ | ១០២,៩ |

**សម្គាល់ ៖** តួលេខនេះមិនរាប់បញ្ចូលពលករចំណាកស្រុកទៅក្រៅប្រទេស

## ៣.៣.១. ផលធៀបអាយុនៅក្នុងបន្ទុក

វិធីសាស្ត្រសាមញ្ញពិពណ៌នាអំពីរចនាសម្ព័ន្ធអាយុប្រជាជនត្រូវបានគណនាដោយសន្ទស្សន៍ ហៅថាផលធៀបអាយុអ្នកនៅក្នុងបន្ទុក។ សន្ទស្សន៍នេះជាសមាមាត្រនៃប្រជាជនដែលពឹងអាស្រ័យលើផលិតភាពប្រជាជនដែលជាសកម្មជនសេដ្ឋកិច្ច។ ជាការសន្មត ចំនួនកុមារ (០-១៤ ឆ្នាំ) បូកនឹងចំនួនមនុស្សចាស់ (៦០ ឆ្នាំឡើង) ចែកនឹងចំនួនប្រជាជនអាយុស្ថិតក្នុងកម្លាំងពលកម្ម (១៥-៥៩ ឆ្នាំ) គុណនឹង ១០០។

ជាទូទៅអាយុផលធៀបអាយុក្នុងបន្ទុក (តារាង ៣.៣.២) បង្ហាញអំពីនិន្នាការធ្លាក់ចុះក្នុងអំឡុងឆ្នាំ២០០៨-២០១៩ នៃចំនួនអ្នកនៅក្នុងបន្ទុក។ ផលធៀបអាយុក្នុងបន្ទុករបស់ខេត្តឧត្តរមានជ័យនៅ ឆ្នាំ២០១៩ មាន ៦៥,៧ ។ មានន័យថាក្នុងចំណោមមនុស្ស ១០០នាក់ មានអាយុស្ថិតក្នុងកម្លាំងពលកម្មមាន ៦៦ នាក់ ជាប្រជាជនមានអាយុក្នុងបន្ទុកពឹងអាស្រ័យ។ ផលធៀបអាយុក្នុងបន្ទុកបានថយចុះពីជំរឿនឆ្នាំ២០០៨ ដែលមានអត្រា ៦៩ នាក់។ នៅ អត្រាអ្នកនៅក្នុងបន្ទុកនៅទីប្រជុំជនមាន ៦៤ នាក់ ក្នុងចំណោមក្រុមអាយុស្ថិតក្នុងកម្លាំងពលកម្ម ១០០នាក់។ អត្រាអ្នកនៅក្នុងបន្ទុកជាទូទៅ មានអត្រាខ្ពស់នៅតំបន់ជនបទ។

## ៣.៣.២. ពីរ៉ាមីតអាយុ

រូប ៣.៣.២.១ ៣.៣.២.២ និង ៣.៣.២.៣ បានបង្ហាញពីរ៉ាមីតអាយុប្រជាជន (សរុប ទីប្រជុំជន និងជនបទ ខេត្តឧត្តរមានជ័យ ឆ្នាំ២០០៨ និង ២០១៩) រួមនឹងភាគរយប្រុស និងស្រីតាមក្រុមអាយុ ៥ ឆ្នាំ ចាប់ផ្តើមពីក្រុមអាយុក្មេងបំផុតដែលស្ថិតនៅផ្នែកខាងក្រោម និងបន្តកំណើនអាយុទៅផ្នែកខាងលើនៃពីរ៉ាមីត។ ភាគរយនៃប្រុសបានបង្ហាញនៅខាងឆ្វេងដៃ និងភាគរយនៃស្រីបង្ហាញនៅខាងស្តាំដៃនៃពីរ៉ាមីត។ តំបន់ស្រមោលបង្ហាញពីតំណាងភាគរយប្រជាជននៃជំរឿនឆ្នាំ២០០៨ ខណៈដែលតំបន់គំនូសក្រាស់បង្ហាញពីការភាគរយប្រជាជនជំរឿនឆ្នាំ២០១៩។

ការប្រៀបធៀបពីរ៉ាមីតអាយុឆ្នាំ២០០៨ និង ២០១៩ តាមក្រុមអាយុនីមួយៗ បានបង្ហាញពីលក្ខណៈពិសេសនៃការបែងចែកអាយុ។ សមាមាត្រនៃក្រុមអាយុ ០-៤ ឆ្នាំ ទាបជាងក្រុមអាយុ ៥-៩ ឆ្នាំ ដែលជាលទ្ធផលនៃការកែលម្អស្ថានភាពសុខភាពរបស់ប្រទេស រួមជាមួយការធ្លាក់ចុះនៃលទ្ធភាពបង្កើតកូន និងមរណភាព ក្នុងអំឡុងពេលនេះ។

ពីរ៉ាមីតអាយុប្រជាជនឆ្នាំ២០១៩ បង្ហាញពីទម្រង់ទូទៅនៃការធ្លាក់ចុះនៃសមាមាត្រជាមួយការកើនឡើងនៃក្រុមអាយុ ។ ពីរ៉ាមីតបានបង្ហាញថា ក្រុមអាយុលើស ២៥ ឆ្នាំ មានសមាមាត្រកើនឡើងក្រុមអាយុទាំង ប្រុស ស្រី។ ពីរ៉ាមីតបានបង្ហាញពីការធ្លាក់ចុះនៃសមាមាត្រក្រុមក្រោមអាយុ ២៥ ឆ្នាំ ។

រូប ៣.៣.២.១. ពីរ៉ាមីតអាយុប្រជាជន ខេត្តឧត្តរមានជ័យ សរុប ឆ្នាំ២០០៨ និង ២០១៩




ពីរ៉ាមីតនៅទីប្រជុំជន ឆ្នាំ២០១៩ បង្ហាញពីការថយចុះនៃក្រុមអាយុយុវជនសម្រាប់ប្រុស ស្រី ក្នុងក្រោមក្រុមអាយុ ២០-២៤ ឆ្នាំ។ មូលហេតុចម្បងនៃនិន្នាការនេះ អាចមកពីការធ្វើចំណាកស្រុករបស់ក្រុមកម្មកររោងចក្រកាត់ដេរជាច្រើនពាន់នាក់នៅជនបទដែលភាគច្រើនជាក្មេងស្រី ។

រូប ៣.៣.២.២. ពីរ៉ាមីតអាយុប្រជាជន ខេត្តឧត្តរមានជ័យ ទីប្រជុំជន ២០០៨ និង ២០១៩




រូប ៣.៣.២.៣. ពីរ៉ាមីតអាយុប្រជាជន ខេត្តឧត្តរមានជ័យ ជនបទ ២០០៨ និង ២០១៩




តាមការសង្កេតបានឲ្យដឹងថា ភាពខុសគួរឲ្យកត់សម្គាល់រវាងពីរ៉ាមីតរចនាសម្ព័ន្ធអាយុនៅតំបន់ទីប្រជុំជន និង ជនបទ ដូចក្នុងរូប ៣.៣.២.៤។ តំបន់ជនបទមានក្រុមអាយុវ័យក្មេង និងជាពិសេសក្រុមអាយុវ័យចាស់ច្រើន។ និយាយដោយឡែក នៅទីប្រជុំជនមានប្រជាជនក្នុងក្រុមអាយុកម្លាំងពលកម្មជាសកម្មជនសេដ្ឋកិច្ចច្រើន (១៥-៥៩)។ និន្នាការ នេះអាចដោយសារបំលាស់ទីរបស់ប្រជាជនពីជនបទទៅទីប្រជុំជន ដើម្បីរកការងារធ្វើនៅទីប្រជុំជន។ ពីរ៉ាមីត នៅទីប្រជុំជនរីកកណ្តាលហើយមានលក្ខណៈរួមចង្អៀតនៅខាងចុង អាចបញ្ជាក់បានថាមានសមាមាត្រប្រជាជនក្នុង

ក្រុមអាយុកម្លាំងពលកម្មច្រើន និងមានក្រុមមនុស្សចាស់តិច។ ផ្ទុយមកវិញ ពីរ៉ាមីតនៅជនបទមានការរីកទូលាយនៅក្នុងក្រុមប្រជាជន វ័យក្មេង និងតូចចង្អៀតនៅក្បាលពីរ៉ាមីតមិនដូចនៅទីប្រជុំជនឡើយ។ នេះបង្ហាញយ៉ាងច្បាស់ថាតំបន់ជនបទមានប្រជាជនវ័យក្មេង និងប្រជាជនវ័យចាស់ច្រើន។ ទម្រង់នេះត្រូវបានកត់សម្គាល់នៅជំរឿនទាំងពីរ ឆ្នាំ ២០០៨ និង២០១៩។

រូប ៣.៣.២.៤. ពីរ៉ាមីតអាយុប្រជាជន ខេត្តឧត្តរមានជ័យ ទីប្រជុំជន ជនបទ ២០១៩




## ៣.៤. សមាសភាពភេទ

ផលធៀបភេទ ឬអត្រាភេទត្រូវកំណត់ដោយចំនួនប្រជាជនបុរសក្នុងចំណោមស្ត្រី ១០០។ បើផលធៀបភេទលើសពី ១០០ មានន័យថាចំនួនបុរសលើសចំនួនស្ត្រី ផ្ទុយមកវិញបើផលធៀបភេទតិចជាង ១០០ បញ្ជាក់ថាចំនួនស្ត្រីមានលើសចំនួនបុរស ដែលបង្ហាញអំពីចរិតលក្ខណៈសង្គមដ៏សំខាន់ក្នុងការរស់រវៃសមាមាត្រនៃសមធម៌ទូទៅរវាងបុរស និងស្ត្រីនៅក្នុងសង្គម និងមានឥទ្ធិពលដោយផ្ទាល់ទៅលើការស្វែងរកដៃគូអាពាហ៍ពិពាហ៍ ព្រមទាំងកម្មវិធីអភិវឌ្ឍន៍ ហើយក៏អាចប៉ះពាល់ខុសគ្នាទៅលើគុណភាពនៃជីវិតរបស់បុរស និងស្ត្រីផងដែរ។ សូចនាករនេះត្រូវបានប្រើសម្រាប់សិក្សាអំពីផលធៀបភេទរបស់ប្រជាជនខេត្តឧត្តរមានជ័យ (ផលធៀបភេទ)។

ព័ត៌មានមូលដ្ឋាននេះត្រូវបានប្រមូលតាមរយៈជំរឿនទាំងនៅឆ្នាំ១៩៩៨ និងឆ្នាំ២០០៨ ជំរឿននៅខេត្តឧត្តរមានជ័យត្រូវបានបញ្ចូលពត៌មានបុរស និងស្ត្រី ហើយបានផលិតសម្រាប់ប្រធានបទស្ទើរតែទាំងអស់។ នេះគឺជាតម្រូវការមូលដ្ឋានមួយនៅក្នុងការកសាងផែនការ ដែលអាចជួយកំណត់នូវផលប៉ះពាល់យេនឌ័រ ក្នុងសកម្មភាពអភិវឌ្ឍន៍ និងជួយឆ្លើយតបដមានប្រសិទ្ធភាពចំពោះបញ្ហាយេនឌ័រ។ លទ្ធផលចុងក្រោយនៃចំនួនប្រជាជននៅក្នុងជំរឿនទូទៅ

ប្រជាជននៅខេត្តឧត្តរមានជ័យឆ្នាំ២០១៩ មានប្រជាជនចំនួន ២៧៦.០៣៨ នាក់ ក្នុងនោះ ៥០,១ ភាគរយ ជាបុរស និង ៤៩,៩ ភាគរយជាស្ត្រី។

ជាទូទៅ ចំនួនកំណើតបុរស និងចំនួនកំណើតស្ត្រីមិនមានសមភាពទេក្នុងបណ្តាប្រទេសទាំងអស់។ ការសិក្សាអំពីការផ្តល់កំណើតកូនបានបង្ហាញថា ចំនួនកំណើតបុរសតែងតែច្រើនជាងចំនួនកំណើតរបស់ស្ត្រី។ ផលធៀបភេទពីកំណើតប្រែប្រួលក្នុងរង្វង់ ១០២ ទៅ ១១០ នៅប្រទេសភាគច្រើន (Haupt et al., 2011)។ ផលធៀបភេទនៅខេត្តឧត្តរមានជ័យដែលបានប៉ាន់ស្មាននៅពេលកើតប្រមាណ ១០៥។

ផលធៀបភេទ ឬអត្រាភេទនៅខេត្តឧត្តរមានជ័យមាន ១០២,០ យោងតាមលទ្ធផលចុងក្រោយជំរឿនទូទៅនៅខេត្តឧត្តរមានជ័យ ឆ្នាំ២០១៩។ ចំនួនស្ត្រីតិចជាងចំនួនបុរស ក្នុងចំណោមប្រជាជនខេត្តឧត្តរមានជ័យ។ នៅប្រទេសភាគច្រើនមានផលធៀបភេទស្ថិតក្នុងចន្លោះពី ៩៥ ទៅ ១០៥។ ផលធៀបភេទ ឬអត្រាភេទខេត្តឧត្តរមានជ័យ ហាក់ស្ថិតនៅស្ថេរតាំងពីឆ្នាំ២០០៨។

ផលធៀបភេទនៅខេត្តឧត្តរមានជ័យមានភាពខុសគ្នាពីស្រុកមួយទៅស្រុកមួយ (តារាង ៣.៤.១)។ នៅឆ្នាំ ២០១៩ មានតែស្រុកចុងកាល់ មានផលធៀបភេទទាបជាង ១០០ ។ ស្រុកដែលមានផលធៀបភេទទាបជាងគេគឺស្រុក អង្គរជ័យដោយសារបុរសពេញវ័យជាច្រើនទៅធ្វើការនៅរោងចក្រ ឬវិស័យសេដ្ឋកិច្ចផ្សេងៗ ឬផ្លាស់ប្តូរទៅកន្លែងផ្សេងនៅក្នុងប្រទេស ឬចំណាកស្រុកទៅប្រទេសជិតខាង។

**តារាង ៣.៤.១. ការបែងចែករបាយប្រជាជន តាមរាជធានី ខេត្ត ខេត្តឧត្តរមានជ័យ ឆ្នាំ២០០៨-២០១៩**

| រាជធានី ខេត្ត | ២០០៨ | | ២០១៩ | | ផលធៀបភេទ | |
|---|---|---|---|---|---|---|
| | ប្រុស | ស្រី | ប្រុស | ស្រី | ២០០៨ | ២០១៩ |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) |
| **សរុប** | ៩៣.៦៤៦ | ៩២.១៧៣ | ១៣៩.៣៧៨ | ១៣៦.៦៦០ | ១០១,៦ | ១០២,០ |
| **ទីប្រជុំជន** | ៩.៤៧៥ | ៩.២១៩ | ៤៥.៧០៣ | ៤៥.៥៩៥ | ១០២,៨ | ១០០,២ |
| **ជនបទ** | ៨៤.១៧១ | ៨២.៩៥៤ | ៩៣.៦៧៥ | ៩១.០៦៥ | ១០១,៥ | ១០២,៩ |
| អន្លង់វែង | ១៩.៩៨០ | ១៩.០៦៥ | ២៩.៨៩៩ | ២៨.៤៩០ | ១០៤,៨ | ១០៤,៩ |
| បន្ទាយអំពិល | ២០.៤៤៣ | ២០.៥៦២ | ២៧.៧៧៥ | ២៦.៩៤១ | ៩៩,៤ | ១០៣,១ |
| ចុងកាល់ | ១០.៣៥១ | ១១.៣៩៨ | ១៣.៦០៣ | ១៤.៣០៧ | ៩០,៨ | ៩៥,១ |
| ក្រុងសំរោង | ២៥.៨៨៥ | ២៥.៥២៩ | ៣៦.៤៥៧ | ៣៦.៣៤៦ | ១០១,៤ | ១០០,៣ |
| ត្រពាំងប្រាសាទ | ១៦.៩៨៧ | ១៥.៦១៩ | ៣១.៦៤៤ | ៣០.៥៧៦ | ១០៨,៨ | ១០៣,៥ |

**សម្គាល់ ៖** តួលេខនេះមិនរាប់បញ្ចូលពលករចំណាកស្រុកទៅក្រៅប្រទេស

ផលធៀបភេទខុសគ្នាតាមក្រុមអាយុ (តារាង ២.៤.២)។ ក្នុងឆ្នាំ២០០៨ និងឆ្នាំ២០១៩ ស្រីក្រុមអាយុ ៥៥ ឆ្នាំឡើង មានចំនួនច្រើន និងមានការកត់សម្គាល់នៃចំនួនប្រុសច្រើនជាងស្រីក្នុងក្រុមអាយុនេះ ។ តារាង ៣.៤.២ បង្ហាញចំនួនប្រជាជនស្រីច្រើនជាងប្រុសនៅខេត្តឧត្តរមានជ័យ លើកលែងតែក្រុមអាយុ ៥៥ ឆ្នាំឡើង ។

**តារាង ៣.៤.២. ការបែងចែកផលធៀបភេទ តាមក្រុមអាយុ ភេទ ឧត្តរមានជ័យ ឆ្នាំ២០០៨-២០១៩**

| ក្រុមអាយុ | ផលធៀបភេទ | |
|---|---|---|
| | ឆ្នាំ ២០០៨ | ឆ្នាំ ២០១៩ |
| (១) | (៣) | (៤) |
| **សរុប** | ១០១,៦ | ១០២,០ |
| ០ - ៤ | ១០៥,៣ | ១០៤,៣ |
| ៥ - ៩ | ១០៦,៨ | ១០៧,២ |
| ១០ - ១៤ | ១០៧,៣ | ១០៤,៩ |
| ១៥ - ១៩ | ១០២,៨ | ១០២,៦ |
| ២០ - ២៤ | ៩៦,៥ | ១០៥,១ |
| ២៥ - ២៩ | ១០៥,០ | ១០២,៤ |
| ៣០ - ៣៤ | ១០៤,៥ | ១០៣,៤ |
| ៣៥ - ៣៩ | ១០៦,៧ | ១០៥,៦ |
| ៤០ - ៤៤ | ៩៩,០ | ១០២,៩ |
| ៤៥ - ៤៩ | ៩៥,៣ | ១០០,៥ |
| ៥០ - ៥៤ | ៩២,០ | ៩៣,៥ |
| ៥៥ - ៥៩ | ៨៩,០ | ៩៤,៩ |
| ៦០ - ៦៤ | ៨៥,២ | ៨៨,០ |
| ៦៥ - ៦៩ | ៧៦,០ | ៩១,៧ |
| ៧០ - ៧៤ | ៦៣,៩ | ៧៩,៩ |
| ៧៥ + | ៥៩,០ | ៦៦,៣ |

**សម្គាល់ ៖** តួលេខនេះមិនរាប់បញ្ចូលពលករចំណាកស្រុកទៅក្រៅប្រទេស

## ៣.៥. ស្ថានភាពអាពាហ៍ពិពាហ៍ និងអាយុមធ្យមរៀបការលើកដំបូង

### ៣.៥.១. ស្ថានភាពអាពាហ៍ពិពាហ៍

ស្ថានភាពអាពាហ៍ពិពាហ៍គឺជាកត្តាសំខាន់នៅក្នុងសក្តានុពលរបស់ប្រជាជន ដោយសារវាមានឥទ្ធិពលដល់លទ្ធភាពបង្កើតកូន មរណភាព និងការផ្លាស់ប្តូរលំនៅដ្ឋាន។ តារាង ៣.៥.១ ខាងក្រោមបង្ហាញពីការបែងចែកប្រជាជនប្រុស និងស្រីដែលមានអាយុចាប់ពី ១៥ ឆ្នាំឡើង តាមប្រភេទនៃស្ថានភាពអាពាហ៍ពិពាហ៍។ សំណួរស្តីពីស្ថានភាពអាពាហ៍ពិពាហ៍នៅក្នុងជំរឿនឆ្នាំ២០១៩ ត្រូវបានបែងចែកជាក្រុមដូចជា៖ មិនដែលរៀបការ បច្ចុប្បន្នរៀបការ មេម៉ាយ/ពោះម៉ាយ លែងលះ និងទំនាស់រស់នៅផ្សេងគ្នា។ មនុស្សម្នាក់ត្រូវបានគេចាត់ទុកថាបច្ចុប្បន្នរៀបការ ប្រសិនបើតាមច្បាប់ ឬទំនៀមទម្លាប់ និងទំនៀមទម្លាប់ក្នុងស្រុកគាត់ ត្រូវបានគេទទួលស្គាល់ថាបានរៀបការ ឬរស់នៅជាមួយអ្នកដែលមានភេទផ្ទុយគ្នាជាប្តី និងប្រពន្ធ។

ជំរឿនឆ្នាំ២០១៩ បច្ចុប្បន្នរៀបការមានសមាមាត្រខ្ពស់ជាងគេប្រមាណ ៧០,៧ ភាគរយនៃចំនួនប្រជាជនអាយុចាប់ពី ១៥ ឆ្នាំឡើង។ ប្រជាជនមិនដែលរៀបការមាន ២៤,៧ ភាគរយនៃប្រជាជនអាយុចាប់ពី ១៥ ឆ្នាំឡើង។

សមាមាត្រស្ត្រីមេម៉ាយមានប្រមាណ ៤,៦ ភាគរយ។ ទោះជាយ៉ាងណាក៏ដោយ ស្ត្រីមេម៉ាយ លែងលះគ្នា និងទំនាស់រស់នៅផ្សេងគ្នាមានចំនួនច្រើនជាងបុរស។ ជាលទ្ធផលបុរសមានអត្រាស្លាប់ខ្ពស់ជាងស្ត្រី។ លើសពីនេះទៀតបានបញ្ជាក់ថាបុរសមានទំនោរក្នុងការរៀបការម្តងទៀតច្រើនជាងស្ត្រី ដោយសារកេណីមួយចំនួនដូចជាបុរសពឹងផ្អែកលើស្ត្រីចំពោះការទទួលខុសត្រូវក្នុងគ្រួសារ ហើយបាតុភូតនេះស្ទើរតែមានគ្រប់ប្រទេសទាំងអស់នៅលើពិភពលោក។

### តារាង ៣.៥.១. ប្រជាជនអាយុ ១៥ ឆ្នាំឡើង តាមស្ថានភាពអាពាហ៍ពិពាហ៍ ភេទ និងតំបន់ ខេត្តឧត្តរមានជ័យ ឆ្នាំ២០០៨- ២០១៩

| ស្ថានភាពអាពាហ៍ពិពាហ៍ | ឆ្នាំ | | | | | |
|---|---|---|---|---|---|---|
| | ២០០៨ | | | ២០១៩ | | |
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) |
| **សរុប** | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ |
| មិនដែលរៀបការ | ២៩,៧ | ៣៣,៨ | ២៥,៦ | ២៤,៧ | ២៩,០ | ២០,៤ |
| បានរៀបការហើយ | ៦៥,៤ | ៦៤,៧ | ៦៦,១ | ៧០,៧ | ៦៨,៩ | ៧២,៥ |
| មេម៉ាយ/ពោះម៉ាយ | ៣,៣ | ០,៨ | ៥,៨ | ២,៨ | ១,០ | ៤,៦ |
| លែងលះ | ១,៦ | ០,៧ | ២,៤ | ១,៧ | ១,០ | ២,៣ |
| ទំនាស់រស់នៅផ្សេងគ្នា | ០,១ | ០,០ | ០,១ | ០,១ | ០,១ | ០,១ |
| **ទីប្រជុំជន** | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ |
| មិនដែលរៀបការ | ៣២,៥ | ៣៦,៩ | ២៨,០ | ២៦,៧ | ៣១,០ | ២២,៤ |
| បានរៀបការហើយ | ៦១,៩ | ៦១,៤ | ៦២,៤ | ៦៨,៨ | ៦៦,៩ | ៧០,៦ |
| មេម៉ាយ/ពោះម៉ាយ | ៣,៤ | ០,៨ | ៦,១ | ២,៧ | ១,០ | ៤,៣ |
| លែងលះ | ២,១ | ០,៩ | ៣,៣ | ១,៨ | ១,០ | ២,៥ |
| ទំនាស់រស់នៅផ្សេងគ្នា | ០,១ | ០,០ | ០,១ | ០,១ | ០,១ | ០,១ |
| **ជនបទ** | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ |
| មិនដែលរៀបការ | ២៩,៣ | ៣៣,៤ | ២៥,៣ | ២៣,៧ | ២៨,០ | ១៩,៤ |
| បានរៀបការហើយ | ៦៥,៨ | ៦៥,០ | ៦៦,៥ | ៧១,៦ | ៦៩,៩ | ៧៣,៤ |
| មេម៉ាយ/ពោះម៉ាយ | ៣,៣ | ០,៨ | ៥,៨ | ២,៩ | ១,០ | ៤,៨ |
| លែងលះ | ១,៥ | ០,៧ | ២,៣ | ១,៦ | ១,០ | ២,២ |
| ទំនាស់រស់នៅផ្សេងគ្នា | ០,១ | ០,០ | ០,១ | ០,១ | ០,១ | ០,២ |

***សម្គាល់៖*** *គណនាដោយមិនរាប់បញ្ចូលស្ថានភាពអាពាហ៍ពិពាហ៍ដែលមិនបានរាយការណ៍*

## ៣.៥.២. អាយុរៀបការលើកដំបូង

សំណួរដោយផ្ទាល់ពីអាយុរៀបការលើកដំបូងត្រូវបានស្រង់នៅក្នុងជំរឿន២០១៩ ផងដែរប៉ុន្តែសំណួរលើកឡើងវិញពីអាពាហ៍ពិពាហ៍មានការខុសគ្នាខ្លាំងធៀបនឹងការគណនាដោយប្រយោល ដូច្នេះអាយុរៀបការមធ្យមត្រូវបានប៉ាន់ស្មានដោយវិធីសាស្ត្រប្រយោលពីទិន្នន័យស្ថានភាពអាពាហ៍ពិពាហ៍តាមអាយុ។ អាយុមធ្យមរៀបការលើកទីមួយ SMAM (Hajnal ឆ្នាំ១៩៥៣ ) គឺជាការប៉ាន់ស្មានអាយុមធ្យមដែលបានរស់នៅក្នុងក្រុមរបស់ស្ត្រី ឬបុរសមុនពេលពួកគេរៀបការជាលើកដំបូង។

អាយុរៀបការដំបូង (SMAM) ត្រូវបានទាញយកពីសមាមាត្ររបស់ប្រជាជនមិនទាន់រៀបការក្នុងក្រុមអាយុនីមួយៗបន្តគ្នា។ ការសន្មតទាក់ទងនឹងការគណនានេះ គឺការប្តូរក្នុងសមាមាត្រមិនទាន់រៀបការពីអាយុ X ទៅ X+1 ជារង្វាស់សមាមាត្រកំណើតក្នុងក្រុមបានរៀបការនៅអាយុ X ។ វិធីសាស្ត្រនេះអាចគណនាអាយុរៀបការជាមធ្យមរបស់ប្រជាជន (បុរស ឬស្ត្រី) អាយុ ១៥ ឆ្នាំឡើង មុនពេលពួកគេដល់អាយុ ៥០ ឆ្នាំ។ បន្ថែមពីនេះទៀត វាក៏បានផ្តល់ការប៉ាន់ស្មានអាយុមធ្យមរបស់ប្រជាជនមិនដែលបានរៀបការ បានរៀបការមុនអាយុ ៥០ ឆ្នាំផងដែរ។

ទោះជាយ៉ាងណាក៏ដោយអាយុមធ្យមរៀបការលើកទីមួយនៅខេត្តឧត្តរមានជ័យ SMAM បានគណនាឃើញ ២៥ សម្រាប់បុរស និង ២២ សម្រាប់ស្ត្រី ដោយផ្អែកលើការបែងចែកអាយុក្នុងជំរឿនឆ្នាំ២០១៩ របស់ប្រជាជនមិនដែលរៀបការនៅខេត្តឧត្តរមានជ័យ។ អាយុមធ្យមរៀបការលើកទីមួយ តាម SMAM បុរសខ្ពស់ជាងស្ត្រី។ សមាមាត្រស្ត្រីរៀបការនៅវ័យក្មេងខ្ពស់ជាងបើប្រៀបធៀបនឹងបុរសក្នុងក្រុមអាយុដូចគ្នា ដែលបង្ហាញជាទូទៅស្ត្រីរៀបការនៅវ័យក្មេងជាងបុរស (តារាង ៣.៥.២)។ បើប្រៀបធៀបនឹងឆ្នាំ២០០៨ អាយុជាមធ្យមនៃអាពាហ៍ពិពាហ៍មានការប្រែប្រួលតិចតួច ។

ភាពខុសគ្នាទីប្រជុំជន និងជនបទ បានសង្កេតឃើញក្នុង SMAM។ សម្រាប់ទាំងបុរស និងស្ត្រី SMAM នៅតំបន់ទីប្រជុំជនខ្ពស់ជាងនៅតំបន់ជនបទ។ នៅឆ្នាំ២០១៩ SMAM ក្នុងចំណោមបុរសនៅទីប្រជុំជនមានអត្រាខ្ពស់ជាងបុរសនៅជនបទ ១,០ ឆ្នាំ។ ភាពខុសគ្នានេះ ក្នុងចំណោមស្ត្រីនៅទីប្រជុំជន និងស្ត្រីនៅជនបទមាន ១,០ ឆ្នាំ។ បុរសនៅទីប្រជុំជនហាក់ដូចជាមាននិន្នាការរៀបការយឺតជាងបុរសនៅជនបទ។

**តារាង ៣.៥.២. អាយុមធ្យមរៀបការលើកទីមួយ តាមភេទ និងតំបន់ ខេត្តឧត្តរមានជ័យ ឆ្នាំ ២០០៨ និង ២០១៩**

| តំបន់ | ឆ្នាំ ២០០៨ | | | ឆ្នាំ ២០១៩ | | |
|---|---|---|---|---|---|---|
| | ប្រុស | ស្រី | គំលាតអាយុរៀបការដំបូង | ប្រុស | ស្រី | គំលាតអាយុរៀបការដំបូង |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) |
| សរុប | ២៤ | ២២ | ២ | ២៥ | ២២ | ៣ |
| ទីប្រជុំជន | ២៥ | ២២ | ៣ | ២៦ | ២៣ | ៣ |
| ជនបទ | ២៤ | ២២ | ២ | ២៥ | ២២ | ៣ |

## ៣.៦. អាយុរៀបការយុវវ័យ

សមាមាត្រអាយុរៀបការរបស់យុវវ័យក្នុងចំណោមប្រុស និងស្រីស្ទើរតែដូចគ្នាទាំងឆ្នាំ២០០៨ និង ២០១៩ នៅថ្នាក់ខេត្ត។ ទោះជាយ៉ាងណាក៏ដោយនៅតំបន់ទីប្រជុំជនបានកើនបន្តិច ហើយបានធ្លាក់ចុះបន្តិចនៅតំបន់ជនបទ។ សម្រាប់ប្រុស និងស្រី សមាមាត្ររៀបការនៅយុវវ័យអាយុពី ១៥-១៩ ឆ្នាំ នៅជនបទខ្ពស់ជាងនៅតំបន់ទីប្រជុំជន (តារាង ៣.៦.១)។ សមាមាត្រដែលបានរៀបការក្នុងចំណោមស្រីអាយុពី ២០-២៤ ឆ្នាំ នៅជនបទមានខ្ពស់ជាងបើប្រៀបធៀបនឹងតំបន់ទីប្រជុំជន។

## តារាង ៣.៦.១. អាយុមធ្យមរៀបការដំបូង សមាមាត្រធ្លាប់រៀបការ តាមភេទ អាយុ និងតំបន់ ខេត្តឧត្តរមានជ័យ ឆ្នាំ ២០០៨ -២០១៩

| តំបន់ | ប្រុស | | | | ស្រី | | | | អាយុមធ្យមរៀបការដំបូង ប្រុស និងស្រី |
|---|---|---|---|---|---|---|---|---|---|
| | អាយុមធ្យមរៀបការដំបូង | ភាគរយអ្នកធ្លាប់រៀបការ | | | អាយុមធ្យមរៀបការដំបូង | ភាគរយអ្នកធ្លាប់រៀបការ | | | |
| | | ១៥–១៩ | ២០-២៤ | ៤៥-៤៩ | | ១៥–១៩ | ២០-២៤ | ៤៥-៤៩ | |
| ២០០៨ | | | | | | | | | |
| សរុប | ២៤ | ២,៩ | ៤៤,៦ | ៥២,៥ | ២២ | ១០,៤ | ៤៨,៣ | ៤១,៣ | ២ |
| | | | រដ្ឋាភិបាល | សហគ្រាសរដ្ឋ | សហគ្រាសឯកជនខេត្តឧត្តរមានជ័យ | សហគ្រាសបរទេស | ស្ថាប័នមិនយកប្រាក់ចំណេញ | ផ្នែកគ្រួសារ | ស្ថានទូតស្ថាប័នអន្តរជាតិ | ដ៏ទៃទៀត |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) | (៩) | (១០) | (១១) |
| ជនបទ | ១០៨.២៨០ | ១០០ | ៧,៧ | ០,២ | ៩០,៤ | ១,០ | ០,៤ | ០,១ | ០,០ | - |
| ៥ – ១៤ | ១.១០៣ | ១០០ | ០,២ | - | ៩១,៤ | ០,៦ | ៧,៦ | - | - | - |
| ១៥ – ៥៩ | ៩៨.៦៣២ | ១០០ | ៨,១ | ០,២ | ៩០,១ | ១,១ | ០,៣ | ០,១ | ០,០ | - |
| ៦០ ឆ្នាំឡើង | ៨.៥៤៥ | ១០០ | ៤,៦ | ០,២ | ៩៤,១ | ០,២ | ០,៨ | ០,១ | ០,០ | - |
| ប្រុស | ៥៥.៧៦៥ | ១០០ | ១៣,២ | ០,៣ | ៨៤,៧ | ០,៩ | ០,៧ | ០,១ | ០,១ | - |
| ៥ – ១៤ | ៦៣៦ | ១០០ | - | - | ៨៦,៣ | ០,៣ | ១៣,១ | - | - | - |
| ១៥ – ៥៩ | ៥០.៧៣៧ | ១០០ | ១៣,៨ | ០,៣ | ៨៤,២ | ១,០ | ០,៦ | ០,១ | ០,១ | - |
| ៦០ ឆ្នាំឡើង | ៤.៣៩២ | ១០០ | ៧,៩ | ០,៣ | ៩០,៤ | ០,១ | ១,២ | ០,០ | ០,០ | - |
| ស្រី | ៥២.៥១៥ | ១០០ | ២,០ | ០,១ | ៩៦,៥ | ១,១ | ០,១ | ០,២ | ០,០ | - |
| ៥ – ១៤ | ៤៦៧ | ១០០ | ០,៤ | - | ៩៨,៣ | ១,១ | ០,២ | - | - | - |
| ១៥ – ៥៩ | ៤៧.៨៩៥ | ១០០ | ២,១ | ០,១ | ៩៦,៤ | ១,២ | ០,១ | ០,២ | ០,០ | - |
| ៦០ ឆ្នាំឡើង | ៤.១៥៣ | ១០០ | ១,១ | ០,២ | ៩៨,០ | ០,២ | ០,៤ | ០,២ | - | - |

**សម្គាល់ ៖** មិនរាប់បញ្ចូលផ្នែកនៃការងារដែលមិនបានរាយការណ៍។

## ៥.៦. ចំណាត់ថ្នាក់ការងារតាមមុខរបរ និងសកម្មភាពសេដ្ឋកិច្ច

ចរិតលក្ខណៈសកម្មភាពសេដ្ឋកិច្ច និងសេវាកម្ម ក៏ដូចជាមុខរបរដែលទទួលបានពីជំរឿនទូទៅប្រជាជននៅខេត្តឧត្តរមានជ័យ ឆ្នាំ២០១៩ ដោយអ្នកមានការងារធ្វើ និងអ្នកគ្មានការងារធ្វើ (បានធ្វើការងារពីមុន) ត្រូវបានដាក់លេខកូដនៅការិយាល័យ ដោយអនុវត្តតាមចំណាត់ថ្នាក់បទដ្ឋានអន្តរជាតិនៃសកម្មភាពសេដ្ឋកិច្ច ជំនាន់៤ និងចំណាត់ថ្នាក់បទដ្ឋានអន្តរជាតិនៃមុខរបរ ឆ្នាំ៨៨ ។ តារាង ៥.៦.១ និង ៥.៦.២ បង្ហាញការបែងចែកអ្នកមានការងារធ្វើ តាមចំណាត់ថ្នាក់មុខរបរ និងសកម្មភាពសេដ្ឋកិច្ច ភេទ និងតំបន់ ខេត្តឧត្តរមានជ័យ។ យើងសង្កេតឃើញថាវិស័យកសិកម្មនៅតែមានភាពលើសលប់ បើប្រៀបធៀបនឹងវិស័យផលិតកម្មឧស្សាហកម្ម និងសេវាកម្ម ។

នៅឆ្នាំ២០១៩ អ្នកមានការងារធ្វើភាគច្រើននៅក្នុងសេដ្ឋកិច្ចខេត្តឧត្តរមានជ័យ មានមុខរបរជំនាញកសិកម្ម ព្រៃឈើ និងនេសាទ ប្រមាណ ៧៥,២ ភាគរយ អ្នកធ្វើការងារខាងសេវាកម្ម និងលក់ដូរ ៧,៨ ភាគរយ និងកម្លាំងប្រដាប់អាវុធ ៤,៧ ភាគរយ។ ទាំងនេះបានបញ្ជាក់ថា ទីផ្សារការងារនៅខេត្តឧត្តរមានជ័យមានជំនាញ និងត្រូវការបណ្តុះបណ្តាលវិជ្ជាជីវៈជំនាញការងារបន្ថែមសម្រាប់ការប្រកួតប្រជែងទីផ្សារការងារ ដែលជារបៀបវារៈបន្ទាន់របស់រាជរដ្ឋាភិបាល។

ក្នុងចំណោមក្រុមមុខរបរចម្បងទាំងប្រាំបួន មានតែមុខរបរចម្បងចំនួនបី ឬបួនប៉ុណ្ណោះ ដែលស្រីមានសមាមាត្រខ្ពស់ជាងប្រុស គឺមុខរបរជំនាញកសិកម្ម ព្រៃឈើ និងនេសាទ សិប្បកម្ម និងការងារដែលទាក់ទង និងសេវាកម្ម និងលក់ដូរ និងមុខរបរងាយៗ។ ទោះជាយ៉ាងណាក៏ដោយការខុសគ្នានេះមានក្នុងកម្រិតទាប ។

ការបែងចែកតាមតំបន់ ភាគច្រើននៃអ្នកមានការងារធ្វើនៅទីប្រជុំជន មុខរបរនាញកសិកម្ម ព្រៃឈើ និងនេសាទ (៦០,៩ ភាគរយ) បន្ទាប់មកមានអ្នកធ្វើការងារខាងសេវាកម្ម និងលក់ដូរ (១៣,៦ ភាគរយ) អ្នកធ្វើការខាងសិប្បកម្ម និងការងារដែលទាក់ទង (៥,២ ភាគរយ) និងមុខរបរងាយៗ (៣,៣ ភាគរយ) ។ កសិកម្មនៅតែដើរតួយ៉ាងសំខាន់នៅតំបន់ជនបទខេត្តឧត្តរមានជ័យ (៨២,០ ភាគរយ) កម្លាំងប្រដាប់អាវុធ (៥,១ ភាគរយ) និងអ្នកធ្វើការខាងអ្នកធ្វើការងារខាងសេវាកម្ម និងលក់ដូរ(៥,០ ភាគរយ)។

ប្រៀបធៀបនឹងឆ្នាំ២០០៨ ភាគច្រើននៃអ្នកមានការងារធ្វើ មានមុខរបរជំនាញកសិកម្ម ព្រៃឈើ និងនេសាទ ដែលមានសមាមាត្រកើនឡើងពី ៨១,៥ ភាគរយ មក ៨២,០ ភាគរយ ខណៈដែលមុខរបរផ្សេងទៀតបានកើនឡើង។

## តារាង ៥.៦.១. ការបែងចែកភាគរយនៃអ្នកមានការងារធ្វើ តាមមុខរបរ អាជីព ភេទ និងតំបន់ ខេត្តឧត្តរមានជ័យ ឆ្នាំ ២០០៨-២០១៩

| ក្រុមអាជីព | | ភាគរយនៃអ្នកមានការងារធ្វើ | | | | | |
|---|---|---|---|---|---|---|---|
| | | ២០០៨ | | | ២០១៩ | | |
| ក្រុម | បរិយាយ | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) |
| | | | | | | | |
| | សរុប | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ |
| ០ | កម្លាំងប្រដាប់អាវុធ | ២,៣ | ៤,៤ | ០,១ | ៤,៧ | ៨,៧ | ០,៣ |
| ១ | អ្នកគ្រប់គ្រង | ០,៥ | ០,៨ | ០,២ | ០,៦ | ០,៨ | ០,៣ |
| ២ | វិជ្ជាជីវៈ | ១,១ | ១,៧ | ០,៥ | ២,៧ | ៣,២ | ២,១ |
| ៣ | អ្នកបច្ចេកទេស និងវិជ្ជាជីវៈ | ១,៥ | ២,៣ | ០,៦ | ០,៧ | ១,០ | ០,៤ |
| ៤ | ស្មៀន | ១,៩ | ២,១ | ១,៧ | ១,៨ | ២,០ | ១,៧ |
| ៥ | អ្នកធ្វើការងារខាងសេវាកម្ម និងលក់ដូរ | ៦,១ | ៤,៩ | ៧,៤ | ៧,៨ | ៥,៨ | ១០,០ |
| ៦ | អ្នកធ្វើការ ខាងកសិកម្ម ព្រៃឈើ និងនេសាទ | ៨០,២ | ៧៥,០ | ៨៥,៦ | ៧៥,២ | ៦៩,៧ | ៨១,០ |
| ៧ | អ្នកធ្វើការខាងសិប្បកម្ម និងការងារដែលទាក់ទង | ២,១ | ៣,១ | ១,២ | ៣,៤ | ៤,៨ | ១,៨ |
| ៨ | ការិបញ្ជាម៉ាស៊ីនរោងចក្រ និងម៉ាស៊ីន និងអ្នកផ្គុំតម្លើង | ០,៩ | ១,៦ | ០,២ | ០,៦ | ១,១ | ០,២ |
| ៩ | មុខរបរងាយៗ | ៣,៤ | ៤,១ | ២,៦ | ២,៥ | ២,៩ | ២,២ |

## តារាង ៥.៦.១. ការបែងចែកភាគរយនៃអ្នកមានការងារធ្វើ តាមមុខរបរ អាជីព ភេទ និងតំបន់ ខេត្តឧត្តរមានជ័យ ឆ្នាំ ២០០៨-២០១៩ (ត)

| ក្រុមអាជីព | | ភាគរយនៃអ្នកមានការងារធ្វើ | | | | | |
|---|---|---|---|---|---|---|---|
| | | ២០០៨ | | | ២០១៩ | | |
| ក្រុម | បរិយាយ | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) |
| | **ទីប្រជុំជន** | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ |
| ០ | កម្លាំងប្រដាប់អាវុធ | ៥,២ | ៩,៥ | ០,៣ | ៣,៧ | ៦,៧ | ០,៤ |
| ១ | អ្នកគ្រប់គ្រង | ០,៣ | ០,៥ | ០,១ | ០,៨ | ០,៩ | ០,៦ |
| ២ | វិជ្ជាជីវៈ | ២,១ | ២,៥ | ១,៦ | ៣,៥ | ៤,០ | ២,៩ |
| ៣ | អ្នកបច្ចេកទេស និងវិជ្ជាជីវៈ | ២,៥ | ៣,៦ | ១,២ | ១,៣ | ១,៧ | ០,៨ |
| ៤ | ស្មៀន | ២,៥ | ៣,៥ | ១,៤ | ៤,៥ | ៤,៤ | ៤,៥ |
| ៥ | អ្នកធ្វើការងារខាងសេវាកម្ម និងលក់ដូរ | ១០,៨ | ៧,១ | ១៥,២ | ១៣,៦ | ១០,០ | ១៧,៧ |
| ៦ | អ្នកធ្វើការ ខាងកសិកម្ម ព្រៃឈើ និងនេសាទ | ៦៦,៨ | ៦០,៦ | ៧៣,៩ | ៦០,៩ | ៥៦,៨ | ៦៥,៥ |
| ៧ | អ្នកធ្វើការខាងសិប្បកម្ម និងការងារដែលទាក់ទង | ៣,៩ | ៥,៥ | ២,០ | ៥,២ | ៧,៤ | ២,៨ |
| ៨ | ការីបញ្ជាម៉ាស៊ីនរោងចក្រ និងម៉ាស៊ីន និងអ្នកផ្គុំតម្លើង | ១,៣ | ២,២ | ០,៣ | ១,២ | ២,១ | ០,៣ |
| ៩ | មុខរបរងាយៗ | ៤,៦ | ៥,១ | ៤,០ | ៥,៣ | ៥,៩ | ៤,៧ |

## តារាង ៥.៦.១. ការបែងចែកភាគរយនៃអ្នកមានការងារធ្វើ តាមមុខរបរ អាជីព ភេទ និងតំបន់ ខេត្តឧត្តរមានជ័យ ឆ្នាំ ២០០៨-២០១៩ (ត)

| ក្រុមអាជីព | | ភាគរយនៃអ្នកមានការងារធ្វើ | | | | | |
|---|---|---|---|---|---|---|---|
| | | ២០០៨ | | | ២០១៩ | | |
| ក្រុម | បរិយាយ | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) |
| | ជនបទ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ |
| ០ | កម្លាំងប្រដាប់អាវុធ | ២,០ | ៣,៩ | ០,១ | ៥,១ | ៩,៧ | ០,៣ |
| ១ | អ្នកគ្រប់គ្រង | ០,៥ | ០,៨ | ០,២ | ០,៥ | ០,៧ | ០,២ |
| ២ | វិជ្ជាជីវៈ | ១,០ | ១,៦ | ០,៤ | ២,៣ | ២,៩ | ១,៧ |
| ៣ | អ្នកបច្ចេកទេស និងវិជ្ជាជីវៈ | ១,៤ | ២,១ | ០,៦ | ០,៤ | ០,៧ | ០,២ |
| ៤ | ស្មៀន | ១,៨ | ១,៩ | ១,៧ | ០,៦ | ០,៧ | ០,៤ |
| ៥ | អ្នកធ្វើការងារខាងសេវាកម្ម និងលក់ដូរ | ៥,៧ | ៤,៧ | ៦,៧ | ៥,០ | ៣,៧ | ៦,៤ |
| ៦ | អ្នកធ្វើការ ខាងកសិកម្ម ព្រៃឈើ និងនេសាទ | ៨១,៥ | ៧៦,៥ | ៨៦,៧ | ៨២,០ | ៧៦,០ | ៨៨,២ |
| ៧ | អ្នកធ្វើការខាងសិប្បកម្ម និងការងារដែលទាក់ទង | ២,០ | ២,៨ | ១,១ | ២,៥ | ៣,៥ | ១,៤ |
| ៨ | ការិបញ្ជាម៉ាស៊ីនរោងចក្រ និងម៉ាស៊ីន និងអ្នកផ្គុំតម្លើង | ០,៩ | ១,៦ | ០,២ | ០,៤ | ០,៦ | ០,១ |
| ៩ | មុខរបរងាយៗ | ៣,២ | ៤,០ | ២,៥ | ១,២ | ១,៤ | ១,០ |

**សម្គាល់ ៖** មិនរាប់បញ្ចូលមុខរបរដែលមិនបានរាយការណ៍។

តារាង ៥.៦.២ បង្ហាញការបែងចែកភាគរយនៃប្រជាជនមានការងារធ្វើតាមសកម្មភាពសេដ្ឋកិច្ច។ រចនាសម្ព័ន្ធសេដ្ឋកិច្ចខេត្តឧត្តរមានជ័យបានផ្លាស់ប្តូរឆ្ពោះទៅរកឧស្សាហ៍កម្មទំនើប និងសម័យការូបនីយកម្ម ដោយកំណើនក្នុងវិស័យកម្មន្តសាល ពាណិជ្ជកម្មលក់ដុំលក់រាយ ជួសជុលយានយន្ត និងទោចក្រយានយន្ត សំណង់ស៊ីវិល និងសេវាកម្មផ្សេងទៀត ហើយនិន្នាការថយចុះនៃសមាមាត្រការងារក្នុងវិស័យកសិកម្ម។ តារាងខាងក្រោមបង្ហាញពីការផ្លាស់ប្តូររចនាសម្ព័ន្ធការងាររវាងបីក្រុមវិស័យការងារក្នុងអំឡុង ១១ ឆ្នាំកន្លងមក គឺជាងបីភាគបួននៃការងារធ្វើការក្នុងវិស័យ "កសិកម្ម ព្រៃឈើ និងនេសាទ" ឆ្នាំ២០០៨។ ទោះជាយ៉ាងណាក៏ដោយ នៅឆ្នាំ២០១៩ អ្នកមានការងារធ្វើទាំងអស់ក្នុងវិស័យ "កសិកម្ម ព្រៃឈើ និងនេសាទ" បានថយចុះមក ៧៦,១ ភាគរយ។ ក្រុមវិស័យការងារផ្សេងទៀតមានភាគរយខ្ពស់ដូចជាផលិតកម្ម កើនពី ១,៥ ភាគរយមក ១,៧ ភាគរយ ពាណិជ្ជកម្មលក់ដុំ និងរាយ ជួសជុលរថយន្ត និងទោចក្រយានយន្ត" កើនពី ៥,៦ ភាគរយមក ៧,២ ភាគរយ សំណង់ ១,៣ មក ២,០ ភាគរយ និងក្រៅពីនេះវិស័យការងារផ្សេងទៀតមានភាគរយទាបក្នុងវិស័យការងារនៅខេត្តឧត្តរមានជ័យ។

## តារាង ៥.៦.២. ការបែងចែកភាគរយនៃប្រជាជនមានការងារធ្វើ តាមសកម្មភាពការងារ អាយុ ៥ ឆ្នាំឡើង តាមភេទ និងតំបន់ ខេត្តឧត្តរមានជ័យ ឆ្នាំ២០០៨ - ២០១៩

| ប្រភេទសកម្មភាព | | ភាគរយនៃអ្នកមានការងារធ្វើ | | | | | |
|---|---|---|---|---|---|---|---|
| | | ២០០៨ | | | ២០១៩ | | |
| ផ្នែក | បរិយាយ | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) |
| | សរុប | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ |
| A | កសិកម្ម ព្រៃឈើ និងនេសាទ | ៨១,៣ | ៧៦,២ | ៨៦,៦ | ៧៦,១ | ៧០,៦ | ៨១,៩ |
| B | រុករករ៉ែ និងថ្ម | ០,២ | ០,២ | ០,១ | ០,០ | ០,០ | ០,០ |
| C | ផលិតកម្ម | ១,៥ | ១,៨ | ១,១ | ១,៧ | ២,១ | ១,២ |
| D | អគ្គិសនី ឧស្ម័ន ចំហាយទឹក និងការផ្គត់ផ្គង់ម៉ាស៊ីនត្រជាក់ | ០,០ | ០,១ | ០,០ | ០,១ | ០,១ | ០,០ |
| E | ការផ្គត់ផ្គង់ទឹក លូទឹក ការគ្រប់គ្រងសំរាម និងសកម្មភាពបង្ការ | ០,០ | ០,១ | ០,០ | ០,១ | ០,១ | ០,១ |
| F | សំណង់ | ១,៣ | ២,០ | ០,៦ | ២,០ | ២,៨ | ១,១ |
| G | ពាណិជ្ជកម្មលក់ដុំ និងរាយជួសជុលយានយន្ត និងទោចក្រយានយន្ត | ៥,៦ | ៤,៥ | ៦,៨ | ៧,២ | ៥,៧ | ៨,៨ |
| H | ដឹកជញ្ជូន និងឃ្លាំង | ១,៤ | ២,២ | ០,៥ | ០,៩ | ១,៤ | ០,៣ |
| I | សកម្មភាពសេវាកម្មទីស្នាក់អាស្រ័យ និងម្ហូបអាហារ | ០,៥ | ០,៤ | ០,៧ | ០,៨ | ០,៥ | ១,១ |
| J | ព័ត៌មាន និងគមនាគមន៍ | ០,១ | ០,១ | ០,១ | ០,១ | ០,១ | ០,១ |
| K | សកម្មភាពហិរញ្ញវត្ថុ និងធានារ៉ាប់រង | ០,១ | ០,១ | ០,០ | ០,៤ | ០,៥ | ០,៣ |
| L | អចលនទ្រព្យ | ០,១ | ០,១ | ០,០ | ០,២ | ០,២ | ០,២ |
| M | សកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកទេស | ០,៣ | ០,៣ | ០,២ | ០,៥ | ០,៥ | ០,៤ |
| N | សកម្មភាពរដ្ឋបាល និងសេវាកម្មគាំទ្រ | ៣,៨ | ៧,១ | ០,៤ | ៦,១ | ១០,៩ | ០,៨ |
| O | រដ្ឋបាលសាធារណៈ និងការការពារ សន្តិសុខសង្គម | ១,១ | ១,៧ | ០,៥ | ១,៦ | ១,៨ | ១,៤ |
| P | ការសិក្សាអប់រំ | ០,៣ | ០,៤ | ០,២ | ០,៤ | ០,៥ | ០,៣ |
| Q | សកម្មភាពសុខាភិបាល និងការងារសង្គម | ១,២ | ១,០ | ១,៣ | ១,០ | ០,៩ | ១,១ |
| R | សិល្បៈ ការកំសាន្ត និងការសប្បាយ | ១,១ | ១,៦ | ០,៧ | ១,០ | ១,២ | ០,៧ |
| S | សកម្មភាពសេវាកម្មដទៃទៀត | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ |
| T | សកម្មភាពប្រើប្រាស់គ្រួសារជានិយោជក | ០,១ | ០,២ | ០,១ | ០,០ | ០,០ | ០,០ |
| U | សកម្មភាពអង្គការ និងអង្គការក្រៅបរទេស | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ |

## តារាង ៥.៦.២. ការបែងចែកភាគរយនៃប្រជាជនមានការងារធ្វើ តាមសកម្មភាពការងារ អាយុ ៥ ឆ្នាំឡើង តាមភេទ និងតំបន់ ខេត្តឧត្តរមានជ័យ ឆ្នាំ២០០៨ - ២០១៩ (ត)

| ប្រភេទសកម្មភាព | | ភាគរយនៃអ្នកមានការងារធ្វើ | | | | | |
|---|---|---|---|---|---|---|---|
| | | ២០០៨ | | | ២០១៩ | | |
| ផ្នែក | បរិយាយ | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) |
| | ទីប្រជុំជន | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ |
| A | កសិកម្ម ព្រៃឈើ និងនេសាទ | ៦៧,៣ | ៦១,១ | ៧៤,៦ | ៦២,៥ | ៥៨,៣ | ៦៧,២ |
| B | រុករករ៉ែ និងថ្ម | ០,០ | ០,០ | ០,០ | ០,១ | ០,១ | ០,១ |
| C | ផលិតកម្ម | ២,៨ | ៣,៣ | ២,៣ | ២,៥ | ៣,៤ | ១,៦ |
| D | អគ្គិសនី ឧស្ម័ន ចំហាយទឹក និងការផ្គត់ផ្គង់ម៉ាស៊ីនត្រជាក់ | ០,១ | ០,១ | ០,០ | ០,១ | ០,២ | ០,០ |
| E | ការផ្គត់ផ្គង់ទឹក លូទឹក ការគ្រប់គ្រងសំរាម និងសកម្មភាពបង្ការ | ០,០ | ០,០ | ០,០ | ០,២ | ០,១ | ០,២ |
| F | សំណង់ | ២,៤ | ៣,៣ | ១,៤ | ៣,៩ | ៥,៣ | ២,៥ |
| G | ពាណិជ្ជកម្មលក់ដុំ និងរាយ ជួសជុលរថយន្ត និងទោចក្រយានយន្ត | ១០,២ | ៧,៣ | ១៣,៥ | ១២,២ | ៩,៦ | ១៥,០ |
| H | ដឹកជញ្ជូន និងឃ្លាំង | ១,៧ | ២,៨ | ០,៤ | ២,០ | ៣,១ | ០,៧ |
| I | សកម្មភាពសេវាកម្មទីស្នាក់អាស្រ័យ និងម្ហូបអាហារ | ១,២ | ០,៧ | ១,៨ | ១,៦ | ១,០ | ២,២ |
| J | ព័ត៌មាន និងគមនាគមន៍ | ០,១ | ០,១ | ០,០ | ០,២ | ០,២ | ០,១ |
| K | សកម្មភាពហិរញ្ញវត្ថុ និងធានារ៉ាប់រង | ០,២ | ០,៤ | ០,១ | ០,៧ | ០,៨ | ០,៦ |
| L | អចលនទ្រព្យ | ០,១ | ០,១ | ០,០ | ០,៤ | ០,៤ | ០,៤ |
| M | សកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកទេស | ០,១ | ០,២ | ០,០ | ១,០ | ១,០ | ១,០ |
| N | សកម្មភាពរដ្ឋបាល និងសេវាកម្មគាំទ្រ | ៨,៤ | ១៤,៣ | ១,៤ | ៦,១ | ១០,២ | ១,៥ |
| O | រដ្ឋបាលសាធារណៈ និងការការពារ សន្តិសុខសង្គម | ២,០ | ២,៤ | ១,៦ | ១,៨ | ១,៧ | ១,៨ |
| P | ការសិក្សាអប់រំ | ០,៧ | ០,៩ | ០,៥ | ០,៥ | ០,៦ | ០,៤ |
| Q | សកម្មភាពសុខាភិបាល និងការងារសង្គម | ០,០ | ០,០ | ០,០ | ២,៨ | ២,៤ | ៣,២ |
| R | សិល្បៈ ការកំសាន្ត និងការសប្បាយ | ២,១ | ២,២ | ១,៩ | ១,៧ | ១,៧ | ១,៦ |
| S | សកម្មភាពសេវាកម្មដទៃទៀត | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ |
| T | សកម្មភាពប្រើប្រាស់គ្រួសារជានិយោជក | ០,៦ | ០,៨ | ០,៤ | ០,០ | ០,០ | ០,០ |
| U | សកម្មភាពអង្គការ និងអង្គការក្រៅបរទេស | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ |

## តារាង ៥.៦.២. ការបែងចែកភាគរយនៃប្រជាជនមានការងារធ្វើ តាមសកម្មភាពការងារ អាយុ ៥ ឆ្នាំឡើង តាមភេទ និងតំបន់ ខេត្តឧត្តរមានជ័យ ឆ្នាំ២០០៨ - ២០១៩ (ត)

| ប្រភេទសកម្មភាព | | ភាគរយនៃអ្នកមានការងារធ្វើ | | | | | |
|---|---|---|---|---|---|---|---|
| | | ២០០៨ | | | ២០១៩ | | |
| ផ្នែក | បរិយាយ | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) | (៨) |
| | **ជនបទ** | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ |
| A | កសិកម្ម ព្រៃឈើ និងនេសាទ | ៨២,៧ | ៧៧,៨ | ៨៧,៨ | ៧៦,១ | ៧០,៦ | ៨១,៩ |
| B | រុករករ៉ែ និងថ្ម | ០,២ | ០,២ | ០,២ | ០,០ | ០,០ | ០,០ |
| C | ផលិតកម្ម | ១,៣ | ១,៦ | ១,០ | ១,៧ | ២,១ | ១,២ |
| D | អគ្គិសនី ឧស្ម័ន ចំហាយទឹក និងការផ្គត់ផ្គង់ម៉ាស៊ីនត្រជាក់ | ០,០ | ០,១ | ០,០ | ០,១ | ០,១ | ០,០ |
| E | ការផ្គត់ផ្គង់ទឹក លូទឹក ការគ្រប់គ្រងសំរាម និងសកម្មភាពបង្ការ | ០,០ | ០,១ | ០,០ | ០,១ | ០,១ | ០,១ |
| F | សំណង់ | ១,២ | ១,៩ | ០,៥ | ២,០ | ២,៨ | ១,១ |
| G | ពាណិជ្ជកម្មលក់ដុំ និងរាយជួសជុលរថយន្ត និងទោចក្រយានយន្ត | ៥,១ | ៤,២ | ៦,១ | ៧,២ | ៥,៧ | ៨,៨ |
| H | ដឹកជញ្ជូន និងឃ្លាំង | ១,៣ | ២,១ | ០,៥ | ០,៩ | ១,៤ | ០,៣ |
| I | សកម្មភាពសេវាកម្មទីស្នាក់អាស្រ័យ និងម្ហូបអាហារ | ០,៥ | ០,៣ | ០,៦ | ០,៨ | ០,៥ | ១,១ |
| J | ព័ត៌មាន និងគមនាគមន៍ | ០,១ | ០,១ | ០,១ | ០,១ | ០,១ | ០,១ |
| K | សកម្មភាពហិរញ្ញវត្ថុ និងធានារ៉ាប់រង | ០,០ | ០,០ | ០,០ | ០,៤ | ០,៥ | ០,៣ |
| L | អចលនទ្រព្យ | ០,១ | ០,១ | ០,០ | ០,២ | ០,២ | ០,២ |
| M | សកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកទេស | ០,៣ | ០,៤ | ០,២ | ០,៥ | ០,៥ | ០,៤ |
| N | សកម្មភាពរដ្ឋបាល និងសេវាកម្មគាំទ្រ | ៣,៤ | ៦,៣ | ០,៣ | ៦,១ | ១០,៩ | ០,៨ |
| O | រដ្ឋបាលសាធារណៈ និងការការពារ សន្តិសុខសង្គម | ១,០ | ១,៦ | ០,៤ | ១,៦ | ១,៨ | ១,៤ |
| P | ការសិក្សាអប់រំ | ០,៣ | ០,៣ | ០,២ | ០,៤ | ០,៥ | ០,៣ |
| Q | សកម្មភាពសុខាភិបាល និងការងារសង្គម | ១,៣ | ១,១ | ១,៤ | ១,០ | ០,៩ | ១,១ |
| R | សិល្បៈ ការកំសាន្ត និងការសប្បាយ | ១,០ | ១,៥ | ០,៦ | ១,០ | ១,២ | ០,៧ |
| S | សកម្មភាពសេវាកម្មដ៏ទៃទៀត | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ |
| T | សកម្មភាពប្រើប្រាស់គ្រួសារជានិយោជក | ០,១ | ០,២ | ០,០ | ០,០ | ០,០ | ០,០ |
| U | សកម្មភាពអង្គការ និងអង្គការក្រៅបរទេស | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ |

**សម្គាល់ ៖** មិនរាប់បញ្ចូលសកម្មភាពសេដ្ឋកិច្ចដែលមិនបានរាយការណ៍។

# ជំពូក ៦
# ទេសន្តរប្រវេសន៍

## ៦.១. ទស្សនទាន

ទេសន្តរប្រវេសន៍ត្រូវបានកំណត់ជាដំណើរការផ្លាស់ប្តូរទីកន្លែងរស់នៅ ពីទីតាំងភូមិសាស្ត្រមួយទៅភូមិសាស្ត្រមួយទៀត។ នៅពេលដែលចលនាស្ថិតនៅក្នុងប្រទេសតែមួយត្រូវបានចាត់ទុកថា ជាការធ្វើទេសន្តរប្រវេសន៍ក្នុងស្រុក ហើយករណីពាក់ព័ន្ធនឹងការផ្លាស់ប្តូរប្រទេសហៅថា ការធ្វើទេសន្តរប្រវេសន៍អន្តរជាតិ។ ការរួមបញ្ចូលគ្នាជាមួយលទ្ធភាពបង្កើតកូន មរណភាព និងទេសន្តរប្រវេសន៍បានកំណត់នូវទំហំ និងអត្រាកំណើនប្រជាជន ក៏ដូចជារចនាសម្ព័ន្ធ និងចរិតលក្ខណៈ។ ប្រធានបទនេះមានសារៈសំខាន់ និងចំណាប់អារម្មណ៍ មិនសម្រាប់តែប្រជាជនប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់អ្នកសេដ្ឋកិច្ច អ្នកសង្គមកិច្ច អ្នកភូមិសាស្ត្រ មនុស្សសាស្ត្រ អ្នកវិទ្យាសាស្ត្រ នយោបាយ អ្នកច្បាប់ និងអ្នកធ្វើគោលនយោបាយ អ្នករៀបចំផែនការ និងអ្នកគ្រប់គ្រងសាធារណៈផងដែរ។

ទេសន្តរប្រវេសន៍គឺជាចលនាភូមិសាស្ត្ររបស់ប្រជាជនឆ្លងកាត់ព្រំដែន ដែលបានបញ្ជាក់សម្រាប់គោលបំណងតាំងទីលំនៅអចិន្ត្រៃយ៍ ឬពាក់កណ្តាលអចិន្ត្រៃយ៍។ ទន្ទឹមនឹងការកើត និងការស្លាប់ ទេសន្តរប្រវេសន៍គឺជាសមាសធាតុនៃការប្រែប្រួលប្រជាជន។ ពាក្យ "អន្តោប្រវេសន៍" និង "និរប្រវេសន៍" ត្រូវបានប្រើ ដើម្បីសំដៅទៅលើការផ្លាស់ប្តូររវាងប្រទេស (ទេសន្តរប្រវេសន៍អន្តរជាតិ)។ ពាក្យស្របគ្នា "ទេសន្តរប្រវេសន៍ក្នុងស្រុក" និង "ទេសន្តរប្រវេសន៍ក្រៅស្រុក" ត្រូវបានប្រើប្រាស់សម្រាប់ទេសន្តរប្រវេសន៍ក្នុងប្រទេស។ សម្រាប់គោលបំណងនៃការវិភាគនេះទេសន្តរប្រវេសន៍សំដៅទៅលើមនុស្សណាម្នាក់ដែលបានផ្លាស់ទៅកន្លែងរាប់សម្ភាសន៍ យ៉ាងហោចណាស់ពីភូមិផ្សេងទៀត (ឬពីប្រទេសផ្សេងទៀត) ដែលជាទីលំនៅចុងក្រោយរបស់មនុស្សនោះ។

## ៦.២. ចំនួនជនទេសន្តរប្រវេសន៍

យោងតាមលទ្ធផលជំរឿនប្រជាជន ឆ្នាំ២០១៩ ប្រមាណ ៦២,៧ ភាគរយនៃប្រជាជនខេត្តឧត្តរមានជ័យមិនដែលមានទីលំនៅផ្សេងក្រៅពីកន្លែងធ្វើសម្ភាសន៍ (តារាង ៦.២.១)។ នៅតំបន់ទីប្រជុំជនមានប្រហាក់ប្រហែលជនបទ (៥៩,៣ ភាគរយ និង ៦៤,៤ ភាគរយ)។ និយាយដោយឡែកភាគរយនៃទេសន្តរប្រវេសន៍នៅខេត្តឧត្តរមានជ័យឆ្នាំ២០១៩ មាន ៣៧,៣ ភាគរយ តំបន់ទីប្រជុំជនមាន ៤០,៧ ភាគរយ និងនៅតំបន់ជនបទមាន ៣៥,៦ ភាគរយ។ លទ្ធផលជំរឿនប្រជាជនខេត្តឧត្តរមានជ័យទាំងពីរលើកមុន (ឆ្នាំ១៩៩៨ និងឆ្នាំ២០០៨) ភាគរយនៃជនទេសន្តរប្រវេសន៍ក្នុងចំណោមប្រជាជនបានធ្លាក់ចុះ។ ក្នុងរយៈពេល ៣ ទសវត្សរ៍ ភាគរយនៃប្រជាជន តែងតែរស់នៅកន្លែងតែមួយបានកើនឡើង ទាំងនៅតំបន់ទីប្រជុំជន និងតំបន់ជនបទ។ និន្នាការនេះដូចគ្នារវាងប្រុស និង ស្រី។

### តារាង ៦.២.១. ចំនួនប្រជាជនតែងតែរស់នៅកន្លែងសម្ភាសន៍ និងចំណាកស្រុក តាមតំបន់ ខេត្តឧត្តរមានជ័យឆ្នាំ២០០៨-២០១៩*

| តំបន់ | ឆ្នាំ ២០០៨ | | | ឆ្នាំ ២០១៩ | | |
|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) |
| **សរុប** | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ |
| រស់នៅកន្លែងសម្ភាសន៍ | ៥០,៣ | ៤៩,៤ | ៥១,៣ | ៦២,៧ | ៦១,៣ | ៦៤,១ |
| ចំណាកស្រុក | ៤៩,៧ | ៥០,៦ | ៤៨,៧ | ៣៧,៣ | ៣៨,៧ | ៣៥,៩ |
| **ទីប្រជុំជន** | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ |
| រស់នៅកន្លែងសម្ភាសន៍ | ៥៩,៨ | ៥៧,៤ | ៦២,៣ | ៥៩,៣ | ៥៨,០ | ៦០,៥ |
| ចំណាកស្រុក | ៤០,២ | ៤២,៦ | ៣៧,៧ | ៤០,៧ | ៤២,០ | ៣៩,៥ |
| **ជនបទ** | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ |
| រស់នៅកន្លែងសម្ភាសន៍ | ៤៩,៣ | ៤៨,៥ | ៥០,១ | ៦៤,៤ | ៦២,៩ | ៦៥,៩ |
| ចំណាកស្រុក | ៥០,៧ | ៥១,៥ | ៤៩,៩ | ៣៥,៦ | ៣៧,១ | ៣៤,១ |

**សម្គាល់ ៖** មិនរាប់បញ្ចូលទេសន្តរប្រវេសន៍ដែលលំនៅដ្ឋានពីមុនមិនបានរាយការណ៍។

ដំណាក់កាលនៃការវិភាគទិន្នន័យនៅក្នុងរបាយការណ៍នេះមិនអាចពន្យល់ពីនិន្នាការបានឡើយ។ វាតម្រូវឲ្យមានការវិភាគស៊ីជម្រៅ ដោយការពិចារណាក្នុងការបង្កើតតារាងជាមួយអថេរផ្សេងទៀតដើម្បីឲ្យកាន់តែយល់ច្បាស់អំពីស្ថានភាពនៃការធ្វើទេសន្តប្រវេសន៍។ សម្រាប់របាយការណ៍នេះមានសារៈសំខាន់ណាស់ក្នុងការបញ្ជាក់ពីចលនាទេសន្តរប្រវេសន៍ដែលមាននិន្នាការធ្លាក់ចុះនៅខេត្តឧត្តរមានជ័យ។

### តារាង ៦.២.២. ភាគរយនៃជនទេសន្តរប្រវេសន៍ តាមទីលំនៅមុន ភេទ ខេត្តឧត្តរមានជ័យ២០១៩

| កន្លែងរស់នៅពីមុន | ឆ្នាំ ២០១៩ | | |
|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី |
| (១) | (៥) | (៦) | (៧) |
| **សរុប** | ១០០,០ | ១០០,០ | ១០០,០ |
| ក្នុងខេត្តសម្ភាសន៍ | ១១,២ | ១១,៦ | ១០,៧ |
| ក្នុងខេត្តផ្សេងទៀត | ៨៧,៧ | ៨៧,២ | ៨៨,៣ |
| ក្រៅប្រទេសប្រទេស | ១,១ | ១,២ | ១,០ |
| **ទីប្រជុំជន** | ១០០,០ | ១០០,០ | ១០០,០ |
| ក្នុងខេត្តសម្ភាសន៍ | ១៣,៤ | ១៣,៦ | ១៣,២ |
| ក្នុងខេត្តផ្សេងទៀត | ៨៥,១ | ៨៤,៤ | ៨៥,៨ |
| ក្រៅប្រទេសប្រទេស | ១,៥ | ២,០ | ១,០ |
| **ជនបទ** | ១០០,០ | ១០០,០ | ១០០,០ |
| ក្នុងខេត្តសម្ភាសន៍ | ៩,៩ | ១០,៥ | ៩,២ |
| ក្នុងខេត្តផ្សេងទៀត | ៨៩,២ | ៨៨,៧ | ៨៩,៨ |
| ក្រៅប្រទេសប្រទេស | ០,៩ | ០,៨ | ១,០ |

**សម្គាល់៖** មិនរាប់បញ្ចូលទេសន្តរប្រវេសន៍ដែលលំនៅដ្ឋានពីមុនមិនបានរាយការណ៍។

យោងតាមលទ្ធផលជំរឿន ឆ្នាំ២០១៩ ចំនួនទេសន្តរប្រវេសន៍ភាគច្រើនទាំងពីរភេទមានទីលំនៅពីមុននៅក្នុងខេត្តសម្ភាសន៍ (៦២,២ ភាគរយ)។ ម្យ៉ាងទៀតចលនាទេសន្តរប្រវេសន៍ដែលកំពុងលេចធ្លោនាបច្ចុប្បន្នគឺរវាងខេត្ត និងខេត្ត

ផ្សេងទៀត។ ។ ជាក់ស្តែងនិន្នាការទេសន្តរប្រវេសន៍ពីក្នុងខេត្តទៅខេត្តផ្សេងទៀត។ និន្នាការនេះបានកើតមានក្នុងចំណោមទាំងប្រុស និងស្រី។

ដូចក្នុងករណីមុនដែរការពន្យល់និន្នាការនេះ តម្រូវឲ្យមានការវិភាគបន្ថែមទៀតដោយរួមបញ្ចូលអថេរផ្សេងទៀត។ ទោះជាយ៉ាងណាក៏ដោយវាអាចបង្ហាញសម្មតិកម្មទាក់ទងនឹងដំណើរការនៃការរីកចម្រើននៅតំបន់ទីប្រជុំជន។ សមាសធាតុទេសន្តរប្រវេសន៍នៃនគរូបនីយកម្ម តែងផ្សារភ្ជាប់ជាមួយចលនាទាក់ទងនឹងចម្ងាយឆ្ងាយ។ ចលនានេះបង្ហាញពីទម្រង់នៃការកើនឡើងទេសន្តប្រវេសន៍រវាងខេត្តមួយទៅខេត្តមួយផ្សេងទៀត ក៏ដូចជាការធ្វើទេសន្តប្រវេសន៍ពីជនបទទៅទីប្រជុំជនដែលមានចម្ងាយឆ្ងាយ ជំនួសឲ្យចលនាពីខេត្តមួយទៅខេត្តមួយផ្សេងទៀត គឺពីជនបទទៅជនបទក្នុងខេត្តតែមួយ។

## ៦.៣. មូលហេតុសម្រាប់ទេសន្តរប្រវេសន៍

ជំរឿនប្រជាជនខេត្តឧត្តរមានជ័យ ក៏បានបញ្ចូលនូវសំណួរស្តីពីមូលហេតុទាក់ទងនឹងទេសន្តរប្រវេសន៍ផងដែរ។ តារាង ៦.៣.១ បានបង្ហាញព័ត៌មានតាមជំរឿនឆ្នាំ២០១៩ ។ មូលហេតុចម្បងសម្រាប់ទេសន្តរប្រវេសន៍ផ្តល់ដោយអ្នកសម្ភាសន៍នៅក្នុងជំរឿនគឺគ្រួសារផ្លាស់ទីលំនៅ ។ មូលហេតុសម្រាប់ទេសន្តរប្រវេសន៍នេះអនុវត្តចំពោះសមាជិកគ្រួសារដែលបានផ្លាស់ទៅកន្លែងសម្ភាសន៍ពីទីលំនៅមុនដោយសារគ្រួសារទាំងមូលបានផ្លាស់ទីលំនៅ។ ឧទាហរណ៍បើសមាជិកគ្រួសារណាម្នាក់ (ជាពិសេសមេគ្រួសារ) បានធ្វើទេសន្តរប្រវេសន៍ទៅកន្លែងផ្សេងទៀត ដោយសារប្តូរទីកន្លែងការងាររបស់គាត់ មូលហេតុនៃទេសន្តរប្រវេសន៍គឺការប្តូរទីកន្លែងធ្វើការ។ សម្រាប់សមាជិកដ៏ទៃទៀតនៃគ្រួសារនេះក៏ត្រូវបានផ្លាស់ប្តូរទីលំនៅជាមួយគាត់មូលហេតុសម្រាប់ទេសន្តរប្រវេសន៍គឺគ្រួសារផ្លាស់ទីលំនៅ។ មូលហេតុដោយសារអាពាហ៍ពិពាហ៍ គឺជាករណីដូចគ្នានេះដែរ។ ទេសន្តរប្រវេសន៍ស្រីមានសមាមាត្រខ្ពស់ចំពោះមូលហេតុនេះ។ ភាគរយនៃទេសន្តរប្រវេសន៍ដោយសារមូលហេតុដ៏ទៃទៀតខ្ពស់ក្នុងចំណោមប្រុស រួមមានការប្តូរកន្លែងការងារ និងការស្វែងរកការងារ ។

### តារាង ៦.៣.១. ភាគរយបែងចែកតាមមូលហេតុសម្រាប់ជនទេសន្តរប្រវេសន៍តាមភេទ ខេត្តឧត្តរមានជ័យឆ្នាំ ២០១៩

| មូលហេតុនៃទេសន្ត ប្រវេសន៍** | ឆ្នាំ ២០១៩ | | |
|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី |
| (១) | (៥) | (៦) | (៧) |
| **សរុប** | ១០០,០ | ១០០,០ | ១០០,០ |
| ប្តូរកន្លែងធ្វើការ | ១០,២ | ១៣,៨ | ៦,២ |
| ស្វែងរកការងារ | ២២,៧ | ២៤,៣ | ២០,៩ |
| ការសិក្សា | ០,៩ | ១,០ | ០,៨ |
| រៀបអាពាហ៍ពិពាហ៍ | ៩,៦ | ១០,៥ | ៨,៧ |
| គ្រួសារផ្លាស់ទីលំនៅ | ៥១,៣ | ៤៥,៣ | ៥៧,៨ |
| មាតុភូមិនិវត្តន៍/ មកភូមិកំណើតវិញ | ១,៦ | ១,៥ | ១,៧ |
| គ្រោះធម្មជាតិ | ០,១ | ០,១ | ០,១ |
| តម្រូវឲ្យផ្លាស់ទីកន្លែង សង់ទំនប់វារីអគ្គិសនី | ០,២ | ០,២ | ០,២ |
| តម្រូវឲ្យផ្លាស់ទីកន្លែងដោយសារប៉ះគម្រោង | ០,៣ | ០,៣ | ០,៣ |
| អសន្តិសុខ | ០,៨ | ០,៧ | ១,០ |
| មាតុភូមនិវត្ត ឬមកស្រុកកំណើតវិញ | ០,៨ | ០,៨ | ០,៩ |
| កូនកំព្រា | ០,១ | ០,១ | ០,១ |
| មកលេង | ០,៩ | ០,៨ | ០,៩ |
| មូលហេតុផ្សេងទៀត | ០,៥ | ០,៥ | ០,៤ |

**សម្គាល់ ៖** ** នៅជំរឿន ២០១៩ បូកបន្ថែម តម្រូវឲ្យផ្លាស់ទីកន្លែងដោយសារសង់ទំនប់វារីអគ្គិសនី និងតម្រូវឲ្យផ្លាស់ទីកន្លែងដោយសារប៉ះគម្រោង។

## ៦.៤. ចរន្តនៃទេសន្តរប្រវេសន៍

តារាង ៦.៤.១ បង្ហាញទេសន្តរប្រវេសន៍ក្នុងស្រុកសរុបចំណាត់ថ្នាក់តាមចរន្តនៃទេសន្តរប្រវេសន៍។ យោងតាមជំរឿនឆ្នាំ២០០៨ ចរន្តទេសន្តរប្រវេសន៍ភាគច្រើនគឺពីជនបទទៅជនបទ និងទីប្រជុំជនទៅជនបទដែលជាលំដាប់ទី២។ ដោយឡែកជំរឿនឆ្នាំ២០១៩ បានឲ្យដឹងថាចរន្តទេសន្តរប្រវេសន៍ភាគច្រើនគឺនៅតែទីជនបទទៅជនបទ និងពីទីប្រជុំជនទៅជនបទដែលជាលំដាប់ទី២នៅតែជាចរន្តដ៏សំខាន់នាពេលបច្ចុប្បន្ន ។ ការប្រែប្រួលនេះលឿន និងការវិវត្តន៍ដ៏ខ្លាំងនៃការធ្វើនគរូបនីយកម្មទីប្រជុំជន។

តារាង ៦.៤.១. ភាគរយនៃជនទេសន្តរប្រវេសន៍តាមចរន្តទេសន្តរប្រវេសន៍ទីប្រជុំជន-ជនបទតាមភេទ ខេត្តឧត្តរមានជ័យឆ្នាំ២០០៨-២០១៩*

| ចរន្តទេសន្តរប្រវេសន៍ | ឆ្នាំ ២០០៨ | | | ឆ្នាំ ២០១៩ | | |
|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) |
| សរុប | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ |
| ជនបទទៅជនបទ | ៦៩,៦ | ៦៩,២ | ៧០,០ | ៥៣,០ | ៥៣,២ | ៥២,៨ |
| ជនបទទៅទីប្រជុំជន | ៤,៦ | ៤,៨ | ៤,៣ | ២៦,៤ | ២៥,៧ | ២៧,០ |
| ទីប្រជុំជនទៅជនបទ | ២២,០ | ២២,០ | ២២,១ | ១១,០ | ១១,៥ | ១០,៥ |
| ទីប្រជុំជនទៅទីប្រជុំជន | ៣,៨ | ៣,៩ | ៣,៧ | ៩,៦ | ៩,៥ | ៩,៧ |

**សម្គាល់ ៖** * មិនរាប់បញ្ចូលទេសន្តរប្រវេសន៍ក្រៅខេត្តឧត្តរមានជ័យ។

## ៦.៥. រយៈពេលស្នាក់នៅ

យោងតាមជំរឿនប្រជាជនឆ្នាំ២០១៩ ភាគច្រើននៃទេសន្តរប្រវេសន៍បានរស់នៅកន្លែងសម្នាសន៍យ៉ាងហោចណាស់១០ ឆ្នាំមុនពេលធ្វើជំរឿន(៥៤,២ ភាគរយ មើលតារាង ៦.៥.១)។ សមាមាត្រអ្នកដែលរស់នៅទីលំនៅបច្ចុប្បន្នរបស់ពួកគេពី ១-៤ ឆ្នាំ មុនពេលធ្វើជំរឿន ១៧,៤ ភាគរយ។ នៅទីប្រជុំជនទេសន្តរប្រវេសន៍មានភាគរយខ្ពស់ជាងនៅជនបទ ។ ទោះបីជាយ៉ាងណាក៏ដោយនៅជនបទមានភាគរយទាបជាងនៅតំបន់ទីប្រជុំជន (ក្នុងរង្វង់ ១៦,៩ ភាគរយ) ។

តារាង ៦.៥.១. ភាគរយជនទេសន្តរប្រវេសន៍ក្នុងស្រុក តាមរយៈពេលស្នាក់នៅ តំបន់ ខេត្តឧត្តរមានជ័យឆ្នាំ២០០៨-២០១៩*

| តំបន់ | ចំនួនទេសន្តរប្រវេសន៍ | ចំណាត់ថ្នាក់ទេសន្តរប្រវេសន៍ក្នុងស្រុកតាមរយៈពេលស្នាក់នៅ | | | | | |
|---|---|---|---|---|---|---|---|
| | | សរុប | < ១ ឆ្នាំ | ១-៤ ឆ្នាំ | ៥-៩ ឆ្នាំ | ១០-១៩ ឆ្នាំ | ២០ + ឆ្នាំ |
| (១) | (៣) | (៤) | (៥) | (៦) | (៧) | (៨) | (៩) |
| ឆ្នាំ ២០០៨ | | | | | | | |
| សរុប | ៩២.៣៤៩ | ១០០ | ១២,៧ | ៣៥,៩ | ២៩,៣ | ១៦,៨ | ៥,៣ |
| ទីប្រជុំជន | ៧.៥២០ | ១០០ | ៩,៧ | ៣២,២ | ២៣,៥ | ២៥,៦ | ៩,០ |
| ជនបទ | ៨៤.៨២៩ | ១០០ | ១២,៩ | ៣៦,២ | ២៩,៨ | ១៦,១ | ៥,០ |
| ឆ្នាំ ២០១៩ | | | | | | | |
| សរុប | ១០២.៩៧៤ | ១០០ | ៤,១ | ១៧,៤ | ២៤,៣ | ៣៩,០ | ១៥,២ |
| ទីប្រជុំជន | ៣៧.១៦០ | ១០០ | ៥,២ | ១៨,៣ | ២១,៥ | ៣៩,០ | ១៦,០ |
| ជនបទ | ៦៥.៨១៤ | ១០០ | ៣,៤ | ១៦,៩ | ២៥,៩ | ៣៩,០ | ១៤,៨ |

**សម្គាល់៖** មិនរាប់បញ្ចូលទេសន្តរប្រវេសន៍មកពីក្រៅប្រទេសខេត្តឧត្តរមានជ័យនិងអ្នកមិនបានរាយការណ៍រយៈពេលស្នាក់នៅ។

ក្នុងជំរឿនទាំងបី មានសមាមាត្រខ្ពស់នៃទេសន្តរប្រវេសន៍ក្នុងស្រុកដែលបានរាយការណ៍ថា បានរស់នៅលំនៅដ្ឋានបច្ចុប្បន្ន ១០ ឡើង។ ទោះជាយ៉ាងណាក៏ដោយ ក្នុងចំណោមទេសន្តរប្រវេសន៍ទាំងអស់បានរស់នៅលំនៅដ្ឋានបច្ចុប្បន្ន ក្នុងចន្លោះឆ្នាំ ១០-១៩ ឆ្នាំ តាមជំរឿនឆ្នាំ២០០៨ និងមិនលើសពី២០ឆ្នាំ ។ និន្នាការនេះឆ្លុះបញ្ចាំងពីការធ្វើ បម្លាស់ទីយ៉ាងច្រើនសន្ធិកសន្ទាប់នៅបន្ទាប់ពីការបញ្ចប់របបខ្មែរក្រហម ឆ្នាំ១៩៧៩។

## ៦.៦. ទេសន្តរប្រវេសន៍តាមក្រុមអាយុ

ដូចដែលបានរំពឹងទុក ប្រជាជនភាគច្រើនបានធ្វើទេសន្តរប្រវេសន៍ក្នុងអាយុធ្វើការចន្លោះពី ១៥ ទៅ ៣៩ ឆ្នាំ។ យោងតាមលទ្ធផលជំរឿនឆ្នាំ២០១៩ ជាងសែសិបប្រាំបួនភាគរយនៃទេសន្តរប្រវេសន៍ស្ថិតក្នុងក្រុមអាយុនេះទាំងប្រុស និងស្រី។ ប្រមាណជាង ៩០ ភាគរយនៃជនទេសន្តរប្រវេសន៍ស្ថិតក្នុងក្រុមអាយុ ១៥-៦៤ ឆ្នាំ ទាំងក្នុងចំណោមប្រុស និងស្រី។

តារាង ៦.៦.១. ភាគរយនៃជនទេសន្តរប្រវេសន៍អាយុ ១០ ឆ្នាំឡើង តាមក្រុមអាយុ និងភេទ ខេត្តឧត្តរមានជ័យឆ្នាំ២០០៨-២០១៩*

| ក្រុមអាយុ | ឆ្នាំ ២០០៨ | | | ឆ្នាំ ២០១៩ | | |
|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) |
| សរុប | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ |
| ១០ - ១៤ | ១២,៣ | ១២,៣ | ១២,៣ | ៧,៣ | ៧,៣ | ៧,៣ |
| ១៥ - ១៩ | ១៤,០ | ១៣,៩ | ១៤,២ | ៩,១ | ៨,៩ | ៩,៣ |
| ២០ - ២៤ | ១៣,៣ | ១៣,១ | ១៣,៥ | ៩,៥ | ៩,៧ | ៩,៤ |
| ២៥ - ២៩ | ១២,៩ | ១៣,៤ | ១២,៣ | ១១,៤ | ១១,៦ | ១១,២ |
| ៣០ - ៣៤ | ៧,៨ | ៨,១ | ៧,៦ | ១១,៨ | ១២,១ | ១១,៤ |
| ៣៥ - ៣៩ | ១០,១ | ១០,៤ | ៩,៧ | ១២,១ | ១២,៥ | ១១,៧ |
| ៤០ - ៤៤ | ៨,៦ | ៨,៦ | ៨,៦ | ៧,៧ | ៧,៧ | ៧,៧ |
| ៤៥ - ៤៩ | ៧,៩ | ៧,៨ | ៧,៩ | ៨,០ | ៧,៩ | ៨,១ |
| ៥០ - ៥៤ | ៥,៣ | ៥,២ | ៥,៥ | ៧,២ | ៧,០ | ៧,៤ |
| ៥៥ - ៥៩ | ៣,៣ | ៣,៣ | ៣,៣ | ៦,៨ | ៦,៧ | ៧,០ |
| ៦០ - ៦៤ | ១,៨ | ១,៨ | ១,៩ | ៤,២ | ៤,១ | ៤,៣ |
| ៦៥ - ៦៩ | ១,២ | ១,១ | ១,៤ | ២,៥ | ២,៤ | ២,៦ |
| ៧០ - ៧៤ | ០,៧ | ០,៦ | ០,៩ | ១,២ | ១,២ | ១,២ |
| ៧៥ + | ០,៨ | ០,៥ | ១,០ | ១,១ | ០,៩ | ១,៣ |

**សម្គាល់ ៖** * មិនរាប់បញ្ចូលចំនួនទេសន្តរប្រវេសន៍ក្រៅខេត្តឧត្តរមានជ័យ។

## ៦.៧. ទេសន្តរប្រវេសន៍តាមសកម្មភាពសេដ្ឋកិច្ច

តារាង ៦.៧.១ បានបង្ហាញថាភាគរយខ្ពស់នៃទេសន្តរប្រវេសន៍ចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចពេលគឺ ៨៩,៧ ភាគរយ ។ មានភាគរយខ្ពស់នៃទេសន្តរប្រវេសន៍ចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចនៅជនបទតែទោះជាយ៉ាងក៏ដោយភាគរយនៃទេសន្តរប្រវេសន៍ដែលនៅសល់ភាគច្រើនបានចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចនៅទីប្រជុំជន។ ពួកគេភាគច្រើនធ្វើការក្នុងផ្នែកផលិតកម្ម (២,៩ ភាគរយ) ពាណិជ្ជកម្មលក់ដុំនិងរាយ ជួសជុលរថយន្ត និងទោចក្រយានយន្ត (១៥,០ ភាគរយ) សំណង់ (៤,២ ភាគរយ) ដឹកជញ្ជូន និងឃ្លាំង (២,៥ ភាគរយ) និងសកម្មភាពរដ្ឋបាល និងសេវាកម្មគាំទ្រ (៧,៧ ភាគរយ) នៅទីប្រជុំជន។

## តារាង ៦.៧.១. ភាគរយនៃជនទេសន្តរប្រវេសន៍ក្នុងស្រុកអាយុ ៥ ឆ្នាំឡើង តាមសកម្មភាពសេដ្ឋកិច្ច ភេទ ខេត្តឧត្តរមានជ័យឆ្នាំ២០១៩*

| ប្រភេទសកម្មភាព | សរុប | ទីប្រជុំជន | ជនបទ |
|---|---|---|---|
| (១) | (២) | (៣) | (៤) |
| **សរុប** | ១០០,០ | ១០០,០ | ១០០,០ |
| **សកម្មជនសេដ្ឋកិច្ច** | ៨៩,៧ | ៨៧,៥ | ៩០,៩ |
| **អសកម្មជនសេដ្ឋកិច្ច** | ១០,៣ | ១២,៥ | ៩,១ |
| សរុប | ១០០,០ | ១០០,០ | ១០០,០ |
| កសិកម្ម ព្រៃឈើ និងនេសាទ | ៦៩,៧ | ៥៥,៩ | ៧៧,២ |
| រុករករ៉ែ និងថ្ម | ០,០ | ០,១ | ០,០ |
| ផលិតកម្ម | ២,២ | ២,៩ | ១,៨ |
| អគ្គិសនី ឧស្ម័ន ចំហាយទឹកនិងការផ្គត់ផ្គង់ម៉ាស៊ីនត្រជាក់ | ០,១ | ០,១ | ០,០ |
| ការផ្គត់ផ្គង់ទឹក លូទឹក ការគ្រប់គ្រងសំរាម និងសកម្មភាពបង្ការ | ០,១ | ០,២ | ០,០ |
| សំណង់ | ២,៣ | ៤,២ | ១,៣ |
| ពាណិជ្ជកម្មលក់ដុំនិងរាយ ជួសជុលរថយន្ត និងទោចក្រយានយន្ត | ៩,៥ | ១៥,០ | ៦,៤ |
| ដឹកជញ្ជូន និងឃ្លាំង | ១,៣ | ២,៥ | ០,៦ |
| សកម្មភាពសេវាកម្មទីស្នាក់អាស្រ័យនិងម្ហូបអាហារ | ១,០ | ១,៩ | ០,៥ |
| ព័ត៌មាន និងគមនាគមន៍ | ០,១ | ០,៣ | ០,០ |
| សកម្មភាពហិរញ្ញវត្ថុ និងធានារ៉ាប់រង | ០,៤ | ០,៧ | ០,២ |
| អចលនទ្រព្យ | ០,២ | ០,៤ | ០,១ |
| សកម្មភាពវិជ្ជាជីវៈវិទ្យាសាស្ត្រ និងបច្ចេកទេស | ០,៦ | ១,០ | ០,៣ |
| សកម្មភាពរដ្ឋបាល និងសេវាកម្មគាំទ្រ | ៨,៥ | ៧,៧ | ៨,៩ |
| រដ្ឋបាលសាធារណៈ និងការការពារសន្តិសុខសង្គម | ១,៤ | ១,៦ | ១,៣ |
| ការសិក្សាអប់រំ | ០,៥ | ០,៦ | ០,៤ |
| សកម្មភាពសុខាភិបាល និងការងារសង្គម | ១,៣ | ៣,២ | ០,២ |
| សិល្បៈ ការកំសាន្ត និងការសប្បាយ | ១,០ | ១,៧ | ០,៧ |
| សកម្មភាពសេវាកម្មដទៃទៀត | ០,០ | ០,០ | ០,០ |
| សកម្មភាពប្រើប្រាស់គ្រួសារជានិយោជក | ០,០ | ០,០ | ០,០ |
| សកម្មភាពអង្គការ និងអង្គការក្រៅបរទេស | ០,០ | ០,០ | ០,០ |

**សម្គាល់៖** មិនរាប់បញ្ចូលទេសន្តរប្រវេសន៍មកពីក្រៅប្រទេសកម្ពុជា និងអ្នកមិនបានរាយការណ៍សកម្មភាពសេដ្ឋកិច្ច។

# ជំពូក ៧
# លទ្ធភាពបង្កើតកូន

## ៧.១. ទស្សនទាន

ទិន្នន័យលទ្ធភាពបង្កើតកូនបច្ចុប្បន្នច្រើនតែប្រមូលដោយប្រព័ន្ធអត្រានុកូលដ្ឋាន តាមរយៈការចុះបញ្ជីកំណើត។ បើទិន្នន័យប្រភេទនេះមិនត្រូវបានប្រមូល ឬប្រមូលមិនពេញលេញដូចក្នុងករណីខេត្តឧត្តរមានជ័យ នោះជំរឿនជាប្រភពតែមួយគត់សម្រាប់ការគណនាលទ្ធភាពបង្កើតកូន។ ជំរឿនឆ្នាំ២០១៩ ក៏ដូចជាជំរឿនឆ្នាំ២០០៨ និងឆ្នាំ១៩៩៨ បានបញ្ចូលផ្នែកមួយដែលអាចគណនាលទ្ធភាពបង្កើតកូននាពេលបច្ចុប្បន្នបាន គឺចំនួនកូនដែលស្ត្រីបង្កើតក្នុងរយៈពេល ១២ ខែមុនពេលធ្វើជំរឿនតាមក្រុមអាយុស្ត្រី។ ពីសំណួរនេះអាចគណនាអត្រាលទ្ធភាពបង្កើតកូនតាមអាយុជាក់លាក់ (ASFR) និង អត្រាលទ្ធភាពបង្កើតកូនសរុប (TFR)។

អត្រាលទ្ធភាពបង្កើតកូនតាមអាយុជាក់លាក់ (ASFR) និងអត្រាលទ្ធភាពបង្កើតកូនសរុប (TFR) មិនទទួលរងផលប៉ះពាល់ដោយសមាសភាពអាយុរបស់ប្រជាជនឡើយ ប៉ុន្តែវាមានបញ្ហាផ្សេងទៀត ជាសំខាន់គឺការរាប់មិនអស់។ ដូចបានរៀបរាប់ខាងលើ វិធីសាស្ត្រគណនា ASFR និង TFR បានប្រើចំនួនកំណើតដែលស្ត្រីបានបង្កើតក្នុងរយៈពេល ១២ ខែមុនពេលធ្វើជំរឿន។ កាលណាបង្កើតតារាងតាមក្រុមអាយុប្រាំឆ្នាំរបស់ស្ត្រី ព័ត៌មាននេះអាចផ្តល់ការវាស់វែងដោយផ្ទាល់សម្រាប់អត្រាលទ្ធភាពបង្កើតកូនតាមអាយុជាក់លាក់ (ASFR) និងអត្រាលទ្ធភាពបង្កើតកូនសរុប (TFR)។ ទោះជាយ៉ាងណាក៏ដោយ អត្រានេះតែងប៉ាន់ស្មានស្ទើរ ដោយសាររាប់មិនអស់នូវចំនួនកូននៅពេលសម្ភាសន៍ ដោយប្រើសំណួរពីជំរឿន (អំពីចំនួនកូនដែលបានកើតរបស់ស្ត្រី) មានកម្រិតទាបជាងការប៉ាន់ស្មានដែលត្រូវការកែតម្រូវមួយសមស្រប។

## ៧.២. ការប៉ាន់ស្មានលទ្ធភាពបង្កើតកូន

វិធីសាស្ត្រគណនាលទ្ធភាពបង្កើតកូនដោយប្រយោលត្រូវបានអនុវត្តសម្រាប់កែសម្រួលការប្រមូលទិន្នន័យមិនបានពេញលេញ ឬរាប់មិនអស់។ ដូចបានរៀបរាប់ខាងដើម William Brass បានបង្កើតវិធីសាស្ត្រគណនាដោយប្រយោល ដើម្បីកាត់បន្ថយភាពខ្វះខាតនេះ។ អ្នកប្រជាសាស្ត្រផ្សេងទៀតបន្ទាប់ពីគាត់ បានកែលម្អវិធីសាស្ត្រគណនានេះ ក្នុងនោះមាន Eduardo Arriaga ដែលវិធីសាស្ត្រគណនានេះត្រូវបានប្រើប្រាស់សម្រាប់ជំរឿននៅខេត្តឧត្តរមានជ័យ (មើលតារាង ៧.២.១)[1]។

[1] E. Arriaga និង Associates. 1994. PAS – ការវិភាគប្រជាសាស្ត្រជាមួយ Microcomputers, U. S ការិយាល័យជំរឿនសហរដ្ឋអាមេរិក, D.C., USA។

### តារាង ៧.២.១. ប៉ានស្មានអត្រាលទ្ធភាពបង្កើតកូនតាមអាយុជាក់លាក់ និងអត្រាលទ្ធភាពបង្កើតកូនសរុប តាមតំបន់ ខេត្តឧត្តរមានជ័យ ឆ្នាំ២០១៩

| អត្រាលទ្ធភាពបង្កើតកូនតាមអាយុជាក់លាក់ | សរុប | ទីប្រជុំជន | ជនបទ |
|---|---|---|---|
| (១) | (២) | (៣) | (៤) |
| ១៥ - ១៩ | ០,០៥១៧០៤ | ០,០៤៣៣៧៤ | ០,០៥៦១៥៨ |
| ២០ - ២៤ | ០,១៥១២៨២ | ០,១៤៦៥៥៣ | ០,១៥៣៥២៣ |
| ២៥ - ២៩ | ០,១៥៦០៨៤ | ០,១៥៩៤៨១ | ០,១៥៤១២៦ |
| ៣០ - ៣៤ | ០,១១៤៦៥៨ | ០,១២៨៩១៤ | ០,១០៧២៤ |
| ៣៥ - ៣៩ | ០,០៦៩៥១៩ | ០,០៧៣០២៩ | ០,០៦៧៣៦១ |
| ៤០ - ៤៤ | ០,០២៨១៤១ | ០,០៣៩៦៣១ | ០,០២២២០៩ |
| ៤៥ - ៤៩ | ០,០០៩២០៥ | ០,០០៧១៧៨ | ០,០១០៣៧ |
| អត្រាលទ្ធភាពបង្កើតកូនសរុប | ២,៩ | ៣,០ | ២,៩ |

យោងតាមតារាង ៧.២.១ អត្រាលទ្ធភាពបង្កើតកូនសរុប (TFR) នៅខេត្តឧត្តរមានជ័យមាន ២,៩ សម្រាប់ស្ត្រីម្នាក់ក្នុងកាលបរិច្ឆេទយោងជំរឿនថ្ងៃទី ៣ ខែមីនា ឆ្នាំ២០១៩ និងរយៈពេល ១២ ខែមុនពេលធ្វើជំរឿន ថ្ងៃទី ៣ ខែមីនា ឆ្នាំ២០១៨ ដល់ ២ ខែមីនា ឆ្នាំ២០១៩។ តម្លៃនេះយោងតាមពេលវេលាជាក់លាក់ថ្ងៃទី ៣ ខែសីហា ឆ្នាំ២០១៩ ។

តារាង ៧.២.១ ក៏បង្ហាញផងដែរអំពីភាពខុសគ្នារវាងអត្រាលទ្ធភាពបង្កើតកូនសរុបរវាងតំបន់ទីប្រជុំជន និងជនបទ។ ជាទូទៅអត្រាលទ្ធភាពបង្កើតកូននៅប្រទេសខេត្តឧត្តរមានជ័យគឺទាបនៅទីប្រជុំជននិងជនបទ។ អត្រាលទ្ធភាពបង្កើតកូនសរុបខុសគ្នាតិចតួចគឺ ៣,០ ទល់នឹង ២,៩ សម្រាប់ស្ត្រីម្នាក់។ ជាទូទៅការខុសគ្នាមានកូនម្នាក់ ឬច្រើនជាង

ការវាស់វែងនេះត្រូវគ្នាជាមួយអត្រាលទ្ធភាពបង្កើតកូនតាមអាយុជាក់លាក់ (ASFR) និងអត្រាលទ្ធភាពបង្កើតកូនសរុប (TFR) ក្នុងកម្រិតលទ្ធភាពបង្កើតកូនដែលពួកគេបានបញ្ជាក់។ លទ្ធភាពបង្កើតកូនទាបមានអត្រខុសគ្នាតិចតួចរវាងតំបន់ទីប្រជុំជន និងជនបទ។ គួរចងចាំថាគ្រប់ការវាស់វែងទាំងអស់បានត្រូវនឹងថ្ងៃទី ៣ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី ២ ខែមីនា ឆ្នាំ២០១៨ ឬពិតប្រាកដថ្ងៃទី ៣ ខែសីហា ឆ្នាំ២០១៨។

រូប ៧.២.១ បង្ហាញពីអត្រាលទ្ធភាពបង្កើតកូនតាមអាយុជាក់លាក់ ASFR (កែតម្រូវ) សម្រាប់ជំរឿនឆ្នាំ ២០០៨ និងឆ្នាំ២០១៩។ រូបខ្សែកោងបង្ហាញថា អត្រាលទ្ធភាពបង្កើតកូនកើនឡើងជាមួយអាយុ ទៅដល់ចំណុចកំពូលនៅក្នុងក្រុមអាយុ ២៥-២៩ ឆ្នាំ ហើយបន្ទាប់មកថយចុះវិញ។ ខ្សែកោងបង្ហាញសមាមាត្រមធ្យមនៃស្ត្រីមានកូននៅវ័យក្មេងពេកឬចាស់ពេក។ ឧទាហរណ៍ អត្រាលទ្ធភាពបង្កើតកូនយុវវ័យមាន ៣២ កំណើតក្នុងចំណោម ១.០០០ នាក់។ ទោះបីអត្រាទាប កិច្ចខិតខំប្រឹងប្រែងគួរតែត្រូវធ្វើដើម្បីកាត់បន្ថយ នូវភាពអវិជ្ជមានដល់បុគ្គល និងផលវិបាកជាអវិជ្ជមានដល់សង្គមចំពោះការមានកូនរបស់យុវវ័យ។ ជាងនេះទៀត ស្ត្រី ១.០០០ នាក់ ដែលកំពុងបញ្ចប់ជីវិតបន្តពូជរបស់ពួកគេ (៤៥-៤៩ ឆ្នាំ) មានកូន ១០ នាក់ជាមធ្យម។

រូប ៧.២.១. អត្រាលទ្ធភាពបង្កើតកូន តាមអាយុជាក់លាក់ ខេត្តឧត្តរមានជ័យ ឆ្នាំ២០០៨-២០១៩



# ជំពូក ៨
# មរណភាព

## ៨.១. ទស្សនទាន

មរណភាពសំដៅលើការស្លាប់ដែលកើតឡើងក្នុងចំណោមប្រជាជន។ ប្រូបាប៊ីលីតេនៃការស្លាប់ក្នុងអំឡុងពេលណាមួយទទួលរងដោយឥទ្ធិពលកត្តាជាច្រើនដូចជាអាយុ ភេទ ការអប់រំ និងស្ថានភាពសេដ្ឋកិច្ច។ អត្រាមរណភាពឆ្លុះបញ្ចាំងយ៉ាងច្បាស់អំពីកម្រិតជីវភាពរស់នៅ និងសេវាសុខភាពរបស់ប្រជាជននៃប្រទេសមួយ។

ជាក់ស្តែងកត្តាកំណត់សំខាន់បំផុតនៃមរណភាពគឺអាយុ ។ ជាពិសេសសារៈសំខាន់នៃអត្រាមរណភាពកុមារក្រោមអាយុ ៥ ឆ្នាំ។ សូចនាករមរណភាពមានបីប្រភេទគឺៈ អត្រាមរណភាពទារកជាចំនួនមរណភាពរបស់ទារកដែលមានអាយុក្រោម ១ ឆ្នាំក្នុងចំនួនកំណើតរស់ ១.០០០ នាក់ក្នុងឆ្នាំណាមួយ។ អត្រាមរណភាពរបស់កុមារជាចំនួនមរណភាពរបស់កុមារដែលមានអាយុពី ១ ទៅ ៤ ឆ្នាំក្នុងចំណោមកុមារ ១.០០០ នាក់។ ហើយអត្រាមរណភាពកុមារអាយុក្រោម៥ ឆ្នាំ គឺប្រូបាប៊ីលីតេនៃការស្លាប់ពីកំណើតរហូតដល់អាយុ ៥ ឆ្នាំ។

ប្រទេសជាច្រើន ក្នុងនោះមានខេត្តឧត្តរមានជ័យផងដែរខ្វះការស្រង់ទិន្នន័យដោយប្រព័ន្ធនៃការចុះបញ្ជីអត្រានុកូលដ្ឋាន ដូច្នេះការគណនាមរណភាពគឺពឹងអាស្រ័យទាំងស្រុងលើទិន្នន័យដែលប្រមូលតាមរយៈការធ្វើជំរឿន និងអង្កេតប្រជាសាស្ត្រ មួយចំនួន។ ប៉ុន្តែប្រភពទាំងនេះមិនបានផ្តល់នូវការគណនាមរណភាពត្រឹមត្រូវនោះទេ។ ដើម្បីទទួលបានការគណនាត្រឹមត្រូវតាមនិយាមអន្តរជាតិក្នុងការប្រើប្រាស់មានវិធីសាស្ត្រជាច្រើនក្នុងការគណនានោះ គឺវិធីសាស្ត្រគណនាដោយប្រយោល។ វិធីសាស្ត្រគណនានេះរៀបចំអភិវឌ្ឍន៍ ដោយ William Brass ក្នុងអំឡុងឆ្នាំ ១៩៧០ សម្រាប់សិក្សាអំពីប្រជាសាស្ត្រនៅតំបន់សាហារ៉ាអាហ្វ្រិក។ ផ្អែកតាមការសិក្សានេះ អ្នកប្រជាសាស្ត្រជាច្រើនបានធ្វើការកែលម្អវិធីសាស្ត្រគណនាថ្មីៗដែលអាចគណនាមរណភាពមនុស្សពេញវ័យ និងតារាងវដ្តជីវិត ។

គោលបំណងនៃជំពូកនេះគឺដើម្បីប៉ាន់ស្មានការគណនាមរណភាពទារក កុមារ និងកុមារអាយុក្រោម ៥ ឆ្នាំ ដោយរាប់បញ្ចូលការគណនាមនុស្សពេញវ័យ(តាមរយៈតារាងវដ្តជីវិត) និងមរណភាពមាតាផងដែរ។ វិធីសាស្ត្រគណនា ដោយប្រយោលត្រូវបានប្រើប្រាស់សម្រាប់ការគណនានេះ ។

## ៨.២. មរណភាពទារក កុមារ និងកុមារអាយុក្រោម ៥ឆ្នាំ

មរណភាពនៅអាយុបឋម គឺត្រូវបានវាស់វែងពីសំណួរចំនួនពីរដែលស្រង់ពីជំរឿនគឺៈចំនួនកូនដែលបានកើតលើស្ត្រី និងចំនួនកូនដែលនៅរស់បែងចែកតាមក្រុមអាយុស្ត្រី។ ប្រើបច្ចេកទេសវ័យឆ្លាតទំនើបប្រជាសាស្ត្រ (វិធីសាស្ត្រគណនាដោយប្រយោល) អាចផ្តល់នូវទិន្នន័យដែលអាចជឿជាក់បានសម្រាប់អត្រាមរណភាពទារក និអត្រាមរណកុមារ(ឬប្រូបាប៊ីលីតេស្លាប់)។ វិធីសាស្ត្រចម្បងដើមដែលរៀបចំអភិវឌ្ឍន៍ដោយអ្នកប្រជាសាស្ត្រជនជាតិអង់គ្លេសលោក William Brass។ មានគម្លាតជាច្រើនត្រូវបានស្នើឡើង(Moultrie et al.,2013) ។ វិធីសាស្ត្រដើមរបស់ Brass (វិធី

សាស្ត្រកែសម្រួល) ត្រូវបានប្រើប្រាស់។ ភាគច្រើននៃវិធីសាស្ត្រគណនាមរណភាព គឺប្រើប្រាស់តារាងវដ្តជីវិត ។ មានវិធីសាស្ត្រចម្បងពីរត្រូវបានស្នើឡើងគឺ បច្ចេកទេសអភិវឌ្ឍន៍ដោយ Coale-Demeny តាមតំបន់លំនាំតារាងវត្តន៍ជីវិត (ខាងលិច ខាងជើង ខាងកើត និងខាងត្បូង) និងតារាងវដ្តជីវិតអង្គការសហប្រជាជាតិសម្រាប់ ប្រទេសកំពុងអភិវឌ្ឍន៍ដូចជា (អាមេរិកឡាទីន ឈីលី អាស៊ីខាងត្បូង មជ្ឈឹមបូព៌ា និងទូទៅ ) 1F2។

ករណីខេត្តឧត្តរមានជ័យតារាងវដ្តជីវិតដែលសមស្របបំផុតគឺសម្រាប់គណនាតាមលំនាំភាគខាងជើង ។ ទាំងនេះត្រូវបានកំណត់ ដោយប្រើលំនាំដែលបង្ហាញនៅក្នុងសៀវភៅសិក្សាសម្រង់ខាងក្រោមតារាងយោងទី៣ខាងក្រោមទំព័រ ។

តារាង ៨.២.១ បង្ហាញពីអត្រាមរណភាពទារក កុមារ និងកុមារអាយុក្រោម ៥ ឆ្នាំដែលបានប៉ាន់ស្មានពីទិន្នន័យជំរឿនឆ្នាំ២០១៩ ។ ជាទូទៅ អត្រាមរណភាពមានខ្ពស់នៅក្នុងចំណោមប្រុសជាងស្រីជាពិសេសមរណភាពទារក។ ទម្រង់នេះបានកំណត់ដោយកត្តាជីវសាស្ត្រ។ ផ្ទុយទៅវិញអត្រាមរណភាពកុមារ ជាទូទៅស្រីមានអត្រាខ្ពស់ជាពិសេសនៅបណ្តាប្រទេសដែលមានទំនោរលើភេទ(ទំនោរកូនប្រុស)។ ករណីខេត្តឧត្តរមានជ័យអត្រាទាំងពីរមានប្រហាក់ប្រហែល គ្មានបញ្ជាក់ថាមានទំនោរការចង់បានកូនប្រុស បើក្នុងករណីមានពិតនោះមិនមានផលប៉ះពាល់លើការរស់រានរបស់កុមារទេ។

**តារាង ៨.២.១ អត្រាមរណភាពអាយុបឋម និងអាយុសង្ឃឹមរស់ តាមភេទ និងតំបន់ ខេត្តឧត្តរមានជ័យឆ្នាំ ២០១៩**

| តំបន់ | មរណភាព ទារក | មរណភាព កុមារអាយុ ក្រោម ៥ឆ្នាំ | អាយុសង្ឃឹមរស់ | ពេលវេលា យោង |
|---|---|---|---|---|
| (១) | (២) | (៣) | (៤) | (៥) |
| **ទាំងពីរភេទ** | ១៨,៩ | ៣០,២ | ៧៣,៧ | ២០១៦.៨ |
| **ទីប្រជុំជន** | ២១,៨ | ៣៤,៨ | ៧៤,៣ | ២០១៦.៨ |
| **ជនបទ** | ១៧,៤ | ២៧,៨ | ៧២,៦ | ២០១៦.៨ |
| ប្រុស | ២០,៥ | ៣២,៧ | ៧៣,១ | ២០១៦.៨ |
| ស្រី | ១៧,២ | ២៧,៥ | ៧៥,៨ | ២០១៦.៨ |

អនុលោមតាមតារាង ៨.២.១ និងដូចដែលបានសង្ឃឹមទុកអត្រា មរណភាពនៅជនបទមាន អត្រាខ្ពស់ជាងតំបន់ទីប្រជុំជនស្ទើរតែគ្រប់ប្រទេស។ មានកត្តាជាច្រើនដែល បានបកស្រាយអំពីភាពផ្សេងគ្នា នៃអត្រាមរណភាពក្នុង

[2] Model life tables are sets of life tables based on the generalization of empirical relationships derived from a group of observed life tables. The Coale-Demeny Regional Model Life Tables and the United Nations Life Tables for Developing Countries are the two main systems of model life tables. These systems are based on empirical life tables that have been developed on the principle of narrowing the selection of a life table to those considered realistic on the basis of examination of mortality levels and patterns calculated for actual populations. These systems cover a wide variety of mortality experiences, so that one may be more appropriate than other for a particular country. Each system has *families* of life tables. The families in the Coale-Demeny system are: East, West, North and South and the families in the United Nations system are: Latin American, Chilean, South Asian, Far East and General (United Nations, 1983).

កម្រិតសិក្សាអប់រំរបស់ឪពុកម្តាយ ការទទួលបានសេវាសុខាភិបាល ការអនុវត្តអនាម័យជាដើម។ ទោះជាយ៉ាងណាក៏ដោយភាពខុសគ្នានៅទីប្រជុំជន និងជនបទនៅខេត្តឧត្តរមានជ័យ ដែលបង្ហាញក្នុងតារាង ៨.២.១ មានតិចតួច។ នេះអាចបញ្ជាក់បានថាគោលនយោបាយពង្រីកការទទួលបានសេវាសុខភាពមានភាពទូលំទូលាយ និងគ្រប់គ្រាន់។ ចំនុចនេះគួរត្រូវបានចាត់ទុកជាកត្តាសំខាន់ដើម្បីសិក្សា បញ្ហានេះឱ្យបានទូលំទូលាយនិងគ្រប់ជ្រុងជ្រោយ ។

តារាង ៨.២.១ បង្ហាញផងដែរអំពីអាយុកំណើតសង្ឃឹមរស់ដែលជាសូចនាករសំខាន់នៃមរណភាពទូទៅ ប៉ុន្តែវាទទួលរងឥទ្ធិពលខ្លាំងពីមរណភាពទារក។ ការបកស្រាយលម្អិតនឹងពិភាក្សាក្នុងផ្នែកបន្ទាប់ ។

## ៨.៣. មរណភាពមាតា

ក្នុងអំឡុងបីទសវត្សន៍ចុងក្រោយ អត្រាមរណភាពមាតាមានអត្រាខ្ពស់ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ត្រូវបានទទួលស្គាល់កាន់តែខ្លាំងឡើងថាជាបញ្ហាប្រឈមក្នុងវិស័យសុខភាពសាធារណៈ។ ការពិតគួរឱ្យចាប់អារម្មណ៍នោះគឺផលធៀបនៃមរណភាពមាតា (កំណត់ដោយចំនួនមរណភាពមាតាក្នុងកំឡុងពេលផ្តល់ ១០០.០០០ កំណើតរស់នៅក្នុងអំឡុងពេលដូចគ្នា) នៅប្រទេសកំពុងអភិវឌ្ឍន៍ផលធៀបនេះ គឺមានចំនួនច្រើនជាង ១០០ ដងធៀបនឹងប្រទេសអភិវឌ្ឍន៍។ មរណភាពមាតាត្រូវបានកំណត់ជាសូចនាករ សុខភាពដែលមានភាពខុស គ្នាខ្លាំងរវាងប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអភិវឌ្ឍន៍។ ការស្លាប់របស់មាតាក្នុងអំឡុងពេលមានគ៌ភ គឺជាសូចនាករបញ្ជាក់ពីគុណភាពសេវាសុខភាព។ បញ្ហាចម្បងភាគច្រើននៃមរណភាពមាតាគឺអាចបង្កាបាន។ បន្ថែមលើសពីនេះទៀតមរណភាពមាតា គឺជាសោកនាដកម្មមួយក្នុងចំណោមសោកនាដកម្មធំបំផុតដែលអាចកើតមាននៅក្នុងគ្រួសារ ដែលអាចបង្កជាផលវិបាកជាយ៉ាងធំធេងសម្រាប់កុមារកំព្រា ប្តី/ប្រពន្ធនិងសមាជិកគ្រួសារដ៏ទៃទៀត និងសង្គមជាតិផងដែរ។

បញ្ហាមរណភាពមាតាត្រូវបានលើកយកមកពិភាក្សានៅសន្និសិទ្ធជាច្រើននិងជាបញ្ហាថ្មីៗដែលមានសារសំខាន់ជាផ្នែកមួយនៃគោលដៅ SDG ដែលបានរៀបរាប់ខាងលើ។ ចំណុចដៅចំនួន ៦ ដែលទាក់ទងនឹងមរណភាពមាតាដែលមានក្នុងគោលដៅទី ៣ នៅក្នុងរបៀបវៀរៈឆ្នាំ ២០៣០ នោះគឺ កាត់បន្ថយជាសកលនូវផលធៀបមរណមាតាឲ្យបានទាបជាង ៧០ ក្នុង ១០០.០០០ កំណើតរស់ ។

មានវិធីសាស្ត្រជាច្រើនដើម្បីគណនាមរណមាតា ប៉ុន្តែដែលសមស្រប និងជឿជាក់បំផុតនោះគឺផ្អែកលើសំណួរដោយផ្ទាល់ដែលដាក់បញ្ចូលក្នុងជំរឿនពីសេសក្នុងផ្នែកមរណភាពមនុស្សពេញវ័យ។ សម្រាប់ស្ត្រីក្នុងអាយុ ១៥-៤៩ ដែលបានស្លាប់ក្នុងអំឡុងពេល ១២ ខែមុនពេលធ្វើជំរឿន ត្រូវបានសួរថាតើស្ត្រីនោះបានស្លាប់ក្នុងពេលមានគ៌ភ ឬពេលសម្រាលកូន ឬ ៤២ ថ្ងៃក្រោយពេលសម្រាលកូន។ ជួនកាលសំណួរ អាចរាប់បញ្ចូលតើស្ត្រីនោះស្លាប់នៅកន្លែងណា (មន្ទីរពេទ្យ មណ្ឌលសុខភាព នៅផ្ទះ) ហើយមាននរណាម្នាក់ជួយនាងពេលមុនពេលស្លាប់ដែរឬទេ (វេជ្ជបណ្ឌិត គ្រូពេទ្យ ឆ្មបឯកទេស ឆ្មបបុរាណ) ។

ជាទូទៅ ករណីមរណមនុស្សពេញវ័យ ត្រូវបានស្រង់រាប់មិនអស់ទៅតាមការរំពឹងទុកឡើយ។ មានវិធីសាស្ត្រជាច្រើនត្រូវបានកែតម្រូវលើទិន្នន័យដើម្បីទទួលបានភាពប្រសើរ។ ករណីនេះការគណនាមានការលំបាក និងកម្រិតជឿជាក់ទាប ។

ការលើកឡើងខាងលើនូវបណ្តាសំណួរ រាប់បញ្ចូលក្នុងចំណោមចំនួនសមាជិកគ្រួសារដែលបានស្លាប់ក្នុងរយៈពេល ១២ កន្លងមក។ ដូចដែលបានពន្យល់ខាងដើមព័ត៌មាននេះត្រូវបានស្រង់សម្ភាសន៍ មិនអស់នូវចំនួនអ្នកស្លាប់ដោយរាប់បញ្ចូលទាំងអ្នកស្លាប់ដែលចាត់ទុជាមរណភាពមាតាផងដែរ ។

មរណៈមាតាជាករណីកើតឡើងដោយកម្រដូច្នេះការគណនាកម្រិតក្រោមជាតិមិនអាចធ្វើទៅបានដូចនេះការគណនាធ្វើបាននៅតែកម្រិតប្រទេសប៉ុណ្ណោះ។ យោងតាមជំរឿនឆ្នាំ២០១៩ ទិន្នន័យគណនាដោយផ្ទាល់ (មិនមានការកែតម្រូវ) ត្រូវបានគណនាឃើញផលធៀប ឬអត្រាមរណភាពមាតាមាន ១៤០,៨ ក្នុងចំណោម ១០០.០០០ កំណើតរស់ ។ សូចនាករនេះហាក់បង្ហាញពីការរាប់សម្គាសន៍មិនអស់នូវចំនួនមរណភាពមាតា។ ទោះជាយ៉ាងណាក៏ដោយការកែតម្រូវត្រូវបានធ្វើឡើងដើម្បីវាយតម្លៃគុណភាពនៃការធ្វើចំណាត់ថ្នាក់ការស្លាប់របស់មាតាក្នុងករណីអវត្តមាននៃវិធីសាស្ត្រផ្លូវការ។ ក្នុងករណីនេះជាទូទៅមិនផ្ដល់អនុសាសន៍សម្រាប់ធ្វើការកែតម្រូវមរណភាពតាមក្រុមអាយុឡើយ ។ មានការស៊ើសង្វាក់នៅក្នុងការវាយតម្លៃមរណភាពមាតា តម្រូវឲ្យមានការវិភាគជាពិសេសជាងការរកឃើញបឋមនេះ។ ករណីមរណភាពមាតានឹងត្រូវបានវិភាគស៊ីជម្រៅ ក្នុងរបាយការណ៍វិភាគស៊ីជម្រៅដែលគ្រោងធ្វើ។ ទោះបីយ៉ាងណាមិនមានការកែតម្រូវ ឬកែសម្រួលទៅលើការគណនាអត្រាមរណភាពមាតាឡើយ ហើយអត្រានេះមានទាបជាងក្នុងឆ្នាំ២០០៨ ដែលបានរកឃើញកាលនោះមាន ៤៦០,៨ ក្នុង ១០០.០០០កំណើតរស់ ។

### រូបភាព ៨.៤.១. អត្រាមរណភាពមាតា ខេត្តឧត្តរមានជ័យឆ្នាំ ២០០៨ ២០១៤ និង ២០១៩



# ជំពូក ៩
# ពិការភាព

## ៩.១. ទស្សនទាន

ទិន្នន័យអំពីពិការភាពទាំងប្រាំមួយប្រភេទ ដែលបានប្រមូលក្នុងជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ មានដូចខាងក្រោម៖

(១) ពិការភាពក្នុងការមើល (ភ្នែក)៖ មនុស្សម្នាក់ដែលមានពិការភាពក្នុងការមើលក្នុងកម្រិតណាមួយ បើទោះបីជាប្រើវ៉ែនតាក៏ដោយ ហើយនៅតែមិនអាចមើលអ្វីឃើញ ឬភ្នែកងងឹត ឬ មិនអាចមើលឃើញអ្វីទាំងអស់ (សូម្បីតែពន្លឺ) ត្រូវបានចាត់ទុកថា អសមត្ថភាពក្នុងការមើល ឬពិការភ្នែក។ មនុស្សម្នាក់ដែលមើលច្បាស់តែភ្នែកម្ខាង ឬ មើលឃើញតែចំពោះមុខក៏ត្រូវបានចាត់ទុកថាពិការភាពក្នុងការមើលផងដែរ។ មនុស្សម្នាក់មានបញ្ហានៅក្នុងការមើលជិតឬឆ្ងាយ ប៉ុន្តែអាចមើលបានច្បាស់ដោយពាក់វ៉ែនតា គឺមិនត្រូវបានចាត់ទុកថាពិការភាពក្នុងការមើលនោះទេ។

(២) ពិការភាពក្នុងការស្តាប់ឮ (ថ្លង់)៖ មនុស្សម្នាក់ដែលមានកម្រិតណាមួយក្នុងការស្តាប់ឮ ទោះបីជាប្រើឧបករណ៍ជំនួយការស្តាប់ក៏ដោយ ត្រូវបានចាត់ទុកថា អសមត្ថភាពក្នុងការស្តាប់ឮ ឬពិការភាពក្នុងការស្តាប់ឮ។ ពិការភាពប្រភេទនេះ រួមទាំងមនុស្សម្នាក់ដែលស្តាប់អ្វីមិនឮទាំងអស់ ឬអាចឮតែសម្លេងខ្លាំងតែប៉ុណ្ណោះ ឬអាចស្តាប់ឮនៅពេលដែលពួកគេស្ថិតនៅក្នុងបរិយាកាសដែលមានសំឡេងអឺងកងមួយ ឬពួកគេមានបញ្ហាក្នុងការសម្គាល់សំឡេងចេញពីប្រភពផ្សេងៗ។ លើសពីនេះទៀត មនុស្សម្នាក់ដែលស្តាប់ឮតាមរយៈ ត្រចៀកម្ខាង ប៉ុន្តែត្រចៀកម្ខាងទៀតរបស់គាត់ស្តាប់មិនឮ ក៏ត្រូវចាត់ទុកថាពិការភាពក្នុងការស្តាប់ឮផងដែរ។ មនុស្សម្នាក់ដែលអាចស្តាប់ឮដោយឧបករណ៍ជំនួយការស្តាប់ មិនត្រូវបានចាត់ទុកថា អសមត្ថភាពក្នុងការស្តាប់ឮនោះទេ។

(៣) ពិការភាពក្នុងការដើរ ឬឡើងជណ្តើរ ៖ មនុស្សម្នាក់មានការលំបាក ទោះក្នុងកម្រិតណាមួយនៅពេលធ្វើចលនាក្នុងបរិស្ថានជុំវិញខ្លួនដោយប្រើជើងត្រូវបានចាត់ទុកថា ពិការភាព។ ពិការភាពប្រភេទនេះរួមទាំង មនុស្សម្នាក់ដែលមានបញ្ហាខ្លះក្នុងការដើរជិតឬឆ្ងាយ ឬឡើង ឬចុះជណ្តើរ មនុស្សម្នាក់ដែលមិនអាចដើរចំងាយណាមួយ ដោយគ្មានឈប់សម្រាក ហើយពួកគេមិនអាចដើរបានដោយគ្មានឧបករណ៍ជំនួយក្នុងការដើរដូចជា ដំបងឈើច្រត់ ឈើធ្នាប។ លើសពីនេះ មនុស្សម្នាក់ដែលមិនអាចឈរបានយូរជាងមួយឬពីរនាទី ឬត្រូវការកៅអីកង់ដើម្បីផ្លាស់ទីពីកន្លែងមួយទៅកន្លែង ក៏ត្រូវបានគេចាត់ទុកថាស្ថិតនៅក្នុង ពិការភាពប្រភេទនេះផងដែរ។

(៤) ពិការភាពក្នុងការចងចាំ ឬការផ្តោតអារម្មណ៍ ៖ មនុស្សម្នាក់ត្រូវបានរកឃើញថា មានបញ្ហាខ្លះក្នុងការចងចាំ ឬផ្តោតអារម្មណ៍ លើសកម្មភាពប្រចាំថ្ងៃ ត្រូវបានចាត់ទុកថា ពិការភាពក្នុងការចងចាំ ឬការផ្តោតអារម្មណ៍។ ពិការភាពប្រភេទនេះរួមទាំង មនុស្សម្នាក់ដែលមានបញ្ហាក្នុងការស្វែងរកផ្លូវ ផ្តោតអារម្មណ៍លើអ្វីដែលពួកគេកំពុងធ្វើ ឬចងចាំកន្លែងដែលខ្លួនរស់នៅប៉ុន្មានខែកន្លងទៅ។ លើសពីនេះទៀត មនុស្សម្នាក់មិនអាចនឹកឃើញនូវអ្វីដែលអ្នកណា

ម្នាក់ទើបនិយាយមកកាន់ខ្លួន ឬហាក់ច្រឡំ ឬមានអារម្មណ៍ភ័យខ្លាច ក៏ត្រូវបានទុកថាពិការភាពក្នុងការចងចាំ ឬផ្តោតអារម្មណ៍ផងដែរ។ ទាំងនេះអាចបណ្តាលមកពី ស្ថានភាពប្រចាំថ្ងៃ រួមមានបន្ទុកការងារខ្ពស់ ឬជាលទ្ធផលការប្រើប្រាស់សារធាតុញៀនណាមួយ ឬមូលហេតុចម្បងណាផ្សេងទៀត ដែលបង្ករអោយមានពិការភាពក្នុងប្រភេទនេះ។

(៥) ពិការភាពក្នុងការថែទាំខ្លួនឯង : មនុស្សម្នាក់ដែលមានការលំបាកក្នុងការថែទាំខ្លួន ដោយខ្លួនឯងផ្ទាល់ត្រូវបានចាត់ទុកថា ពិការភាពក្នុងការថែទាំខ្លួនឯង។ ពិការភាពប្រភេទនេះរួមមាន ការងារប្រចាំថ្ងៃដូចជា ការលាងសម្អាត ការស្លៀកពាក់ ឬតុបតែងខ្លួន។ ការលាងសម្អាតគឺសំដៅដល់ ដំណើរការនៃការលាងជម្រះខ្លួនទាំងមូល (ធម្មតាជាមួយសាប៊ូ និងទឹក)។ សកម្មភាពនៃការលាងសម្អាត រួមមាន ការបោកសំលៀកបំពាក់ ព្រមទាំងប្រមូលរបស់របរដែលចាំបាច់មានដូចជា សាប៊ូ សំលៀកបំពាក់ ឬទឹក។ ការស្លៀកពាក់ សំដៅដល់ស្ថានភាពទាំងអស់នៃការស្លៀកសំលៀកបំពាក់។ មនុស្សម្នាក់ដែលមិនអាចធ្វើការងារទាំងនេះដោយខ្លួនឯងបាន ត្រូវបានចាត់ថាមានពិការភាពប្រភេទនេះ។

(៦)ពិការភាពក្នុងការទំនាក់ទំនងដោយសារសុខភាពផ្លូវកាយ ផ្លូវចិត្ត ឬផ្លូវអារម្មណ៍ : មនុស្សម្នាក់ដែលមានបញ្ហា សុខភាពផ្លូវកាយ ផ្លូវចិត្ត ឬផ្លូវអារម្មណ៍ ដែលប៉ះពាល់ដល់ ការនិយាយ ការស្តាប់ ឬការយល់ និងកម្រិតក្នុងការធ្វើសកម្មភាពទំនាក់ទំនងប្រចាំថ្ងៃ។ ពិការភាពប្រភេទនេះរួមមាន មនុស្សម្នាក់ដែលអាចមានបញ្ហាយល់ខុសនៅពេលសន្ទនា ឬ មធ្យោបាយផ្សេងៗក្នុងការទំនាក់ទំនង។ ការទំនាក់ទំនងសំដៅដល់ ការផ្លាស់ប្តូរព័ត៌មានឬគំនិតគ្នាទៅវិញទៅមក។ ការផ្លាស់ប្តូរព័ត៌មានឬគំនិតឬប្តូរគំនិត គឺធ្វើឡើងដោយប្រើប្រាស់សំឡេង សញ្ញាសម្គាល់ ឬការសរសេរព័ត៌មាន។

## ៩.២. កម្រិតពិការភាព

តារាង ៩.២.១. បង្ហាញពីអត្រាពិការភាព បែងចែកតាម ភេទ តំបន់។ ឆ្លើយតបទៅនឹងប្រភេទពិការទាំងប្រាំមួយដោយធ្វើចំណាត់ថ្នាក់ជាបីប្រភេទ (ពិការខ្លះ ពិការខ្លាំង និងមិនអាចធ្វើអ្វីបានសោះ) កើតឡើងសូម្បីតែមួយកម្រិតនៅក្នុងប្រភេទពិការទាំងប្រាំមួយ ពិការណាមួយ (មិនអាចធ្វើអ្វីបានសោះ)។ អត្រានៃប្រជាជន មានពិការកម្រិតណាមួយ (ដូចបានរៀបរាប់ខាងលើ)។ អត្រាពិការភាពអាយុ ៥ ឆ្នាំឡើងនៅឧត្តរមានជ័យ សម្រាប់កម្រិតពិការណាមួយមាន ៤,៨ ភាគរយ (តារាង ៩.២.១)។ អត្រាពិការខ្លាំងក្នុងចំណោមប្រជាជនឧត្តរមានជ័យនៅមានកម្រិតទាបត្រឹម ០,៨ ភាគរយ ដោយឡែកពិការធ្ងន់ធ្ងរធ្វើអ្វីមិនកើតមានអត្រាទាបបំផុតក្នុងចំណោមប្រជាជនឧត្តរមានជ័យ ០,២ ភាគរយ។ បែងចែកតាមភេទ ស្ត្រីមានអត្រាជិត ១,០ ភាគរយខ្ពស់ជាងបុរស (៤,៤ ភាគរយ ទល់នឹង ៥,២ ភាគរយ) ដែលទម្រង់នេះស្របគ្នានឹងកម្រិតអត្រាពិការខ្លាំង។ បែងចែកតាមតំបន់នៅអត្រាពិការក្នុងកម្រិតណាមួយនៅជនបទខ្ពស់ជាងអត្រាពិការនៅតំបន់ទីប្រជុំជន (៤,៥ ភាគរយ ទល់នឹង ៥,០ ភាគរយ)។ ទម្រង់ផ្សេងគ្នានៃកម្រិតពិការតាមភេទមានលក្ខណៈស៊ីសង្វាក់គ្នាទាំងនៅជនបទ និងតំបន់ប្រជុំជន លើកលែងតែពិការភាពធ្ងន់ធ្ងរនៅតំបន់ទីប្រជុំជន និងជនបទដូចគ្នា។ ទម្រង់នេះមានលក្ខណៈដូចគ្នាទាំងប្រុស និងស្រី។

### តារាង ៩.២.១. អត្រាពិការភាពអាយុ ៥ ឆ្នាំឡើង បែងចែកតាមកម្រិតពិការភាព ភេទ ខេត្តឧត្តរមានជ័យ ឆ្នាំ ២០១៩

| តំបន់ | ចំនួនប្រជាជនអាយុ ៥ ឆ្នាំឡើង | សរុប | មិនពិការ | ពិការខ្លះ | ពិការខ្លាំង | មិនអាចធ្វើអ្វីបានសោះ |
|---|---|---|---|---|---|---|
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) |
| **សរុប** | ២៤៦.៣៤០ | ១០០ | ៩៥,២ | ៣,៩ | ០,៨ | ០,២ |
| ប្រុស | ១២៤.២១៤ | ១០០ | ៩៥,៦ | ៣,៥ | ០,៨ | ០,២ |
| ស្រី | ១២២.១២៦ | ១០០ | ៩៤,៨ | ៤,២ | ០,៨ | ០,២ |
| **ទីប្រជុំជន** | ៨១.៨០៥ | ១០០ | ៩៥,៥ | ៣,៥ | ០,៨ | ០,២ |
| ប្រុស | ៤០.៩២៥ | ១០០ | ៩៥,៨ | ៣,២ | ០,៨ | ០,២ |
| ស្រី | ៤០.៨៨០ | ១០០ | ៩៥,២ | ៣,៨ | ០,៨ | ០,២ |
| **ជនបទ** | ១៦៤.៥៣៥ | ១០០ | ៩៥,០ | ៤,១ | ០,៨ | ០,២ |
| ប្រុស | ៨៣.២៨៩ | ១០០ | ៩៥,៤ | ៣,៧ | ០,៧ | ០,២ |
| ស្រី | ៨១.២៤៦ | ១០០ | ៩៤,៥ | ៤,៤ | ០,៨ | ០,២ |

តារាង ៩.២.២. អត្រាពិការភាពបែងចែកតាមកម្រិតពិការ ភេទ តំបន់ ។ ក្នុងចំណោមប្រជាជនពិការទាំងអស់ ១១.៩៣១នាក់ ក្នុងនោះពិការខ្លះៗមាន ៧៩,៧ ភាគរយ ពិការខ្លាំងមាន ១៦,៥ ភាគរយ និងពិការមិនអាចធ្វើអ្វីបានសោះមាន ៣,៧ ភាគរយ ។

### តារាង ៩.២.២. អត្រាពិការភាពអាយុ ៥ ឆ្នាំឡើង បែងចែកតាមកម្រិតពិការភាព ភេទ ខេត្តឧត្តរមានជ័យ ឆ្នាំ ២០១៩

| តំបន់ | ចំនួនពិការអាយុ ៥ ឆ្នាំឡើង | សរុប | ពិការខ្លះ | ពិការខ្លាំង | មិនអាចធ្វើអ្វីបានសោះ |
|---|---|---|---|---|---|
| (១) | (២) | (៣) | (៤) | (៥) | (៦) |
| ទាំងពីរភេទ | ១១.៩៣១ | ១០០ | ៧៩,៧ | ១៦,៥ | ៣,៧ |
| ប្រុស | ៥.៥២១ | ១០០ | ៧៨,៩ | ១៧,២ | ៣,៩ |
| ស្រី | ៦.៤១០ | ១០០ | ៨០,៥ | ១៥,៩ | ៣,៦ |
| **ទីប្រជុំជន** | ៣.៦៦៥ | ១០០ | ៧៧,៦ | ១៨,៣ | ៤,១ |
| ប្រុស | ១.៧០៦ | ១០០ | ៧៦,១ | ១៩,៨ | ៤,១ |
| ស្រី | ១.៩៥៩ | ១០០ | ៧៨,៩ | ១៦,៩ | ៤,១ |
| **ជនបទ** | ៨.២៦៦ | ១០០ | ៨០,៧ | ១៥,៨ | ៣,៥ |
| ប្រុស | ៣.៨១៥ | ១០០ | ៨០,១ | ១៦,១ | ៣,៧ |
| ស្រី | ៤.៤៥១ | ១០០ | ៨១,២ | ១៥,៥ | ៣,៣ |

ជំរឿនឆ្នាំ២០១៩ អត្រាពិការនៅក្នុងខេត្តឧត្តរមានជ័យមានការប្រែប្រួលខ្លាំងជាមួយនឹងការកើនឡើងនៃអាយុ (រូប ៩.២.១) ។ នៅគ្រប់កម្រិតនៃពិការអត្រាស្ថិតក្នុងកម្រិតពី ៦,១ ភាគរយ សម្រាប់ក្រុមអាយុ ៥-១៤ ឆ្នាំ ទៅ ៣៧,៩ ភាគរយ សម្រាប់ក្រុមអាយុ ៦០ ឆ្នាំឡើង។ អត្រាជនពិការបានចាប់ផ្តើមកើនបន្តិចនៅក្នុងក្រុមអាយុវ័យកណ្តាលពី ១៤,៤ ភាគរយ សម្រាប់ក្រុមអាយុ ១៥-៣៤ ឆ្នាំទៅ ៤១,៦ ភាគរយសម្រាប់អាយុ ៣៥-៥៩ ឆ្នាំ ។ មានទំនាក់ទំនងជាវិជ្ជមានរវាងស្ថានភាពពិការ និងអាយុ ដែលជនពិការធ្ងន់ធ្ងរកើនឡើងជាងប្រាំដងពីក្រុមអាយុវ័យកណ្តាលទៅក្រុមអាយុវ័យចាស់ ដូចបានឃើញក្នុងរូប (៦,១ ភាគរយ ទល់នឹង ៣៧,៩ ភាគរយ) ។

### រូប ៩.២.១. អត្រាពិការភាពអាយុ ៥ ឆ្នាំឡើង បែងចែកតាមក្រុមអាយុ ភេទ ឧត្តរមានជ័យ ឆ្នាំ ២០១៩




សមាមាត្រក្នុងចំណោមជនពិការ តាមរយៈការមើលសូម្បីពាក់វ៉ែនតាក្តី (៣,៦ ភាគរយ) មានអត្រាខ្ពស់ជាងប្រភេទពិការផ្សេងទៀត។ ប្រភេទពិការផ្សេងទៀតមាននៅក្នុងកម្រិតពី ១,៨ ភាគរយ (សម្រាប់ពិការពិការក្នុងការថែទាំខ្លួន ដូចជាងូតទឹក ឬស្លៀកពាក់ និងពិការក្នុងការនិយាយ ដូចជាយល់អ្នកដ៏ទៃ ឬឲ្យអ្នកដ៏ទៃយល់) ទៅ ២,៦ ភាគរយ (ពិការក្នុងការស្តាប់ សូម្បីតែប្រើឧបករណ៍ជំនួយ)។

### តារាង ៩.២.៣. បែងចែកភាគរយនៃប្រជាជនពិការអាយុ ៥ ឆ្នាំឡើង តាមប្រភេទ ពិការ ភេទ និងខេត្តឧត្តរមានជ័យ ឆ្នាំ ២០១៩

| ប្រភេទនៃពិការ | ការបែងចែកជាភាគរយ | | |
|---|---|---|---|
| | សរុប | ទីប្រជុំជន | ជនបទ |
| **ទាំងពីរភេទ** | | | |
| **ពិការក្នុងការមើល សូម្បីតែពាក់វ៉ែនតា** | ១០០,0 | ១០០,0 | ១០០,0 |
| មិនមានពិការ | ៩៦,៤ | ៩៦,៦ | ៩៦,៣ |
| ពិការខ្លះដែរ | ៣,១ | ២,៨ | ៣,២ |
| ពិការខ្លាំង | 0,៥ | 0,៥ | 0,៤ |
| មិនអាចធ្វើអ្វីបានសោះ | 0,១ | 0,១ | 0,១ |
| **ពិការក្នុងការស្តាប់ សូម្បីតែប្រើឧបករណ៍ជំនួយ** | ១០០,0 | ១០០,0 | ១០០,0 |
| មិនមានពិការ | ៩៧,៤ | ៩៧,៥ | ៩៧,៣ |

| ប្រភេទនៃពិការ | ការបែងចែកជាភាគរយ | | |
|---|---|---|---|
| | សរុប | ទីប្រជុំជន | ជនបទ |
| ពិការខ្លះដែរ | ២,៣ | ២,១ | ២,៣ |
| ពិការខ្លាំង | ០,៣ | ០,៣ | ០,៣ |
| មិនអាចធ្វើអ្វីបានសោះ | ០,១ | ០,១ | ០,០ |
| **ពិការក្នុងការផ្លាស់ទី ឬឡើងជណ្តើរ (ការដើរ)** | ១០០,០ | ១០០,០ | ១០០,០ |
| មិនមានពិការ | ៩៧,៦ | ៩៧,៥ | ៩៧,៦ |
| ពិការខ្លះដែរ | ២,០ | ២,០ | ១,៩ |
| ពិការខ្លាំង | ០,៤ | ០,៤ | ០,៤ |
| មិនអាចធ្វើអ្វីបានសោះ | ០,១ | ០,១ | ០,១ |
| **ពិការក្នុងការចងចាំ ឬការផ្ចង់អារម្មណ៍** | ១០០,០ | ១០០,០ | ១០០,០ |
| មិនមានពិការ | ៩៧,៧ | ៩៧,៦ | ៩៧,៧ |
| ពិការខ្លះដែរ | ២,០ | ២,០ | ២,០ |
| ពិការខ្លាំង | ០,៣ | ០,៣ | ០,៣ |
| មិនអាចធ្វើអ្វីបានសោះ | ០,១ | ០,១ | ០,១ |
| **ពិការក្នុងការថែទាំខ្លួន ដូចជាងូតទឹក ឬស្លៀកពាក់** | ១០០,០ | ១០០,០ | ១០០,០ |
| មិនមានពិការ | ៩៨,២ | ៩៨,២ | ៩៨,២ |
| ពិការខ្លះដែរ | ១,៥ | ១,៥ | ១,៥ |
| ពិការខ្លាំង | ០,២ | ០,៣ | ០,២ |
| មិនអាចធ្វើអ្វីបានសោះ | ០,១ | ០,១ | ០,០ |
| **ពិការក្នុងការនិយាយ ដូចជាយល់អ្នកដទៃ ឬឲ្យអ្នកដទៃយល់** | ១០០,០ | ១០០,០ | ១០០,០ |
| មិនមានពិការ | ៩៨,២ | ៩៨,២ | ៩៨,២ |
| ពិការខ្លះដែរ | ១,៥ | ១,៥ | ១,៥ |
| ពិការខ្លាំង | ០,៣ | ០,៣ | ០,២ |
| មិនអាចធ្វើអ្វីបានសោះ | ០,១ | ០,១ | ០,១ |
| ប្រុស | | | |
| **ពិការក្នុងការមើល សូម្បីតែពាក់វ៉ែនតា** | ១០០,០ | ១០០,០ | ១០០,០ |
| មិនមានពិការ | ៩៦,៨ | ៩៧,០ | ៩៦,៧ |
| ពិការខ្លះដែរ | ២,៧ | ២,៤ | ២,៨ |
| ពិការខ្លាំង | ០,៤ | ០,៥ | ០,៤ |
| មិនអាចធ្វើអ្វីបានសោះ | ០,១ | ០,១ | ០,១ |
| **ពិការក្នុងការស្តាប់ សូម្បីតែប្រើឧបករណ៍ជំនួយ** | ១០០,០ | ១០០,០ | ១០០,០ |
| មិនមានពិការ | ៩៧,៧ | ៩៧,៨ | ៩៧,៧ |
| ពិការខ្លះដែរ | ១,៩ | ១,៨ | ២,០ |

| ប្រភេទនៃពិការ | ការបែងចែកជាភាគរយ | | |
|---|---|---|---|
| | សរុប | ទីប្រជុំជន | ជនបទ |
| ពិការខ្លាំង | ០,៣ | ០,៣ | ០,៣ |
| មិនអាចធ្វើអ្វីបានសោះ | ០,១ | ០,១ | ០,០ |
| **ពិការក្នុងការផ្លាស់ទី ឬឡើងជណ្តើរ (ការដើរ)** | ១០០,០ | ១០០,០ | ១០០,០ |
| មិនមានពិការ | ៩៧,៩ | ៩៧,៩ | ៩៧,៩ |
| ពិការខ្លះដែរ | ១,៧ | ១,៧ | ១,៦ |
| ពិការខ្លាំង | ០,៤ | ០,៤ | ០,៤ |
| មិនអាចធ្វើអ្វីបានសោះ | ០,១ | ០,១ | ០,១ |
| **ពិការក្នុងការចងចាំ ឬការផ្តង់អារម្មណ៍** | ១០០,០ | ១០០,០ | ១០០,០ |
| មិនមានពិការ | ៩៨,០ | ៩៧,៩ | ៩៨,០ |
| ពិការខ្លះដែរ | ១,៧ | ១,៨ | ១,៧ |
| ពិការខ្លាំង | ០,២ | ០,៣ | ០,២ |
| មិនអាចធ្វើអ្វីបានសោះ | ០,១ | ០,១ | ០,១ |
| **ពិការក្នុងការថែទាំខ្លួន ដូចជាងូតទឹក ឬស្លៀកពាក់** | ១០០,០ | ១០០,០ | ១០០,០ |
| មិនមានពិការ | ៩៨,៥ | ៩៨,៤ | ៩៨,៥ |
| ពិការខ្លះដែរ | ១,៣ | ១,៣ | ១,២ |
| ពិការខ្លាំង | ០,២ | ០,២ | ០,២ |
| មិនអាចធ្វើអ្វីបានសោះ | ០,០ | ០,១ | ០,០ |
| **ពិការក្នុងការនិយាយ ដូចជាយល់អ្នកដទៃ ឬឲ្យអ្នកដទៃយល់** | ១០០,០ | ១០០,០ | ១០០,០ |
| មិនមានពិការ | ៩៨,៥ | ៩៨,៤ | ៩៨,៥ |
| ពិការខ្លះដែរ | ១,២ | ១,៣ | ១,២ |
| ពិការខ្លាំង | ០,២ | ០,២ | ០,២ |
| មិនអាចធ្វើអ្វីបានសោះ | ០,១ | ០,១ | ០,១ |
| **ស្រី** | | | |
| **ពិការក្នុងការមើល សូម្បីតែពាក់វ៉ែនតា** | ១០០,០ | ១០០,០ | ១០០,០ |
| មិនមានពិការ | ៩៦,០ | ៩៦,៣ | ៩៥,៩ |
| ពិការខ្លះដែរ | ៣,៤ | ៣,១ | ៣,៦ |
| ពិការខ្លាំង | ០,៥ | ០,៥ | ០,៥ |
| មិនអាចធ្វើអ្វីបានសោះ | ០,១ | ០,១ | ០,១ |
| **ពិការក្នុងការស្តាប់ សូម្បីតែប្រើឧបករណ៍ជំនួយ** | ១០០,០ | ១០០,០ | ១០០,០ |
| មិនមានពិការ | ៩៧,០ | ៩៧,២ | ៩៦,៩ |
| ពិការខ្លះដែរ | ២,៦ | ២,៥ | ២,៧ |

| ប្រភេទនៃពិការ | ការបែងចែកជាភាគរយ | | |
|---|---|---|---|
| | សរុប | ទីប្រជុំជន | ជនបទ |
| ពិការខ្លាំង | ០,៤ | ០,៣ | ០,៤ |
| មិនអាចធ្វើអ្វីបានសោះ | ០,១ | ០,១ | ០,១ |
| **ពិការក្នុងការផ្លាស់ទី ឬឡើងជណ្ដើរ (ការដើរ)** | ១០០,០ | ១០០,០ | ១០០,០ |
| មិនមានពិការ | ៩៧,២ | ៩៧,២ | ៩៧,៣ |
| ពិការខ្លះដែរ | ២,៣ | ២,៣ | ២,៣ |
| ពិការខ្លាំង | ០,៤ | ០,៤ | ០,៤ |
| មិនអាចធ្វើអ្វីបានសោះ | ០,១ | ០,១ | ០,១ |
| **ពិការក្នុងការចងចាំ ឬការផ្ចង់អារម្មណ៍** | ១០០,០ | ១០០,០ | ១០០,០ |
| មិនមានពិការ | ៩៧,៣ | ៩៧,៣ | ៩៧,៣ |
| ពិការខ្លះដែរ | ២,២ | ២,៣ | ២,២ |
| ពិការខ្លាំង | ០,៤ | ០,៤ | ០,៣ |
| មិនអាចធ្វើអ្វីបានសោះ | ០,១ | ០,១ | ០,១ |
| **ពិការក្នុងការថែទាំខ្លួន ដូចជាងូតទឹក ឬស្លៀកពាក់** | ១០០,០ | ១០០,០ | ១០០,០ |
| មិនមានពិការ | ៩៧,៩ | ៩៧,៩ | ៩៧,៩ |
| ពិការខ្លះដែរ | ១,៧ | ១,៧ | ១,៧ |
| ពិការខ្លាំង | ០,៣ | ០,៣ | ០,៣ |
| មិនអាចធ្វើអ្វីបានសោះ | ០,១ | ០,១ | ០,០ |
| **ពិការក្នុងការនិយាយ ដូចជាយល់អ្នកដ៏ទៃ ឬឲ្យអ្នកដ៏ទៃយល់** | ១០០,០ | ១០០,០ | ១០០,០ |
| មិនមានពិការ | ៩៧,៩ | ៩៧,៩ | ៩៧,៩ |
| ពិការខ្លះដែរ | ១,៧ | ១,៧ | ១,៧ |
| ពិការខ្លាំង | ០,៣ | ០,៣ | ០,៣ |
| មិនអាចធ្វើអ្វីបានសោះ | ០,១ | ០,១ | ០,១ |

# ជំពូក ១០

# លំនៅដ្ឋាន ចរិតលក្ខណៈគ្រួសារ និងសម្ភារៈប្រើប្រាស់ក្នុងគ្រួសារ

## ១០.១. លំនៅដ្ឋាន

ជំរឿន២០១៩ មិនបានរាប់បញ្ចូលនូវជំរឿនផ្ទះសំបែង ប៉ុន្តែព័ត៌មានខ្លះស្តីពីលក្ខណៈផ្ទះសំបែងក៏ត្រូវបានប្រមូលនៅក្នុងប្រតិបត្តិការចុះបញ្ជី ក្នុងរយៈពេល ៣ ថ្ងៃមុនធ្វើការសម្ភាសន៍ជំរឿនពិតប្រាកដ។ អំឡុងពេលចុះបញ្ជីផ្ទះ រាល់អាគារ ឬសំណង់ត្រូវបានប្រើប្រាស់សម្រាប់គោលបំណងលំនៅដ្ឋានដោយផ្នែក ឬទាំងមូលត្រូវបានចុះបញ្ជី ទៅតាមគ្រួសារដែលរស់នៅក្នុងលំនៅដ្ឋាន ដោយមន្ត្រីសម្ភាសន៍នៅក្នុងតារាង ក (មើលគំរូក្នុងឧបសម្ព័ន្ធ ៣) លើសពីនេះទៀត ការចុះបញ្ជីព័ត៌មានខាងក្រោមត្រូវបានប្រមូល និងកត់ត្រាដោយមន្ត្រីសម្ភាសន៍នៅក្នុងលក្ខណៈលំនៅដ្ឋាន ៖ (i) អាគារ គឺជាលំនៅដ្ឋានទាំងមូល ឬដោយផ្នែក ហើយបន្ទាប់មកការប្រើប្រាស់ផ្សេងៗសម្រាប់អាគារត្រូវបានកត់ត្រា (ii) វត្ថុធាតុប្រើប្រាស់សម្រាប់ជញ្ជាំង ដំបូល និងកម្រាលរបស់អាគារ។

**តារាង ១០.១.១. ភាគរយនៃអាគារលំនៅដ្ឋាន ជាលំនៅដ្ឋានទាំងមូល ឬដោយផ្នែក និងប្រភេទលំនៅដ្ឋានដ៏ទៃទៀត ខេត្តឧត្តរមានជ័យឆ្នាំ២០០៨ និង ២០១៩**

| លំនៅដ្ឋាន | ចំនួនអាគារសរុប | ការបែងចែកភាគរយ | | | | |
|---|---|---|---|---|---|---|
| | | សរុប | លំនៅដ្ឋានទាំងមូល | លំនៅដ្ឋានដ៏ទៃទៀត | | |
| | | | | លំនៅដ្ឋានផង និងហាងលក់ទំនិញផង | លំនៅដ្ឋានផង និងរោងជាងផង | លំនៅដ្ឋានផងនិងប្រើប្រាស់ផ្សេងផង |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) |
| **២០១៩** | | | | | | |
| សរុប | ៥៧.៦០៨ | ១០០ | ៩៤,៩ | ៣,៨ | ០,៨ | ០,១ |
| ទីប្រជុំជន | ១៨.៧៦៧ | ១០០ | ៩៣,៨ | ៤,៤ | ០,៩ | ០,២ |
| ជនបទ | ៣៨.៨៤១ | ១០០ | ៩៥,៤ | ៣,៥ | ០,៨ | ០,១ |
| **២០០៨** | | | | | | |
| សរុប | ៣៨.២៥៤ | ១០០ | ៩៦,៧ | ២,២ | ០,៥ | ០,៥ |
| ទីប្រជុំជន | ៣.៥២៩ | ១០០ | ៩៤,៨ | ៣,៣ | ១,៣ | ០,៥ |
| ជនបទ | ៣៤.៧២៥ | ១០០ | ៩៦,៩ | ២,១ | ០,៤ | ០,៥ |

**សម្គាល់ ៖** មិនរាប់បញ្ចូលប្រភេទប្រើប្រាស់អាគារមិនបានរាយការណ៍

តាមលទ្ធផលជំរឿនប្រជាជនឆ្នាំ២០១៩ បានបង្ហាញថាចំនួននៃអាគារលំនៅដ្ឋាននៅខេត្តឧត្តរមានជ័យបានកើនឡើងពី ៣៨.២៥៤ ឆ្នាំ ២០០៨ និងដល់ ៥៧.៦០៨ ក្នុងឆ្នាំ ២០១៩ តាមលំដាប់រៀង (តារាង ១០.១.១)។ នៅទូទាំង ខេត្តឧត្តរមានជ័យមាន ៩៤,៩ ភាគរយនៃអាគារជាលំនៅដ្ឋានសំរាប់ស្នាក់នៅ។ សមាមាត្រនៅតំបន់ទីប្រជុំជន និងជនបទ មានចំនួន ៩៣,៨ ភាគរយ និង ៩៥,៤ ភាគរយ តាមលំដាប់រៀង។ ប្រភេទអាគារ ដែលជាលំនៅដ្ឋានផង និងប្រើប្រាស់សំរាប់គោលបំណងផ្សេងទៀតមានសមាមាត្រខ្ពស់នៅតំបន់ទីប្រជុំជនជាងជនបទ។

## តារាង ១០.១.២. ភាគរយនៃអាគារ និងលំនៅដ្ឋានតាមលក្ខណៈនៃសំណង់អាគារ និងតាមទីកន្លែងរស់នៅ ខេត្តឧត្តរមានជ័យឆ្នាំ២០០៨ និង២០១៩

| សរុប ទីប្រជុំជន ជនបទ | ចំនួនអាគារសរុប | ភាគរយនៃអាគារតាមលក្ខណៈនៃសំណង់ | | | |
|---|---|---|---|---|---|
| | | សរុប | អចិន្ត្រៃយ៍ | ពាក់កណ្ដាលអចិន្ត្រៃយ៍ | បណ្ដោះអាសន្ន |
| (១) | (២) | (៣) | (៤) | (៥) | (៦) |
| ២០១៩ | | | | | |
| **សរុប** | ៥៧.៦០៨ | ១០០ | ៩៣,៧ | ៤,៩ | ១,៤ |
| ទីប្រជុំជន | ១៨.៧៦៧ | ១០០ | ៩២,៥ | ៥,៤ | ២,១ |
| ជនបទ | ៣៨.៨៤១ | ១០០ | ៩៤,៣ | ៤,៧ | ១,០ |
| ២០០៨ | | | | | |
| **សរុប** | ៣៨.២៥៤ | ១០០ | ៥០,២ | ៣១,១ | ១៨,៨ |
| ទីប្រជុំជន | ៣.៥២៩ | ១០០ | ៦៨,០ | ២១,២ | ១០,៧ |
| ជនបទ | ៣៤.៧២៥ | ១០០ | ៤៨,៣ | ៣២,១ | ១៩,៦ |

**សម្គាល់ ៖** មិនរាប់បញ្ចូលប្រភេទប្រើប្រាស់អាគារមិនបានរាយការណ៍

សម្ភារៈសាងសង់អាគារបានរួមបញ្ចូលគ្នា ប្រើប្រាស់ដើម្បីកំណត់គុណភាពសំណង់អាគារ។ ផ្អែកលើវត្ថុធាតុជញ្ជាំង និងដំបូល អាគារត្រូវបានប្រើប្រាស់ក្នុងគោលបំណងលំនៅដ្ឋាន (ទាំងមូល និងដោយផ្នែក) ចាត់ថ្នាក់ជាអចិន្ត្រៃយ៍ ពាក់កណ្ដាលអចិន្ត្រៃយ៍ ឬបណ្ដោះអាសន្ន។ ដំបូលធ្វើដោយឫស្សី ស្បូវ ស្លឹក ឬបន្ទះជ័រ ត្រូវបានសន្មតថាបណ្ដោះអាសន្ន។ ដំបូលធ្វើអំពីវត្ថុធាតុដូចខាងក្រោមនេះត្រូវបានសន្មតជាអចិន្ត្រៃយ៍ ដូចជាឈើ/ក្ដារ បន្ទះ/បេតុង/ឥដ្ឋ/ថ្ម/សង្ក័សី/អាលុយមីញ៉ូម/បន្ទះលោហៈធាតុផ្សេងៗ/ហ្វ៊ីប្រូស៊ីម៉ង់ត៍ និងក្បឿង។ ជញ្ជាំងធ្វើដោយឫស្សី ស្បូវ ស្លឹក ឬបន្ទះជ័រ ឬវត្ថុធាតុបិទបាំងបណ្ដោះអាសន្នត្រូវបានសន្មតថាបណ្ដោះអាសន្ន។ ជញ្ជាំងធ្វើដោយវត្ថុធាតុដូចខាងក្រោមនេះត្រូវបានសន្មតថាជាអចិន្ត្រៃយ៍ ដូចជាឈើ/ក្ដារបន្ទះ/បេតុង/ឥដ្ឋ/ថ្ម/សង្ក័សី/អាលុយមីញ៉ូម /បន្ទះលោហៈធាតុផ្សេងៗ/ហ្វ៊ីប្រូស៊ីម៉ង់ត៍។

អាគារ ឬរចនាសម្ព័ន្ធដែលរួមបញ្ចូលដោយវត្ថុធាតុជញ្ជាំងអចិន្ត្រៃយ៍ និងដំបូលអចិន្ត្រៃយ៍ត្រូវបានចាត់ទុកជាអចិន្ត្រៃយ៍។ អាគារ ឬរចនាសម្ព័ន្ធរួមបញ្ចូលគ្នាដោយសម្ភារៈជញ្ជាំងអចិន្ត្រៃយ៍ និងដំបូលបណ្ដោះអាសន្ន ឬវត្ថុធាតុជញ្ជាំងបណ្ដោះអាសន្ន និងដំបូលអចិន្ត្រៃយ៍ត្រូវបានចាត់ទុកថា អាគារមានលក្ខណៈពាក់កណ្ដាលអចិន្ត្រៃយ៍។ អាគារ ឬរចនា សម្ព័ន្ធរួមបញ្ចូលគ្នាដោយវត្ថុធាតុជញ្ជាំងបណ្ដោះអាសន្ន និងដំបូលបណ្ដោះអាសន្ន ត្រូវបានចាត់ទុកថាជាអាគារមានលក្ខណៈបណ្ដោះអាសន្ន។

តារាង ១០.១.២ បង្ហាញថានៅឆ្នាំ២០១៩ ប្រមាណ ៩៣,៧ ភាគរយនៃអាគារលំនៅដ្ឋាន ជាអាគារមានលក្ខណៈអចិន្ត្រៃយ៍។ ប្រមាណ ៤,៩ ភាគរយនៃអាគារលំនៅដ្ឋាន ជាសំណង់មានលក្ខណៈពាក់កណ្ដាលអចិន្ត្រៃយ៍ និង ១,៤ ភាគរយ ជារចនាសម្ព័ន្ធមានលក្ខណៈបណ្ដោះអាសន្ន។ នៅតំបន់ជនបទប្រមាណ ៤,៧ ភាគរយនៃអាគារលំនៅដ្ឋានជាសំណង់មានលក្ខណៈពាក់កណ្ដាលអចិន្ត្រៃយ៍ និងប្រមាណ ១,០ ភាគរយ ជារចនាសម្ព័ន្ធមានលក្ខណៈបណ្ដោះអាសន្ន។

## ១០.២. ចរិតលក្ខណៈគ្រួសារ

### ១០.២.១. ចំនួន និងទំហំគ្រួសារ

ចំនួនគ្រួសារសរុបដែលបានរាប់នៅខេត្តឧត្តរមានជ័យក្នុងពេលធ្វើជំរឿនឆ្នាំ២០០៨ និង២០១៩ មាន ៣៨.៣៩៨ និង ៦០.៨៨៦ តាមលំដាប់រៀង។ ក្នុងចំណោមគ្រួសារទាំងនោះគ្រួសារធម្មតា ឬគ្រួសារប្រក្រតី ។ ចំណែកគ្រួសារធម្មតា ឬគ្រួសារប្រក្រតីនៅទីប្រជុំជនឆ្នាំ២០០៨ មានចំនួន ៣.៦០៨ ប្រៀបធៀបនឹងឆ្នាំ២០១៩ បានកើនឡើង ១៦.២១៨ ។ នៅជនបទមាន ៣៤,៧៩០ បើប្រៀបធៀបនឹងឆ្នាំ២០១៩ បានកើនឡើងចំនួន ៦,២៧០ គ្រួសារ។

តារាង ១០.២.១ ចំនួនគ្រួសារធម្មតា ឬគ្រួសារប្រក្រតី និងទំហំជាមធ្យមអំឡុងឆ្នាំ២០០៨ និង២០១៩ ខេត្តឧត្តរមានជ័យ

| លំនៅដ្ឋាន | គ្រួសារធម្មតា | | ការប្រែប្រួល | ទំហំគ្រួសារជាមធ្យម | |
|---|---|---|---|---|---|
| | ២០០៨ | ២០១៩ | ២០០៨-២០១៩ | ២០០៨ | ២០១៩ |
| សរុប | ៣៨.៣៩៨ | ៦០.៨៨៦ | ២២.៤៨៨ | ៤,៨ | ៤,៤ |
| ទីប្រជុំជន | ៣.៦០៨ | ១៩.៨២៦ | ១៦.២១៨ | ៥,២ | ៤,៥ |
| ជនបទ | ៣៤.៧៩០ | ៤១.០៦០ | ៦.២៧០ | ៤,៨ | ៤,៤ |

តារាង ១០.២.១ បានបង្ហាញថាទំហំគ្រួសារជាមធ្យមបានថយចុះពី ៤,៨ នៅឆ្នាំ២០០៨ ទៅ ៤,៤ នៅឆ្នាំ ២០១៩ ក្នុងរយៈពេលមួយទសវត្សរ៍នៅថ្នាក់ខេត្ត។ នៅតំបន់ទីប្រជុំជនបានធ្លាក់ចុះ ០,៧ ក្នុងរយៈពេលទសវត្សរ៍នេះ ចំណែកឯនៅជនបទបានថយ ០,៤។ និន្នាការនៃការថយចុះទំហំគ្រួសារ គឺស្របជាមួយនឹងការកើនឡើងនៃចំនួនគ្រួសារនៅក្នុងប្រទេស នេះបង្ហាញថាការប្រែប្រួលមួយពីរចនាសម្ព័ន្ធគ្រួសារធំឆ្ពោះទៅគ្រួសារតូច។

តាមរយៈលទ្ធផលនៃការធ្វើជំរឿនបង្ហាញថាគ្រួសារធម្មតាដែលមានសមាជិកចំនួន ៤,៤ នាក់ មានសមាមាត្រស្ត្រីជាមេគ្រួសារ ១៧,៣ ភាគរយ ក្នុងឆ្នាំ២០១៩ ទីប្រជុំជន ១៧,០ ភាគរយ និងជនបទ ១៧.៥ ភាគរយ។

តារាង ១០.២.៣ ភាគរយនៃគ្រួសារ តាមភេទនៃមេគ្រួសារ និងទំហំគ្រួសារ ខេត្តឧត្តរមានជ័យឆ្នាំ២០១៩

| ចរិតលក្ខណៈ | សរុប | | |
|---|---|---|---|
| | សរុប | ទីប្រជុំជន | ជនបទ |
| (១) | (២) | (៣) | (៤) |
| **មេគ្រួសារ** | | | |
| ប្រុស | ៨២,៧ | ៨៣,០ | ៨២,៥ |
| ស្រី | ១៧,៣ | ១៧,០ | ១៧,៥ |
| **សរុប** | ១០០,០ | ១០០,០ | ១០០,០ |

**សម្គាល់ ៖** មិនរាប់បញ្ចូលគ្រួសារស្ថាប័ន គ្រួសារគ្មានផ្ទះសំបែង គ្រួសាររស់នៅលើទូក គ្រួសារឆ្លងកាត់

### ១០.២.២. បុរស និងស្ត្រីជាមេគ្រួសារ

ប្រមាណជា ១៧,៣ ភាគរយនៃគ្រួសារដឹកនាំដោយស្ត្រី ។ ស្ត្រីជាមេគ្រួសារភាគច្រើនមានអាយុចន្លោះពី ២៥-៥៩ ឆ្នាំ (តារាង ១០.២.៤) មាន ៨២,៣ ភាគរយ ជំរឿនឆ្នាំ២០១៩ ។

## រូប ១០.២.១. ស្ត្រីជាមេគ្រួសារ តាមតំបន់ ខេត្តឧត្តរមានជ័យឆ្នាំ២០១៩




## តារាង ១០.២.៤. ការបែងចែកភាគរយនៃមេគ្រួសារ (អាយុ ១០ ឆ្នាំឡើង) តាមតំបន់ និងក្រុមអាយុ ៥ ឆ្នាំ ខេត្តឧត្តរមានជ័យឆ្នាំ ២០១៩

| ក្រុមអាយុ | សរុប | ទីប្រជុំជន | ជនបទ |
|---|---|---|---|
| (១) | (២) | (៣) | (៤) |
| **សរុប** | ១០០,០ | ១០០,០ | ១០០,០ |
| ១០-១៤ | ០,២ | ០,២ | ០,២ |
| ១៥ -១៩ | ០,៥ | ០,៤ | ០,៥ |
| ២០ -២៤ | ៣,៣ | ២,៨ | ៣,៥ |
| ២៥ -២៩ | ៩,៩ | ៩,២ | ១០,២ |
| ៣០ -៣៤ | ១៤,៤ | ១៣,៧ | ១៤,៧ |
| ៣៥ -៣៩ | ១៦,២ | ១៦,៥ | ១៦,១ |
| ៤០ -៤៤ | ១០,១ | ១០,៦ | ៩,៩ |
| ៤៥ -៤៩ | ១០,៨ | ១១,៦ | ១០,៤ |
| ៥០ -៥៤ | ១០,៥ | ១១,០ | ១០,៣ |
| ៥៥ -៥៩ | ១០,៥ | ១០,៧ | ១០,៣ |
| ៦០ -៦៤ | ៦,៧ | ៦,៦ | ៦,៨ |
| ៦៥ -៦៩ | ៣,៩ | ៤,០ | ៣,៩ |
| ៧០ -៧៤ | ១,៧ | ១,៧ | ១,៧ |
| ៧៥+ | ១,៣ | ១,១ | ១,៤ |

**សម្គាល់ ៖** មិនរាប់បញ្ចូលគ្រួសារស្ថាប័ន គ្រួសារគ្មានផ្ទះសំបែង គ្រួសាររស់នៅលើទូក និងគ្រួសារឆ្លងកាត់។

## ១០.២.៣. ចំនួនបន្ទប់ប្រើប្រាស់ក្នុងគ្រួសារ

ភាគច្រើននៃគ្រួសារ (៦០,៤ ភាគរយ) មានបន្ទប់តែមួយប៉ុណ្ណោះ។ នៅទីប្រជុំជនមាន ៦០,០ ភាគរយនៃគ្រួសារមានមួយបន្ទប់ ២៧,៦ ភាគរយ មានពីរបន្ទប់ ៨,៣ ភាគរយនៃគ្រួសារមានបីបន្ទប់ និងប្រមាណ ៤,១ ភាគរយនៃគ្រួសារដែលរស់នៅលំនៅដ្ឋានមានបួនបន្ទប់ឡើងទៅ។

## តារាង ១០.២.៩. ការបែងចែកគ្រួសារតាមស្ថានភាពលំនៅដ្ឋាន ចំនួនបន្ទប់គ្រប់គ្រងដោយគ្រួសារ និងតំបន់ ខេត្តឧត្តរមានជ័យឆ្នាំ ២០០៨ និង២០១៩

| ស្ថានភាពលំនៅដ្ឋាន | ចំនួនបន្ទប់ដែលគ្រួសារមាន | | | | | |
|---|---|---|---|---|---|---|
| | សរុប | ១ | ២ | ៣ | ៤ | ៥ + |
| (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) |
| **២០១៩** | | | | | | |
| **សរុប** | | | | | | |
| ចំនួនគ្រួសារ | ៦០.៨៨៦ | ៦០,៤ | ២៨,៥ | ៨,០ | ២,២ | ០,៩ |
| ផ្ទះផ្ទាល់ខ្លួន | ៥៧.១៦៣ | ៥៩,៨ | ២៩,០ | ៨,១ | ២,២ | ០,៩ |
| ផ្ទះជួល | ១.៦៥៦ | ៦៩,២ | ២៤,០ | ៤,៧ | ១,១ | ១,០ |
| មិនមែនជាម្ចាស់ផ្ទះ តែជួលមិនបាច់បង់ប្រាក់ឈ្នួល | ១.៩២៤ | ៧០,៥ | ១៩,៦ | ៧,០ | ២,២ | ០,៧ |
| មូលដ្ឋានផ្សេងទៀត | ១៤៣ | ៦៨,៥ | ១៥,៤ | ៨,៤ | ២,៨ | ៤,៩ |
| **ទីប្រជុំជន** | | | | | | |
| ចំនួនគ្រួសារ | ១៩.៨២៦ | ៦០,០ | ២៧,៦ | ៨,៣ | ២,៦ | ១,៥ |
| ផ្ទះផ្ទាល់ខ្លួន | ១៧.៧៥៥ | ៥៨,៧ | ២៨,៤ | ៨,៦ | ២,៧ | ១,៦ |
| ផ្ទះជួល | ១.១៣៤ | ៧១,២ | ២១,៩ | ៤,៣ | ១,៤ | ១,២ |
| មិនមែនជាម្ចាស់ផ្ទះ តែជួលមិនបាច់បង់ប្រាក់ឈ្នួល | ៩០៤ | ៧១,៦ | ១៩,២ | ៦,៦ | ១,៥ | ១,០ |
| មូលដ្ឋានផ្សេងទៀត | ៣៣ | ៦០,៦ | ១៥,២ | ១៥,២ | ៣,០ | ៦,១ |
| **ជនបទ** | | | | | | |
| ចំនួនគ្រួសារ | ៤១.០៦០ | ៦០,៦ | ២៩,០ | ៧,៩ | ២,០ | ០,៦ |
| ផ្ទះផ្ទាល់ខ្លួន | ៣៩.៤០៨ | ៦០,៣ | ២៩,៣ | ៧,៩ | ១,៩ | ០,៦ |
| ផ្ទះជួល | ៥២២ | ៦៤,៩ | ២៨,៧ | ៥,៦ | ០,៤ | ០,៤ |
| មិនមែនជាម្ចាស់ផ្ទះ តែជួលមិនបាច់បង់ប្រាក់ឈ្នួល | ១.០២០ | ៦៩,៥ | ១៩,៩ | ៧,៣ | ២,៨ | ០,៥ |
| មូលដ្ឋានផ្សេងទៀត | ១១០ | ៧០,៩ | ១៥,៥ | ៦,៤ | ២,៧ | ៤,៥ |
| **២០០៨** | | | | | | |
| **សរុប** | | | | | | |
| ចំនួនគ្រួសារ | ៣៨.៣៩៨ | ៧១,៣ | ២១,៣ | ៥,៧ | ១,២ | ០,៦ |
| ផ្ទះផ្ទាល់ខ្លួន | ៣៤.៨៧២ | ៧០,៣ | ២២,០ | ៥,៩ | ១,២ | ០,៦ |
| ផ្ទះជួល | ១.៦៦៦ | ៧៨,៥ | ១៥,៩ | ៣,៥ | ០,៨ | ១,៣ |
| មិនមែនជាម្ចាស់ផ្ទះ តែជួលមិនបាច់បង់ប្រាក់ឈ្នួល | ១.៦១៩ | ៨៣,១ | ១២,៣ | ៣,៥ | ០,៨ | ០,២ |
| មូលដ្ឋានផ្សេងទៀត | ២៤១ | ៧៩,៧ | ១៣,៣ | ៦,២ | ០,៤ | ០,៤ |
| **ទីប្រជុំជន** | | | | | | |
| ចំនួនគ្រួសារ | ៣.៦០៨ | ៦៥,១ | ២៤,១ | ៧,៤ | ១,៩ | ១,៤ |
| ផ្ទះផ្ទាល់ខ្លួន | ៣.២៥២ | ៦៣,៩ | ២៥,១ | ៧,៦ | ២,០ | ១,៥ |
| ផ្ទះជួល | ១៦៩ | ៦៩,៨ | ២០,៧ | ៨,៣ | ១,២ | ០,០ |
| មិនមែនជាម្ចាស់ផ្ទះ តែជួលមិនបាច់បង់ប្រាក់ឈ្នួល | ១៧៣ | ៨២,១ | ១១,០ | ៤,៦ | ០,៦ | ១,៧ |
| មូលដ្ឋានផ្សេងទៀត | ១៤ | ៨៥,៧ | ១៤,៣ | ០,០ | ០,០ | ០,០ |
| **ជនបទ** | | | | | | |
| ចំនួនគ្រួសារ | ៣៤.៧៩០ | ៧១,៩ | ២១,០ | ៥,៥ | ១,១ | ០,៥ |
| ផ្ទះផ្ទាល់ខ្លួន | ៣១.៦២០ | ៧១,០ | ២១,៧ | ៥,៧ | ១,១ | ០,៥ |
| ផ្ទះជួល | ១.៤៩៧ | ៧៩,៥ | ១៥,៤ | ២,៩ | ០,៧ | ១,៥ |
| មិនមែនជាម្ចាស់ផ្ទះ តែជួលមិនបាច់បង់ប្រាក់ឈ្នួល | ១.៤៤៦ | ៨៣,៣ | ១២,៤ | ៣,៤ | ០,៨ | ០,១ |
| មូលដ្ឋានផ្សេងទៀត | ២២៧ | ៧៩,៣ | ១៣,២ | ៦,៦ | ០,៤ | ០,៤ |

**សម្គាល់ ៖** មិនរាប់បញ្ចូលគ្រួសារស្ថាប័ន គ្រួសារគ្មានផ្ទះសំបែង គ្រួសាររស់នៅលើទូក និងគ្រួសារឆ្លងកាត់។

## ១០.៣. សម្ភារៈប្រើប្រាស់ក្នុងគ្រួសារ

### ១០.៣.១. ទឹកសម្រាប់ទទួលទាន

ដូចជំរឿនឆ្នាំ២០០៨ ដែរព័ត៌មានអំពីសម្ភារៈប្រើប្រាស់នៅក្នុងគ្រួសារត្រូវបានប្រមូលក្នុងជំរឿនឆ្នាំ២០១៩ ។ ដោយឡែក សម្រាប់ការប្រមូលព័ត៌មានអំពីប្រភពទឹកស្អាតសម្រាប់ទទួលទាន រួមមានទឹកបំពង់បណ្ដាញក្នុងលំនៅដ្ឋាន ទឹកបំពង់បណ្ដាញក្នុងទីធ្លា/បរិវេណលំនៅដ្ឋាន ទឹកបំពង់សាធារណៈ អណ្ដូងស្នប់/អណ្ដូងខួង អណ្ដូងជីកមានគម្រប ការពារ ទឹកភ្លៀង និងទឹកដប/ទឹកពិសាដប។ ប្រមាណ ៣៨,៩ ភាគរយ នៃគ្រួសារខេត្តឧត្តរមានជ័យមានប្រភពទឹកស្អាតសម្រាប់ប្រើប្រាស់នៅឆ្នាំ២០១៩ (តារាង ១០.៣.១)។ នៅតំបន់ទីប្រជុំជនមានភាគរយខ្ពស់នៃគ្រួសារដែលមានប្រភពទឹកស្អាតសម្រាប់ទទួលទាន (៤៤,៦ ភាគរយ)។ម្យ៉ាងវិញទៀត ប្រមាណ ២៧,៤ ភាគរយ នៃគ្រួសារនៅទីប្រជុំជនមានប្រភពផ្គត់ផ្គង់ទឹកស្អាតសម្រាប់ទទួលទាននៅក្នុងបរិវេណគេហដ្ឋានរបស់ពួកគេ។ ប៉ុន្តែនៅជនបទមានតែ ២៣,៣ ភាគរយ ប៉ុណ្ណោះដែលមានប្រភពទឹកស្អាតសម្រាប់ទទួលទាននៅក្នុងគេហដ្ឋាន។ តាមតួលេខនេះបានបញ្ជាក់ឲ្យឃើញថាការផ្គត់ផ្គង់ទឹកស្អាតសម្រាប់ប្រើប្រាស់នៅក្នុងគេហដ្ឋានរបស់ប្រជាជន ខេត្តឧត្តរមានជ័យមានការរីកចម្រើនជាងឆ្នាំ២០០៨ ជាពិសេសនៅតំបន់ជនបទ។

រូប ១០.៣.១. ភាគរយនៃគ្រួសារ តាមទីតាំងប្រភពទឹកសម្រាប់ទទួលទាន និងតំបន់ ខេត្តឧត្តរមានជ័យឆ្នាំ២០១៩



តារាង ១០.៣.១. ការបែងចែកភាគរយគ្រួសារ តាមប្រភពទឹកចម្បងសម្រាប់ទទួលទាន ខេត្តឧត្តរមានជ័យឆ្នាំ២០១៩

| តាមប្រភពទឹកចម្បងសម្រាប់ទទួលទាន | សរុប | ទីប្រជុំជន | ជនបទ |
|---|---|---|---|
| (១) | (២) | (៣) | (៤) |
| ២០១៩ | | | |
| សរុប | ១០០,០ | ១០០,០ | ១០០,០ |
| ទឹកម៉ាស៊ីនបណ្ដាញ | ៦,៧ | ១២,៩ | ៣,៦ |
| ទឹកបំពងបណ្ដាញក្នុងទីធ្លា/បរិវេណផ្ទះ | ២,០ | ២,១ | ១,៩ |
| ទឹកបំពង់សាធារណៈ | ១,០ | ១,០ | ១,០ |
| ទឹកអណ្ដូងស្នប់ | ១៤,០ | ៥,១ | ១៨,២ |
| អណ្ដូងជីកមានគម្រប | ៣,៦ | ៣,១ | ៣,៩ |
| អណ្ដូងជីកគ្មានគម្រប | ៣,៦ | ៣,៣ | ៣,៨ |
| ទឹកចេញក្រោមដីមានការការពារ | ០,២ | ០,២ | ០,២ |
| ទឹកចេញក្រោមដីគ្មានការការពារ | ០,៣ | ០,៤ | ០,១ |
| ទឹកភ្លៀង | ១,២ | ១,៣ | ១,២ |
| ទឹកចេញក្រោមដី ទន្លេ អូរ បឹងត្រពាំង។ល។ | ២១,៣ | ២៣,៦ | ២០,២ |
| ទិញទឹកឡានស៊ីទែន | ១១,២ | ១២,៣ | ១០,៦ |
| ទិញទឹកធុងរទេះ | ២៤,៨ | ១៦,០ | ២៩,០ |
| ទឹកដប/ទឹកពិសារដប | ៩,៩ | ១៨,០ | ៦,០ |
| ប្រភពទឹកផ្សេងទៀត | ០,២ | ០,១ | ០,៣ |
| ២០០៨ | | | |
| សរុប | ១០០,០ | ១០០,០ | ១០០,០ |
| ទឹកម៉ាស៊ីនបណ្ដាញ | ៥,០ | ៤,២ | ៥,១ |
| ទឹកអណ្ដូងស្នប់ | ២៩,២ | ៣២,៨ | ២៨,៨ |
| អណ្ដូងជីកមានគម្រប | ៦,៦ | ៤,៤ | ៦,៨ |
| អណ្ដូងជីកគ្មានគម្រប | ១៣,៤ | ៩,៥ | ១៣,៨ |
| ទឹកភ្លៀង | ០,៩ | ១,២ | ០,៩ |
| ទឹកចេញក្រោមដី ទន្លេ អូរ បឹងត្រពាំង។ល។ | ៣៥,៧ | ២៧,៦ | ៣៦,៥ |
| ទឹកទិញ | ៧,៥ | ១៤,៥ | ៦,៨ |
| ប្រភពទឹកផ្សេងទៀត | ១,៧ | ៥,៨ | ១,៣ |

១.*នៅឆ្នាំ ២០០៨ ព័ត៌មានប្រមូលតែទឹកម៉ាស៊ីនបណ្ដាញ ហើយមិនបានបំបែកសម្រាប់អណ្ដូង "ទឹកបំពងបណ្ដាញក្នុងក្នុងទីធ្លា/បរិវេណផ្ទះ" និង "ទឹកបំពង់សាធារណៈ" ឡើយ។
២.*នៅឆ្នាំ ២០០៨ មិនបានព័ត៌មានទាក់ទងនឹង "ទឹកចេញក្រោមដីមានការការពារ " និង "ចេញក្រោមដីគ្មានការការពារ" ឡើយ។
៣.*នៅឆ្នាំ ២០០៨ ព័ត៌មានប្រមូលតែទឹកទិញ ហើយមិនបានបំបែកសម្រាប់ "ទិញទឹកឡានស៊ីទែន" "ទិញទឹកធុងរទេះ" និង "ទឹកដប/ទឹកពិសាដប" ឡើយ។

## ១០.៣.២. ប្រភពបំភ្លឺសំខាន់ៗ

តាមលទ្ធផលការធ្វើជំរឿនប្រជាជនឆ្នាំ២០១៩ គ្រួសារនៅខេត្តឧត្តរមានជ័យភាគច្រើនបានប្រើប្រាស់អគ្គិសនីបណ្ដាញសម្រាប់បំភ្លឺ។ តារាង ១០.៣.២ បានបង្ហាញថាប្រមាណ ៥២,៩ ភាគរយ នៃគ្រួសារនៅខេត្តឧត្តរមានជ័យប្រើប្រាស់អគ្គិសនី (រួមមាន អគ្គិសនីបណ្ដាញ ម៉ាស៊ីនភ្លើង និងទាំងពីរប្រភព) នៅឆ្នាំ២០១៩ បានកើនឡើងខ្លាំងប្រៀបធៀបនឹងឆ្នាំ២០០៨ មាន ១៧,៦ ភាគរយ ។ ដោយឡែកប្រមាណ ៥៨,០ ភាគរយនៃគ្រួសារនៅតំបន់ទីប្រជុំជនប្រើ

ប្រាស់អគ្គិសនីសម្រាប់បំភ្លឺ ចំណែកគ្រួសារនៅជនបទមាន ៥០,៤ ភាគរយ។ តាមតួលេខខាងលើបញ្ជាក់ថារយ:ពេល ជាងមួយទសវត្សរ៍នេះ ភាគច្រើនលើសលប់នៃគ្រួសារខេត្តឧត្តរមានជ័យបានប្រើប្រាស់អគ្គិសនីជាប្រភពបំភ្លឺ ។

### រូប ១០.៣.២. ភាគរយនៃគ្រួសារ តាមប្រភពបំភ្លឺចម្បង និងតំបន់ ខេត្តឧត្តរមានជ័យឆ្នាំ២០១៩




### តារាង ១០.៣.២. ភាគរយនៃគ្រួសារ តាមប្រភពបំភ្លឺចម្បងប្រើប្រាស់ ខេត្តឧត្តរមានជ័យឆ្នាំ២០០៨ និង ២០១៩

| ស្ថានភាពលំនៅដ្ឋាន | សរុប | ទីប្រជុំជន | ជនបទ |
|---|---|---|---|
| (១) | (២) | (៣) | (៤) |
| ២០១៩ | | | |
| សរុប | ១០០,០ | ១០០,០ | ១០០,០ |
| អគ្គិសនីបណ្ដាញ | ៤៦,៣ | ៥០,៧ | ៤៤,២ |
| ម៉ាស៊ីនភ្លើង | ២,៤ | ២,៥ | ២,៤ |
| អគ្គិសនីបណ្ដាញ និងម៉ាស៊ីនភ្លើង | ៤,១ | ៤,៨ | ៣,៧ |
| ប្រេងកាត | ០,៥ | ០,៤ | ០,៥ |
| ទៀន | ០,៥ | ០,៥ | ០,៥ |
| អាគុយថ្មពិល | ៤០,៩ | ៣៨,៧ | ៤១,៩ |
| ផ្សេងទៀត | ៥,៣ | ២,៤ | ៦,៧ |
| ២០០៨ | | | |
| សរុប | ១០០,០ | ១០០,០ | ១០០,០ |
| អគ្គិសនីបណ្ដាញ | ១២,៨ | ៣៧,៤ | ១០,២ |
| ម៉ាស៊ីនភ្លើង | ២,២ | ២,៣ | ២,១ |
| អគ្គិសនីបណ្ដាញ និងម៉ាស៊ីនភ្លើង | ២,៧ | ២,១ | ២,៧ |
| ប្រេងកាត | ៥៨,២ | ៣៩,៤ | ៦០,២ |
| ទៀន | ១,០ | ០,៦ | ១,១ |
| អាគុយថ្មពិល | ២២,២ | ១៨,០ | ២២,៦ |
| ផ្សេងទៀត | ១,០ | ០,០ | ១,១ |

### ១០.៣.៣. បង្គន់អនាម័យ

តាមលទ្ធផលជំរឿនឆ្នាំ២០១៩ ការប្រើប្រាស់បង្គន់អនាម័យនៅខេត្តឧត្តរមានជ័យមានការរីកចម្រើនខ្លាំងក្នុងរយៈពេលមួយទសវត្ស។ តារាង ១០.៣.៣ បានបង្ហាញថានៅឆ្នាំ២០១៩ មាន ៧០,៥ ភាគរយនៃគ្រួសារខេត្តឧត្តរមានជ័យមានបង្គន់អនាម័យ ប្រើប្រាស់ ប្រៀបធៀបនឹងឆ្នាំ២០០៨ បានកើនឡើងយ៉ាងខ្លាំងពី ២១,៤ ភាគរយ ។ គ្រួសារខេត្តឧត្តរមានជ័យឆ្នាំ២០១៩ ជាង ៧ គ្រួសារក្នុងចំណោម ១០ គ្រួសារនៅតំបន់ទីប្រជុំជមានបង្គន់អនាម័យប្រើប្រាស់ និងជិត ៧ គ្រួសារនៅជនបទ។ ក្នុងនោះប្រមាណ ១២,៦ ភាគរយនៃគ្រួសារមានបង្គន់អនាម័យនៅតំបន់ទីប្រជុំជន ប្រើប្រាស់បង្គន់ចាក់ទឹក ឬ(ចុចបង្ហូរទឹក) តភ្ជាប់ទៅប្រព័ន្ធលូ ចំណែកឯនៅជនបទមានត្រឹមតែ ៦,៥ ភាគរយ ប្រមាណ ៤៧,៣ ភាគរយនៃគ្រួសារនៅទីប្រជុំជនបានប្រើប្រាស់បង្គន់ចាក់ទឹក ឬ(ចុចបង្ហូរទឹក) តភ្ជាប់អាងស្តុក ឬរណ្តៅ និងនៅជនបទមាន ៤៧,២ ភាគរយ។

**តារាង ១០.៣.៣. ការបែងចែកភាគរយនៃគ្រួសារ តាមការប្រើប្រាស់បង្គន់ និងប្រភេទបង្គន់ ខេត្តឧត្តរមានជ័យ ឆ្នាំ២០០៨ និង២០១៩**

| ការប្រើប្រាស់បង្គន់ និងប្រភេទបង្គន់ | សរុប | ទីប្រជុំជន | ជនបទ |
|---|---|---|---|
| (១) | (២) | (៣) | (៤) |
| ២០១៩ | | | |
| សរុប | ១០០,០ | ១០០,០ | ១០០,០ |
| គ្រួសារគ្មានបង្គន់ប្រើប្រាស់ | ២៩,៥ | ២៧,៦ | ៣០,៤ |
| បង្គន់ចាក់ទឹក ឬចុចបង្ហូរទឹកតភ្ជាប់ប្រព័ន្ធលូ | ៨,៥ | ១២,៦ | ៦,៥ |
| បង្គន់ចាក់ទឹក ឬចុចបង្ហូរទឹកតភ្ជាប់ទៅបណ្តាញ ឬរណ្តៅ | ៤៧,៣ | ៤៧,៣ | ៤៧,២ |
| បង្គន់ចាក់ទឹក ឬចុចបង្ហូរទឹកទៅកន្លែងផ្សេង (បង្ហូរទឹក អាងស្តុក ឬរណ្តៅ) | ៥,៧ | ៤,០ | ៦,៥ |
| បង្គន់រណ្តៅមានចានបង្គន់សម្រាប់បត់ជើង | ៦,១ | ៦,៦ | ៥,៨ |
| បង្គន់រណ្តៅគ្មានផែនបង្គន់សម្រាប់បត់ជើង | ២,៦ | ១,៦ | ៣,១ |
| បង្គន់បទជើងទន្លាក់ ឬក្នុងទឹក (ត្រពាំង/ បឹង/ទន្លេ/សមុទ្រ) | ០,២ | ០,២ | ០,២ |
| បង្គន់ផ្សេងទៀត | ០,២ | ០,១ | ០,៣ |
| ២០០៨ | | | |
| សរុប | ១០០,០ | ១០០,០ | ១០០,០ |
| គ្រួសារគ្មានបង្គន់ប្រើប្រាស់ | ៧៨,៦ | ៦៦,៤ | ៧៩,៩ |
| បង្គន់ចាក់ទឹក ឬចុចបង្ហូរទឹកតភ្ជាប់ប្រព័ន្ធលូ | ៦,៦ | ៩,០ | ៦,៣ |
| បង្គន់ចាក់ទឹក ឬចុចបង្ហូរទឹកតភ្ជាប់ទៅបណ្តាញ ឬរណ្តៅ | ៩,៤ | ២១,៦ | ៨,១ |
| រណ្តៅ | ៤,៥ | ២,៩ | ៤,៧ |
| បង្គន់ផ្សេងទៀត | ០,៩ | ០,១ | ១,០ |

សម្គាល់ ៖ ១.*នៅឆ្នាំ ២០០៨ មិនមានព័ត៌មាន "បង្គន់ចាក់ទឹក ឬ(មិនបង្ហូរទៅអាងស្តុក ឬរណ្តៅ) បង្ហូរទៅកន្លែងផ្សេង (ចុចបង្ហូរទឹក)" និង "បង្គន់បទជើងទន្លាក់ ឬក្នុងទឹក (ត្រពាំង/បឹង/ទន្លេ/សមុទ្រ)" ឡើយ។

២.*នៅឆ្នាំ ២០០៨ ព័ត៌មានប្រមូលតែបង្គន់ប្រភេទរណ្តៅ ហើយមិនបានបំបែកសម្រាប់ "បង្គន់រណ្តៅមានចានបង្គន់សម្រាប់បត់ជើង" និង "បង្គន់រណ្តៅគ្មានផែនបង្គន់សម្រាប់បត់ជើង" ឡើយ។

## ១០.៣.៤. ឥន្ធនៈសម្រាប់ចម្អិន

តាមរយៈការធ្វើជំរឿនឆ្នាំ២០០៨ និង២០១៩ បានបង្ហាញថានិន្នាការនៃគ្រួសារខេត្តឧត្តរមានជ័យប្រើប្រាស់ឧសសម្រាប់ចម្អិនអាហារមានការថយចុះ ចំណែកឯគ្រួសារដែលប្រើប្រាស់ឧស្ម័នហ្គាសបានកើនឡើងជាលំដាប់។ ទោះបីជាយ៉ាងណាក៏ដោយ ឧសនៅតែជាឥន្ធនៈចម្បងសម្រាប់ចម្អិនអាហារនៅតំបន់ជនបទ។ តារាង ១០.៣.៥ បានបង្ហាញថា ប្រមាណ ៤៥,៧ ភាគរយនៃគ្រួសារខេត្តឧត្តរមានជ័យបានប្រើប្រាស់ឧសសម្រាប់ចម្អិនអាហារ នៅតំបន់ទីប្រជុំជនមានតែ ៣៩,២ ប៉ុណ្ណោះ ប៉ុន្តែបើនៅតំបន់ជនបទ ៤៩,០ ភាគរយ ច្រើនជាងជាងបីរដងបើប្រៀបធៀបនឹងតំបន់ទីប្រជុំជន។ ប្រមាណ ៨,៤ នៃប្រជាជនខេត្តឧត្តរមានជ័យប្រើប្រាស់ឧស្ម័នហ្គាសសម្រាប់ចម្អិនអាហារ ចំណែកឯនៅតំបន់ទីប្រជុំជនវិញមាន ១៣,៤ ភាគរយ និងតំបន់ជនបទមានតែ ៥,៩ ភាគរយ ប៉ុណ្ណោះ។

តារាង ១០.៣.៥. គ្រួសារតាមប្រភេទឥន្ធនៈប្រើប្រាស់ចម្អិនអាហារតាមលំនៅដ្ឋាន ខេត្តឧត្តរមានជ័យឆ្នាំ១៩៩៨ ២០០៨ និង២០១៩

| ប្រភេទឥន្ធនៈប្រើប្រាស់ចម្អិនអាហារ | សរុប | ទីប្រជុំជន | ជនបទ |
|---|---|---|---|
| (១) | (២) | (៣) | (៤) |
| **២០១៩** | | | |
| សរុប | ១០០,០ | ១០០,០ | ១០០,០ |
| ឧស | ៤៥,៧ | ៣៩,២ | ៤៩,០ |
| ធ្យូងឈើ ធ្យូងថ្ម | ៤៣,៣ | ៤៣,៥ | ៤៣,២ |
| ប្រេងកាត | ០,៧ | ០,៩ | ០,៦ |
| ឧស្ម័ន និងហ្គាស | ៨,៤ | ១៣,៤ | ៥,៩ |
| អគ្គិសនី | ១,៧ | ២,៨ | ១,១ |
| គ្មាន | ០,២ | ០,២ | ០,១ |
| ផ្សេងទៀត | ០,១ | ០,១ | ០,០ |
| **២០០៨** | | | |
| សរុប | ១០០,០ | ១០០,០ | ១០០,០ |
| ឧស | ៨១,៤ | ៧៦,២ | ៨១,៩ |
| ធ្យូងឈើ ធ្យូងថ្ម | ១៥,៦ | ១៩,៨ | ១៥,២ |
| ប្រេងកាត | ០,៦ | ០,៩ | ០,៦ |
| ឧស្ម័ន និងហ្គាស | ១,៦ | ២,៥ | ១,៥ |
| អគ្គិសនី | ០,៥ | ០,៤ | ០,៥ |
| គ្មាន | ០,២ | ០,១ | ០,២ |
| ផ្សេងទៀត | ០,១ | ០,០ | ០,១ |

## ១០.៣.៥. ការប្រើប្រាស់អ៊ីនធឺណិត

ជំរឿនឆ្នាំ២០១៩ គ្រួសារនៅក្នុងខេត្តឧត្តរមានជ័យមានការកើនឡើងក្នុងការប្រើប្រាស់អ៊ីនធឺណិតដោយសារតែពិភពលោកមានភាពរីកចម្រើនខ្លាំងនូវវិស័យបច្ចេកវិទ្យា ជាពិសេសទូរស័ព្ទចល័តដែលអាចប្រើប្រាស់ជាមួយនឹងប្រព័ន្ធអ៊ីនធឺណិតបាន ម្យ៉ាងវិញទៀតប្រជាជនខេត្តឧត្តរមានជ័យភាគច្រើនមានប្រើប្រាស់អ៊ីនធឺណិត។ រូប ១០.៣.៦ បានបង្ហាញឲ្យឃើញថា ៥១,៦ ភាគរយនៃគ្រួសារនៅខេត្តឧត្តរមានជ័យមានប្រើប្រាស់អ៊ីនធឺណិត ក្នុងនោះនៅផ្ទះ ២៧,៦

ភាគរយ ប្រើប្រាស់ អ៊ីនធឺណិតនៅទីសាធារណៈ ១,៤ ភាគរយ និងប្រើអ៊ីនធឺណិតនៅផ្ទះ និងសាធារណៈ ២២,៦ ភាគរយ។ ភាគរយនៃគ្រួសារនៅតំបន់ទីប្រជុំជនប្រើប្រាស់អ៊ីនធឺណិតខ្ពស់ជាង(៥២,២ ភាគរយ) បើប្រៀបធៀបទៅនឹងភាគរយនៃគ្រួសារនៅតំបន់ជនបទ (៥១,៣ ភាគរយ)។

រូប ១០.៣.៣. ការបែងចែកភាគរយនៃគ្រួសារតាមការប្រើប្រាស់អ៊ីនធឺណិត តំបន់ ខេត្តឧត្តរមានជ័យឆ្នាំ២០១៩




## ១០.៣.៦. សម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួន

ព័ត៌មានអំពីប្រភេទ និងចំនួនសម្ភារៈប្រើប្រាស់ក្នុងគ្រួសារត្រូវបានប្រមូលក្នុងជំរឿននៅឆ្នាំ ២០០៨ និងឆ្នាំ ២០១៩ ព័ត៌មាននេះបានផ្តល់នូវសូចនាករនៃលក្ខខ័ណ្ឌសេដ្ឋកិច្ចរបស់ប្រជាជនខេត្តឧត្តរមានជ័យ។ លទ្ធផលជំរឿនឆ្នាំ ២០១៩ បានបង្ហាញថា ភាគរយនៃគ្រួសារទូទាំងខេត្តឧត្តរមានជ័យដែលមានទូរទស្សន៍ផ្ទាល់ខ្លួនសម្រាប់ប្រើប្រាស់មាន ៤៨,១ ភាគរយ នៅទីប្រជុំជន មាន ៥៥,៥ ភាគរយ និងនៅជនបទមាន ៤៤,៤ ភាគរយ (តារាង ១០.៣.៦)។ ទន្ទឹមនឹងនេះ ប្រមាណ ៩០,៩ ភាគរយនៃគ្រួសារមានទូរសព្ទ័ដៃនៅទូទាំងខេត្តឧត្តរមានជ័យខណៈដែលគ្រួសារនៅទីប្រជុំជនមាន ៩១,៨ ភាគរយ និងគ្រួសារនៅជនបទមាន ៩០,៥ ភាគរយ។ នៅទីប្រជុំជនគ្រួសារដែលមានម៉ូតូប្រើប្រាស់ផ្ទាល់ខ្លួនប្រមាណ ៧៦,៦ ភាគរយ និងប្រមាណ ៧៥,៧ ភាគរយនៅជនបទ។ ចំណែកឯគ្រួសារដែលមានរថយន្ត(រថយន្តដឹកទំនិញធុនតូចឬធំ ឬរថយន្តសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន) មានតែ ៧,៣ ភាគរយប៉ុណ្ណោះនៅខេត្តឧត្តរមានជ័យ។ កង់ជាកម្មសិទ្ធិប្រើប្រាស់ផ្ទាល់ខ្លួនមាន ៤៧,៦ ភាគរយនៃគ្រួសារនៅទីប្រជុំជន និងនៅជនបទមាន ៥៥,៦ ភាគរយ។ យោងតាមលទ្ធផលខាងលើអាចនិយាយបានថា ម៉ូតូនៅតែជាមធ្យោបាយធ្វើដំណើរពេញនិយមរបស់ប្រជាជនខេត្តឧត្តរមានជ័យជាពិសេសនៅទីប្រជុំជន។ ចំណែកឯទូរទស្សន៍ នៅតែជាការពេញនិយមរបស់ប្រជាជនខេត្តឧត្តរមានជ័យទាំងនៅទីប្រជុំជន និងជនបទ ដោយសារតែមានការកើនឡើងនៃភាគរយគ្រួសារបានប្រើប្រាស់អគ្គិសនីនៅទូទាំងប្រទេសនេះបង្ហាញឲ្យឃើញពីការផ្លាស់ប្តូរជីវភាពរស់នៅរបស់ប្រជាជនខេត្តឧត្តរមានជ័យ។

## តារាង ១០.៣.៦. ការបែងចែកគ្រួសារ តាមប្រភេទ និងចំនួនឧបករណ៍ប្រើប្រាស់ផ្ទាល់ខ្លួន ខេត្តឧត្តរមានជ័យ ឆ្នាំ២០០៨ និង ២០១៩

| ប្រភេទសម្ភារៈប្រើប្រាស់ | សរុប | ទីប្រជុំជន | ជនបទ |
|---|---|---|---|
| (១) | (២) | (៣) | (៤) |
| ២០១៩ | | | |
| វិទ្យុ/ម៉ាញ៉េ | ១០,១ | ១០,៥ | ៩,៩ |
| ទូរទស្សន៍ | ៤៨,១ | ៥៥,៥ | ៤៤,៤ |
| ទូរស័ព្ទលើតុ | ១,១ | ១,១ | ១,១ |
| ទូរស័ព្ទដៃ | ៩០,៩ | ៩១,៨ | ៩០,៥ |
| កុំព្យូទ័រផ្ទាល់ខ្លួន | ៤,៩ | ៦,៨ | ៤,០ |
| កង់ | ៤៦,២ | ៤៧,៦ | ៤៥,៦ |
| ម៉ូតូ | ៧៦,០ | ៧៦,៦ | ៧៥,៧ |
| ទូរទឹកកក | ៨,៨ | ១៤,៧ | ៥,៩ |
| ម៉ាស៊ីនបោក | ៤,៥ | ៨,៣ | ២,៦ |
| កង្ហារ | ៦៨,៩ | ៦៨,៧ | ៦៩,០ |
| ម៉ាស៊ីនត្រជាក់ | ២,៤ | ៥,០ | ១,២ |
| រថយន្ត/រថយន្តដឹកទំនិញធុនតូច/ធំ | ៧,៣ | ១០,១ | ៥,៩ |
| ទូក/កាណូត | ០,៦ | ០,៣ | ០,៧ |
| ត្រាក់ទ័រធុនធំ/តូច | ២,៣ | ១,៦ | ២,៦ |
| គោយន្ត | ៣៨,៦ | ២៨,៤ | ៤៣,៥ |
| ២០០៨ | | | |
| វិទ្យុ/ម៉ាញ៉េ | ៣១,៥ | ៣៨,៩ | ៣០,៧ |
| ទូរទស្សន៍ | ៣៣,០ | ៤៧,៤ | ៣១,៥ |
| ទូរស័ព្ទលើតុ | ០,៧ | ០,៨ | ០,៧ |
| ទូរស័ព្ទដៃ | ២៧,៤ | ៣៩,១ | ២៦,២ |
| កុំព្យូទ័រផ្ទាល់ខ្លួន | ១,០ | ៣,១ | ០,៨ |
| កង់ | ៥២,៣ | ៧០,៣ | ៥០,៤ |
| ម៉ូតូ | ៣៥,២ | ៤៧,០ | ៣៤,០ |
| រថយន្ត/រថយន្តដឹកទំនិញធុនតូច/ធំ | ២,៥ | ៤,៣ | ២,៣ |
| ទូក/កាណូត | ០,៤ | ០,១ | ០,៥ |
| ត្រាក់ទ័រធុនធំ/តូច | ០,២ | ០,៥ | ០,២ |
| គោយន្ត | ១៣,៥ | ១១,៧ | ១៣,៧ |

# ជំពូក ១១

# សេចក្តីសង្ខេប និងការសន្និដ្ឋាន

## ១១.១. សូចនាករប្រជាសាស្ត្រ

តាមលទ្ធផលចុងក្រោយនៃជំរឿនទូទៅប្រជាជនខេត្តឧត្តរមានជ័យ ឆ្នាំ២០១៩ មាន ២៧៦.០៣៨ នាក់ ក្នុងនោះ តំបន់ទីប្រជុំជន មាន ៩១.២៩៨ នាក់ ឬ ៣៣,១ ភាគរយ និងជនបទមាន ១៨៤.៧៤០ នាក់ ឬ ៦៦,៩ ភាគរយ។

លទ្ធផលចុងក្រោយនៃជំរឿនទូទៅប្រជាជននៅខេត្តឧត្តរមានជ័យ ឆ្នាំ២០១៩ តាមវិធីសាស្ត្រឃើញរាប់ ចំនួនប្រជាជនខេត្តឧត្តរមានជ័យសរុបកើនឡើងត្រឹមតែ ៩.២១៩ នាក់ ត្រូវនឹង ៤៨,៦ ភាគរយ ក្នុងរយៈពេល ១១ ឆ្នាំ ចន្លោះឆ្នាំ២០១៨ និង ២០១៩ ក្នុងអត្រាកំណើនប្រចាំឆ្នាំ ៣,៦ ភាគរយ។

## ១១.២. ការបែងចែកប្រជាជន

យោងតាមលទ្ធផលចុងក្រោយនៃជំរឿនទូទៅប្រជាជននៅខេត្តឧត្តរមានជ័យ ឆ្នាំ២០១៩ តាមវិធីសាស្ត្រឃើញរាប់ ដង់ស៊ីតេប្រជាជនខេត្តឧត្តរមានជ័យ មាន ៤៥ នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េកើនឡើង ១៥ នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ ពី ៣០ នាក់ នៅឆ្នាំ ២០០៨ ។

ដង់ស៊ីតេប្រជាជនស្រុកអន្លង់វែងមានខ្ពស់ជាងគេ (១៤២ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ) ក្រុងសំរោង (៧៥ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ) ស្រុកត្រពាំងប្រាសាទ (៤៤ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ) ស្រុកបន្ទាយមាស (១៩៧ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ) ស្រុកបន្ទាយអំពិល (៣៦ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ) ដោយឡែកស្រុកចុងកាល់មានដង់ស៊ីតេប្រជាជនទាបជាងគេ (២៣ នាក់ និង៧៧ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ)

៩៩,៥ ភាគរយ កាន់ព្រះពុទ្ធសាសនា។ ក្រុមសាសនាដែលធំជាងគេបន្ទាប់ គឺអ្នកកាន់សាសនាឥស្លាមមានប្រមាណជា ០,២ ភាគរយ។ សាសនាគ្រឹស្ទ និងសាសនាផ្សេងទៀតមាន ០,៣ ភាគរយ។ អ្នកកាន់សាសនាគ្រឹសាសនាផ្សេងទៀតមានតិចក្នុងចំណោមប្រជាជនសរុបខេត្តឧត្តរមានជ័យ ។

## ១១.៣. អត្រាភេទ និងរចនាសម្ព័ន្ធអាយុ

រចនាសម្ព័ន្ធអាយុរបស់ប្រជាជនខេត្តឧត្តរមានជ័យវ៉ៃក្មេងនៅឡើយដែលប្រជាជនអាយុក្រោម ១៥ ឆ្នាំ មានរហូតដល់ ៣៣,៧ ភាគរយ និងអាយុ ៦០ ឆ្នាំឡើង មានប្រមាណ ៥,៩ ភាគរយ។ តារាងបង្ហាញអំពីមេដ្យានអាយុ ២៣ ឆ្នាំ នៅឆ្នាំ២០១៩ ។ មេដ្យានអាយុនៃជំរឿនឆ្នាំ២០០៨ មានតែ ១៩ ឆ្នាំ ដូច្នេះមេដ្យានអាយុប្រជាជនមានអាយុកើនឡើង ៤ ឆ្នាំ ក្នុងរយៈពេល ១១ ឆ្នាំ។ផលធៀបភេទ ឬអត្រាភេទនៅខេត្តឧត្តរមានជ័យមាន ១០២,០ យោងតាមលទ្ធផលចុងក្រោយជំរឿនទូទៅនៅខេត្តឧត្តរមានជ័យ ឆ្នាំ២០១៩។ ចំនួនស្ត្រីតិចជាងចំនួនបុរស ក្នុងចំណោមប្រជាជនខេត្តឧត្តរមានជ័យ។

## ១១.៤. ស្ថានភាពអាពាហ៍ពិពាហ៍

ជំរឿនឆ្នាំ២០១៩ បច្ចុប្បន្នរៀបការមានសមាមាត្រខ្ពស់ជាងគេប្រមាណ ៧០,៧ ភាគរយនៃចំនួនប្រជាជនអាយុចាប់ពី ១៥ ឆ្នាំឡើង។ ប្រជាជនមិនដែលរៀបការមាន ២៤,៧ ភាគរយនៃប្រជាជនអាយុចាប់ពី ១៥ ឆ្នាំឡើង។ សមាមាត្រស្ត្រីមេម៉ាយមានប្រមាណ ៤,៦ ភាគរយ។ ទោះជាយ៉ាងណាក៏ដោយ ស្ត្រីមេម៉ាយ លែងលះគ្នា និងទំនាស់រស់នៅផ្សេងគ្នាមានចំនួនច្រើនជាងបុរស។ ជាលទ្ធផលបុរសមានអត្រាស្លាប់ខ្ពស់ជាងស្ត្រី។ លើសពីនេះទៀតបានបញ្ជាក់ថាបុរសមានទំនោរក្នុងការរៀបការម្តងទៀតច្រើនជាងស្ត្រី ។ ២៥ សម្រាប់បុរស និង ២២ សម្រាប់ស្ត្រី ដោយផ្អែកលើការបែងចែកអាយុក្នុងជំរឿនឆ្នាំ២០១៩ របស់ប្រជាជនមិនដែលរៀបការនៅខេត្តឧត្តរមានជ័យ។ អាយុមធ្យមរៀបការលើកទីមួយតាមបុរសខ្ពស់ជាងស្ត្រី។ ភាពខុសគ្នានេះ ក្នុងចំណោមស្ត្រីនៅទីប្រជុំជន និងស្ត្រីនៅជនបទមាន ១,០ ឆ្នាំ។ បុរសនៅទីប្រជុំជនហាក់ដូចជាមាននិន្នាការរៀបការយឺតជាងបុរសនៅជនបទ។

## ១១.៥. អក្ខរភាព និងការអប់រំ

អត្រាអក្ខរភាពសម្រាប់ភាសាណាមួយក្នុងចំណោមប្រជាជនខេត្តឧត្តរមានជ័យ អាយុ ៧ ឆ្នាំឡើង បានកើនឡើងពី ៦៥,៥ ភាគរយ នៅឆ្នាំ២០០៨ ទៅ ៨១,៧ នៅឆ្នាំ២០១៩។ ក្នុងរយៈពេល ១១ ឆ្នាំ អត្រាអក្ខរភាពរបស់ស្ត្រីបានកើនឡើងប្រមាណ ១៩,៧ ភាគរយ បើធៀបទៅនឹងការកើនឡើងប្រមាណ ១២,៨ ភាគរយ សម្រាប់បុរស។ ទោះជាយ៉ាងណាក៏ដោយគំលាតដ៏ធំរវាងអក្ខរភាពបុរស និងស្ត្រី (៨៥,៧ ភាគរយ សម្រាប់បុរស និង ៧៧,៧ ភាគរយ សម្រាប់ស្ត្រីក្នុងឆ្នាំ២០១៩) ខ្ពស់នៅជនបទ។ ក្រៅពីភាសាខ្មែរ ប្រជាជនខេត្តឧត្តរមានជ័យមួយចំនួនក៏ចេះភាសាផ្សេងទៀតផងដែរ ក្នុងនោះភាសាផ្សេងទៀតក្រៅពីភាសាខ្មែរ ០,៦ ភាគរយ សម្រាប់ចេះតែភាសាខ្មែរមាន ៩៤,៣ ភាគរយ ភាសាខ្មែរ និងអង់គ្លេសមាន ៣,១ ភាគរយ ខ្មែរនិងភាសាផ្សេងទៀត ក្រៅពីភាសាអង់គ្លេសមាន ២,០ ភាគរយ ។

អត្រាអក្ខរភាពមនុស្សពេញវ័យត្រូវបានកំណត់សម្រាប់អាយុ ១៥ ឆ្នាំឡើង ដែលចេះអាន និងចេះសរសេរឃ្លាសាមញ្ញជាភាសាណាមួយ។ អត្រាអក្ខរភាពមនុស្សពេញវ័យបានកើនឡើងរវាងឆ្នាំ ២០០៨-២០១៩ ។ អត្រាអក្ខរភាពមនុស្សពេញវ័យបានកើនឡើងរវាងឆ្នាំ ២០០៨-២០១៩ (តារាង ៤.៣.១) ។ អត្រានេះបានកើនឡើងនៅតំបន់ជនបទ (៦២,៥ ភាគរយ ក្នុងឆ្នាំ ២០០៨ ទៅ ៧៨,៥ ភាគរយក្នុងឆ្នាំ២០១៩) ហើយស្ត្រីមានកំណើនខ្ពស់ជាងបុរសរវាងឆ្នាំ ២០០៨ និង ២០១៩ ។ មានការផ្លាស់ប្តូរគួរឲ្យកត់សម្គាល់នៅក្នុងតំបន់ទីប្រជុំជនដែលអត្រាអក្ខរភាពមនុស្សពេញវ័យឆ្នាំ ២០០៨ មាន ៧៤,៦ ភារយ កើនដល់ ៨១,៨ ភាគរយនៅឆ្នាំ ២០១៩ ។

២៨,៥ ភាគរយនៃប្រជាជនអាយុ ៧ ឆ្នាំឡើង ដែលធ្លាប់បានចូលរៀននៅសាលា ឬគ្រឹះស្ថានសិក្សាណាមួយបានបញ្ចប់ថ្នាក់បឋមសិក្សា ហើយ ១៧,៧ ភាគរយ បានបញ្ចប់ថ្នាក់មធ្យមសិក្សាបឋមភូមិ មាន ១,៧ ភាគរយ បានបញ្ចប់មធ្យមសិក្សា/មានសញ្ញាបត្រ (បានបញ្ចប់មធ្យមសិក្សា/មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សញ្ញប័ត្រមធ្យមសិក្សាបឋមភូមិមានបច្ចេកទេស/វិជ្ជាជីវៈ សញ្ញប័ត្រមធ្យមសិក្សាទុតិយភូមិមានបច្ចេកទេស/វិជ្ជាជីវៈ) និងបានបញ្ចប់ក្រោយមធ្យមសិក្សា (សញ្ញាបត្រថ្នាក់មហាវិទ្យាល័យ សញ្ញាបត្រថ្នាក់អនុបណ្ឌិត និងសញ្ញាបត្រថ្នាក់បណ្ឌិត) មានតែ

០,៨ ភាគរយ។ មានប្រមាណ ៥០,២ ភាគរយនៃប្រជាជនខេត្តឧត្តរមានជ័យអាយុ ៧ ឆ្នាំឡើង មិនបានបញ្ចប់ថ្នាក់បឋមសិក្សា ខណៈដែលមានសមាមាត្រតិច (១,០ ភាគរយ) នៃប្រជាជនអក្ខរភាពមិនបានបញ្ចប់ថ្នាក់ណាមួយ។

ក្រុមអាយុ ១៥-១៩ ឆ្នាំ ជាទូទៅគួរបញ្ចប់ថ្នាក់កម្រិតមធ្យមសិក្សាបឋម ប៉ុន្តែពិនិត្យឃើញថា ២១,០ ភាគរយក្នុងក្រុមអាយុ ១៥-១៩ ឆ្នាំ នៅមិនទាន់បានបញ្ចប់កម្រិតបឋមសិក្សា អាចដោយមូលហេតុចុះឈ្មោះចូលរៀនយឺត ឬត្រួតថ្នាក់ ឬឈប់រៀន។ ក្នុងក្រុមអាយុដដែល ១៥-១៩ ឆ្នាំ មាន ៤៧,០ ភាគរយ និង ៣១,០ ភាគរយ បានបញ្ចប់កម្រិតបឋមសិក្សា និងកម្រិតមធ្យមសិក្សាបឋមភូមិ តាមលំដាប់រៀង។ គួរកត់សម្គាល់ផងដែរ ប្រមាណ ០,៩ ភាគរយ ក្នុងក្រុមអាយុនេះបានបញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិ/សញ្ញាបត្រ។

ចំណោមប្រជាជនក្នុងក្រុមអាយុ ២០-២៤ ឆ្នាំ មិនបានបញ្ចប់កម្រិតបឋមសិក្សាមាន ២៨,៦ ភាគរយបានបញ្ចប់កម្រិតបឋមសិក្សា ៣៦,៦ ភាគរយ បញ្ចប់មធ្យមសិក្សាបឋមភូមិ ២៩,០ ភាគរយ បញ្ចប់មធ្យមសិក្សា/មានសញ្ញាបត្រ (បញ្ចប់មធ្យមសិក្សា/មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សញ្ញាបត្រមធ្យមសិក្សាបឋមភូមិមានបច្ចេកទេស/វិជ្ជាជីវៈ សញ្ញប័ត្រមធ្យមសិក្សាទុតិយភូមិមានបច្ចេកទេស/វិជ្ជាជីវៈ) និងបានបញ្ចប់ក្រោយមធ្យមសិក្សា (សញ្ញាបត្រ ថ្នាក់មហាវិទ្យាល័យ សញ្ញាបត្រថ្នាក់អនុបណ្ឌិត និងសញ្ញាបត្រថ្នាក់បណ្ឌិត) ៥,០ និង ០,៧ ភាគរយ តាមលំដាប់រៀង។

## ១១.៦. កម្លាំងពលកម្ម និងការងារ

អត្រាសកម្មភាពសេដ្ឋកិច្ច ឬអត្រាចូលរួមកម្លាំងពលកម្ម (LFPR) ខេត្តឧត្តរមានជ័យក្នុងចំណោមប្រជាជនអាយុ ១៥ ឆ្នាំឡើងបានកើនឡើងពី ៨៣,៥ ភាគរយ នៅឆ្នាំ២០០៨ មក ៨៦,៧ ភាគរយ នៅឆ្នាំ២០១៩ អាចមកពីការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចលើគ្រប់វិស័យរបស់ប្រទេសនាពេលបច្ចុប្បន្ន។ អត្រាចូលរួមសកម្មភាពសេដ្ឋកិច្ចនៅជនបទខ្ពស់ជាងទីប្រជុំជនទាំងប្រុស និងស្រី អាចមកពីអត្រាចូលរួមខ្ពស់ក្នុងការងារកសិកម្មនៅជនបទ និងអត្រាចូលរួមក្នុងការសិក្សាខ្ពស់របស់កុមារនៅទីប្រជុំជន។

អត្រាមានការងារធ្វើត្រូវបានកំណត់ជាភាគរយនៃអ្នកមានការងារធ្វើទៅនឹងចំនួនប្រជាជនសរុបនៅក្នុងកម្លាំងពលកម្ម មាន ៩៨, ៥ ភាគរយ នៅឆ្នាំ២០០៨ និង ៩៩,៧ ភាគរយ នៅឆ្នាំ២០១៩ នៅខេត្តឧត្តរមានជ័យ។

អត្រាគ្មានការងារធ្វើក្នុងក្រុមអាយុ ១៥ ឆ្នាំឡើង នៅខេត្តឧត្តរមានជ័យមាន ០,៣ ភាគរយ នៅឆ្នាំ២០១៩។ អត្រាអ្នកគ្មានការងារថយក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ។ នៅឆ្នាំ២០១៩ អត្រាគ្មានការងារធ្វើក្នុងចំណោមប្រុសមាន ០,៣ ភាគរយ និងស្រី ០,៤ ភាគរយ។ នៅថ្នាក់ខេត្ត អត្រាគ្មានការងារធ្វើមាន ៣ នាក់ ក្នុងចំណោមកម្លាំងពលកម្ម ១.០០០ នាក់គិតជាចំនួនដាច់ខាតអ្នកគ្មានការងារធ្វើជាង ៥ រយនាក់ ។

លទ្ធផលចុងក្រោយជំរឿនទូទៅប្រជាជននៅខេត្តឧត្តរមានជ័យ ឆ្នាំ២០១៩ បានឲ្យដឹងថាអ្នកធ្វើការងារឲ្យគ្រួសារមិនយកប្រាក់ឈ្នួល និងអ្នកធ្វើការងារដោយទុនផ្ទាល់ខ្លួន ៨៤,៦ ភាគរយនៃប្រជាជនមានការងារធ្វើនៅខេត្តឧត្តរមានជ័យ ឆ្នាំ២០១៩ ។ អ្នកធ្វើការដោយទុនផ្ទាល់ខ្លួន ៣៩,៦ ភាគរយ ហើយភាគច្រើននៃអ្នកធ្វើការនេះនៅខេត្ត

ឧត្តរមានជ័យនៅក្នុងវិស័យក្រៅប្រព័ន្ធ។ សមាមាត្រស្រីធ្វើការក្នុងវិស័យក្រៅប្រព័ន្ធខ្ពស់ជាងប្រុស។ ប្រមាណ ៥២,៧ ភាគរយនៃអ្នកធ្វើការប្រុសជាអ្នកធ្វើការដោយទុនផ្ទាល់ខ្លួន។ ស្រីធ្វើការអ្នកធ្វើការឲ្យគ្រួសារមិនយកប្រាក់ឈ្នួលមានសមាមាត្រខ្ពស់ (៦៥,៩ ភាគរយ)។

ភាគច្រើននៃប្រជាជននៅថ្នាក់ខេត្តមានការងារធ្វើនៅផ្នែកសហគ្រាសឯកជនក្នុងស្រុកមាន (៨៩,៨ ភាគរយ) បន្ទាប់មកការងាររដ្ឋាភិបាល (៧,៨ ភាគរយ) ការងារសហគ្រាសបរទេស (១,៥ ភាគរយ) និងការងារក្នុងផ្នែកប្រាំផ្សេងទៀតមានតែ (១,០ ភាគរយ) ប៉ុណ្ណោះ។

អ្នកមានការងារធ្វើភាគច្រើននៅក្នុងសេដ្ឋកិច្ចខេត្តឧត្តរមានជ័យ មានមុខរបរជំនាញកសិកម្ម ព្រៃឈើ និងនេសាទ ប្រមាណ ៧៥,២ ភាគរយ អ្នកធ្វើការងារខាងសេវាកម្ម និងលក់ដូរ ៧,៨ ភាគរយ និងកម្លាំងប្រដាប់អាវុធ ៤,៧ ភាគរយ។

នៅឆ្នាំ២០១៩ អ្នកមានការងារធ្វើទាំងអស់ក្នុងវិស័យ "កសិកម្ម ព្រៃឈើ និងនេសាទ" បានថយចុះមក ៧៦,១ ភាគរយ។ ក្រុមវិស័យការងារផ្សេងទៀតមានភាគរយខ្ពស់ដូចជាផលិតកម្ម កើនពី ១,៥ ភាគរយមក ១,៧ ភាគរយ ពាណិជ្ជកម្មលក់ដុំ និងរាយ ជួសជុលរថយន្ត និងទោចក្រយានយន្ត" កើនពី ៥,៦ ភាគរយមក ៧,២ ភាគរយ សំណង់ ១,៣ មក ២,០ ភាគរយ និងក្រៅពីនេះ វិស័យការងារផ្សេងទៀតមានភាគរយទាបក្នុងវិស័យការងារនៅខេត្តឧត្តរមានជ័យ។

## ១១.៧. ទេសន្តរប្រវេសន៍

យោងតាមលទ្ធផលជំរឿនប្រជាជន ឆ្នាំ២០១៩ ប្រមាណ ៦២,៧ ភាគរយនៃប្រជាជនខេត្តឧត្តរមានជ័យមិនដែលមានទីលំនៅផ្សេងក្រៅពីកន្លែងធ្វើសម្ភាស ។ នៅតំបន់ទីប្រជុំជនមានប្រហាក់ប្រហែលជនបទ (៥៩,៣ ភាគរយ និង ៦៤,៤ ភាគរយ)។ និយាយដោយឡែកភាគរយនៃទេសន្តរប្រវេសន៍នៅខេត្តឧត្តរមានជ័យឆ្នាំ ២០១៩ មាន ៣៧,៣ ភាគរយ តំបន់ទីប្រជុំជនមាន ៤០,៧ ភាគរយ និងនៅតំបន់ជនបទមាន ៣៥,៦ ភាគរយ។

ទេសន្តរប្រវេសន៍ភាគច្រើនទាំងពីរភេទមានទីលំនៅពីមុននៅក្នុងខេត្តសម្ភាសន៍ (៦២,២ ភាគរយ)។ ម៉្យាងទៀតចលនាទេសន្តរប្រវេសន៍ដែលកំពុងលេចធ្លោនាបច្ចុប្បន្នគឺរវាងខេត្ត និងខេត្តផ្សេងទៀត។

មូលហេតុចម្បងសម្រាប់ទេសន្តរប្រវេសន៍ផ្តល់ដោយអ្នកសម្ភាសន៍នៅក្នុងជំរឿនគឺគ្រួសារផ្លាស់ទីលំនៅ ។ មូលហេតុសម្រាប់ទេសន្តរប្រវេសន៍នេះ អនុវត្តចំពោះសមាជិកគ្រួសារដែលបានផ្លាស់ទៅកន្លែងសម្ភាសន៍ពីទីលំនៅមុនដោយសារគ្រួសារទាំងមូលបានផ្លាស់ទីលំនៅ។ ជំរឿនឆ្នាំ២០១៩ បានឲ្យដឹងថាចរន្តទេសន្តរប្រវេសន៍ភាគច្រើនគឺនៅតែទីជនបទទៅជនបទ និងពីទីប្រជុំជនទៅជនបទដែលជាលំដាប់ទី២នៅតែជាចរន្តដ៏សំខាន់នាពេលបច្ចុប្បន្ន ។ ការប្រែប្រួលនេះលឿន និងការវិវត្តន៍ដ៏ខ្លាំងនៃការធ្វើនគរូបនីយកម្មទីប្រជុំជន។

ភាគច្រើននៃទេសន្តរប្រវេសន៍បានរស់នៅកន្លែងសម្ភាសន៍យ៉ាងហោចណាស់១០ឆ្នាំ មុនពេលធ្វើជំរឿន (៥៤,២ ភាគរយ)។ សមាមាត្រអ្នកដែលរស់នៅទីលំនៅបច្ចុប្បន្នរបស់ពួកគេពី ១-៤ ឆ្នាំ មុនពេលធ្វើជំរឿន ១៧,៤ ភាគរយ។ នៅទីប្រជុំជនទេសន្តប្រវេសន៍មានភាគរយខ្ពស់ជាងនៅជនបទ ។ ទោះបីជាយ៉ាងណាក៏ដោយនៅជនបទមានភាគរយទាបជាងនៅតំបន់ទីប្រជុំជន (ក្នុងរង្វង់ ១៦,៩ ភាគរយ) ។

ដូចដែលបានរំពឹងទុក ប្រជាជនភាគច្រើនបានធ្វើទេសន្តរប្រវេសន៍ក្នុងអាយុធ្វើការចន្លោះពី ១៥ ទៅ ៣៩ ឆ្នាំ។ យោងតាមលទ្ធផលជំរឿនឆ្នាំ២០១៩ ជាងសែសិបប្រាំបួនភាគរយនៃទេសន្តរប្រវេសន៍ស្ថិតក្នុងក្រុមអាយុនេះទាំងប្រុស និងស្រី។ ប្រមាណជាង ៩០ ភាគរយនៃជនទេសន្តរប្រវេសន៍ស្ថិតក្នុងក្រុមអាយុ ១៥-៦៤ ឆ្នាំ ទាំងក្នុងចំណោមប្រុស និងស្រី។

ភាគរយខ្ពស់នៃទេសន្តរប្រវេសន៍ចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចពេលគឺ ៨៩,៧ ភាគរយ ។ មានភាគរយខ្ពស់នៃទេសន្តរប្រវេសន៍ចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចនៅជនបទតែទោះជាយ៉ាងក៏ដោយភាគរយនៃទេសន្តរប្រវេសន៍ដែលនៅសល់ភាគច្រើនបានចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចនៅទីប្រជុំជន។ ពួកគេភាគច្រើនធ្វើការក្នុងផ្នែកផលិតកម្ម (២,៩ ភាគរយ) ពាណិជ្ជកម្មលក់ដុំនិងរាយ ជួសជុលរថយន្ត និងទោចក្រយានយន្ត (១៥,០ ភាគរយ) សំណង់ (៤,២ ភាគរយ) ដឹកជញ្ជូន និងឃ្លាំង (២,៥ ភាគរយ) និងសកម្មភាពរដ្ឋបាល និងសេវាកម្មគាំទ្រ (៧,៧ ភាគរយ) នៅទីប្រជុំជន។

## ១១.៨. លទ្ធភាពបង្កើតកូន

អត្រាលទ្ធភាពបង្កើតកូនសរុប (TFR) នៅខេត្តឧត្តរមានជ័យ មាន ២,៩ សម្រាប់ស្ត្រីម្នាក់។ ជាទូទៅអត្រាលទ្ធភាពបង្កើតកូននៅខេត្តឧត្តរមានជ័យ គឺទាបនៅតំបន់ទីប្រជុំជននិងជនបទ។ អត្រាលទ្ធភាពបង្កើតកូនសរុបខុសគ្នាតិចតួចគឺ ៣,០ ទល់នឹង ២,៩ សម្រាប់ស្ត្រីម្នាក់។

## ១១.៩. មរណភាព

តាមលទ្ធផលជំរឿនឆ្នាំ២០១៩ អត្រាមរណភាពទារក នៅខេត្តឧត្តរមានជ័យ មាន ១៨,៩ នាក់ ក្នុងចំណោម ១.០០០ កំណើតរស់។ អត្រាមរណភាពទារកខុសគ្នានៅតំបន់ទីប្រជុំជន និងជនបទ គឺ ២១,៨ និង ១៧,៤ ក្នុងចំណោម ១.០០០ កំណើតរស់។ អត្រាមរណភាពទារកប្រុសខ្ពស់ជាងអត្រាមរណភាពទារកស្រី គឺ ២០,៥ និង ១៧,២ ។

អាយុកំណើតសង្ឃឹមរស់នៅខេត្តឧត្តរមានជ័យ មាន ៧៣,៧ ក្នុងនោះ ប្រុសមាន ៧៣,១ និងស្រីមាន ៧៥,៨ ។

## ១១.១០. ពិការភាព

ទិន្នន័យអំពីពិការភាពទាំងប្រាំមួយប្រភេទ ដែលបានប្រមូលក្នុងជំរឿនទូទៅប្រជាជននៅខេត្តឧត្តរមានជ័យ ឆ្នាំ ២០១៩ បង្ហាញពីអត្រាពិការភាព បែងចែកតាម ភេទ តំបន់។ អត្រាពិការភាពអាយុ ៥ ឆ្នាំឡើង នៅឧត្តរមានជ័យ សម្រាប់កម្រិតពិការណាមួយមាន ៤,៨ ភាគរយ ។ អត្រាពិការខ្លាំងក្នុងចំណោមប្រជាជនឧត្តរមានជ័យនៅមានកម្រិតទាបត្រឹម ០,៨ ភាគរយ ដោយផ្នែកពិការធ្ងន់ធ្ងរធ្វើអ្វីមិនកើតមានអត្រាទាបបំផុតក្នុងចំណោមប្រជាជនឧត្តរមានជ័យ ០,២ ភាគរយ។ បែងចែកតាមភេទ ស្ត្រីមានអត្រាជិត ១,០ ភាគរយខ្ពស់ជាងបុរស (៤,៤ ភាគរយ ទល់នឹង ៥,២ ភាគរយ) ដែលទម្រង់នេះស្របគ្នានឹងកម្រិតអត្រាពិការខ្លាំង។ បែងចែកតាមតំបន់នៅអត្រាពិការក្នុងកម្រិតណាមួយនៅជនបទខ្ពស់ជាងអត្រាពិការនៅតំបន់ទីប្រជុំជន (៤,៥ ភាគរយ ទល់នឹង ៥,០ ភាគរយ)។

ក្នុងចំណោមប្រជាជនពិការទាំងអស់ ១១.៩៣១នាក់ ក្នុងនោះពិការខ្លះៗមាន ៧៩,៧ ភាគរយ ពិការខ្លាំងមាន ១៦,៥ ភាគរយ និងពិការមិនអាចធ្វើអ្វីបានសោះមាន ៣,៧ ភាគរយ ។

នៅគ្រប់កម្រិតនៃពិការអត្រាស្ថិតក្នុងកម្រិតពី ៦,១ ភាគរយ សម្រាប់ក្រុមអាយុ ៥-១៤ ឆ្នាំ ទៅ ៣៧,៩ ភាគរយ សម្រាប់ក្រុមអាយុ ៦០ ឆ្នាំឡើង។ អត្រាជនពិការបានចាប់ផ្ដើមកើនបន្តិចនៅក្នុងក្រុមអាយុរយៈកណ្ដាលពី ១៤,៤ ភាគរយ សម្រាប់ក្រុមអាយុ ១៥-៣៤ ឆ្នាំទៅ ៤១,៦ ភាគរយសម្រាប់អាយុ ៣៥-៥៩ ឆ្នាំ ។

សមាមាត្រក្នុងចំណោមជនពិការ តាមរយៈការមើលសូម្បីពាក់វ៉ែនតាក្ដី (៣,៦ ភាគរយ) មានអត្រាខ្ពស់ជាងប្រភេទពិការផ្សេងទៀត។ ប្រភេទពិការផ្សេងទៀតមាននៅក្នុងកម្រិតពី ១,៨ ភាគរយ (សម្រាប់ពិការពិការក្នុងការថែទាំខ្លួន ដូចជាងូតទឹក ឬស្លៀកពាក់ និងពិការក្នុងការនិយាយ ដូចជាយល់អ្នកដទៃ ឬឲ្យអ្នកដទៃយល់) ទៅ ២,៦ ភាគរយ (ពិការក្នុងការស្ដាប់សូម្បីតែប្រើឧបករណ៍ជំនួយ) ។

## ១១.១១. លក្ខណៈផ្ទះសំបែង និងគ្រួសារ

ខេត្តឧត្តរមានជ័យមាន ៩៤,៩ ភាគរយនៃអាគារជាលំនៅដ្ឋានសំរាប់ស្នាក់នៅ។ សមាមាត្រនៅតំបន់ទីប្រជុំជន និងជនបទ មានចំនួន ៩៣,៨ ភាគរយ និង ៩៥,៤ ភាគរយ តាមលំដាប់រៀង។ ប្រភេទអាគារ ដែលជាលំនៅដ្ឋានផង និងប្រើប្រាស់សំរាប់គោលបំណងផ្សេងទៀតមានសមាមាត្រខ្ពស់នៅតំបន់ទីប្រជុំជនជាងជនបទ។

ប្រមាណ ៤,៩ ភាគរយនៃអាគារលំនៅដ្ឋាន ជាសំណង់មានលក្ខណៈពាក់កណ្ដាលអចិន្ត្រៃយ៍ និង ១,៤ ភាគរយ ជារចនាសម្ព័ន្ធមានលក្ខណៈបណ្ដោះអាសន្ន។ នៅតំបន់ជនបទប្រមាណ ៤,៧ ភាគរយនៃអាគារលំនៅដ្ឋានជាសំណង់មានលក្ខណៈពាក់កណ្ដាលអចិន្ត្រៃយ៍ និងប្រមាណ ១,០ ភាគរយ ជារចនាសម្ព័ន្ធមានលក្ខណៈបណ្ដោះអាសន្ន។

### គ្រួសារ

ទំហំគ្រួសារជាមធ្យមបានថយចុះពី ៤,៨ នៅឆ្នាំ២០០៨ ទៅ ៤,៤ នៅឆ្នាំ២០១៩ ក្នុងរយៈពេលមួយទសវត្សរ៍នៅថ្នាក់ខេត្ត។ នៅតំបន់ទីប្រជុំជនបានធ្លាក់ចុះ ០,៧ ក្នុងរយៈពេលទសវត្សរ៍នេះ ចំណែកឯនៅជនបទបានថយ ០,៤។ និន្នាការនៃការថយចុះទំហំគ្រួសារ គឺស្របជាមួយនឹងការកើនឡើងនៃចំនួនគ្រួសារនៅក្នុងប្រទេស នេះបង្ហាញថាការប្រែប្រួលមួយពីរចនាសម្ព័ន្ធគ្រួសារធំឆ្ពោះទៅគ្រួសារតូច។

តាមរយៈលទ្ធផលនៃការធ្វើជំរឿនបង្ហាញថាគ្រួសារធម្មតាដែលមានសមាជិកចំនួន ៤,៤ នាក់ មានសមាមាត្រ ស្ត្រីជាមេគ្រួសារ ១៧,៣ ភាគរយ ក្នុងឆ្នាំ២០១៩ ទីប្រជុំជន ១៧,០ ភាគរយ និងជនបទ ១៧.៥ ភាគរយ។ ភាគច្រើននៃគ្រួសារ (៦០,៤ ភាគរយ) មានបន្ទប់តែមួយប៉ុណ្ណោះ។ នៅទីប្រជុំជនមាន ៦០,០ ភាគរយនៃគ្រួសារមានមួយបន្ទប់ ២៧,៦ ភាគរយ មានពីរបន្ទប់ ៨,៣ ភាគរយនៃគ្រួសារមានបីបន្ទប់ និងប្រមាណ ៤,១ ភាគរយនៃគ្រួសារដែលរស់នៅលំនៅដ្ឋានមានបួនបន្ទប់ឡើងទៅ។

### ទឹកសម្រាប់ទទួលទាន

ប្រមាណ ៣៨,៩ ភាគរយ នៃគ្រួសារខេត្តឧត្តរមានជ័យមានប្រភពទឹកស្អាតសម្រាប់ប្រើប្រាស់នៅឆ្នាំ២០១៩ ។ នៅតំបន់ទីប្រជុំជនមានភាគរយខ្ពស់នៃគ្រួសារដែលមានប្រភពទឹកស្អាតសម្រាប់ទទួលទាន (៤៤,៦ ភាគរយ)។ ម្យ៉ាង

វិញទៀត ប្រមាណ ២៧,៤ ភាគរយ នៃគ្រួសារនៅទីប្រជុំជនមានប្រភពផ្គត់ផ្គង់ទឹកស្អាតសម្រាប់ទទួលទាននៅក្នុងបរិវេណគេហដ្ឋានរបស់ពួកគេ។ ប៉ុន្តែនៅជនបទមានតែ ២៣,៣ ភាគរយ ប៉ុណ្ណោះដែលមានប្រភពទឹកស្អាតសម្រាប់ទទួលទាននៅក្នុងគេហដ្ឋាន។

## ប្រភពបំភ្លឺ

ប្រមាណ ៥២,៩ ភាគរយ នៃគ្រួសារនៅខេត្តឧត្តរមានជ័យប្រើប្រាស់អគ្គិសនី (រួមមាន អគ្គិសនីបណ្ដាញ ម៉ាស៊ីនភ្លើង និងទាំងពីរប្រភព) នៅឆ្នាំ២០១៩ បានកើនឡើងខ្លាំងប្រៀបធៀបនឹងឆ្នាំ២០០៨ មាន ១៧,៦ ភាគរយ ។ ដោយឡែកប្រមាណ ៥៨,០ ភាគរយនៃគ្រួសារនៅតំបន់ទីប្រជុំជនប្រើប្រាស់អគ្គិសនីសម្រាប់បំភ្លឺ ចំណែកគ្រួសារនៅជនបទមាន ៥០,៤ ភាគរយ។

## បង្គន់អនាម័យ

មាន ៧០,៥ ភាគរយនៃគ្រួសារខេត្តឧត្តរមានជ័យមានបង្គន់អនាម័យប្រើប្រាស់ ។ គ្រួសារខេត្តឧត្តរមានជ័យឆ្នាំ២០១៩ ជាង ៧ គ្រួសារក្នុងចំណោម ១០ គ្រួសារនៅតំបន់ទីប្រជុំជមានបង្គន់អនាម័យប្រើប្រាស់ និងជិត ៧ គ្រួសារនៅជនបទ។ ក្នុងនោះប្រមាណ ១២,៦ ភាគរយនៃគ្រួសារមានបង្គន់អនាម័យនៅតំបន់ទីប្រជុំជន ប្រើប្រាស់បង្គន់ចាក់ទឹក ឬ(ចុចបង្ហូរទឹក) តភ្ជាប់ទៅប្រព័ន្ធលូ ចំណែកឯនៅជនបទមានត្រឹមតែ ៦,៥ ភាគរយ ប្រមាណ ៤៧,៣ ភាគរយនៃគ្រួសារនៅទីប្រជុំជនបានប្រើប្រាស់បង្គន់ចាក់ទឹក ឬ(ចុចបង្ហូរទឹក) តភ្ជាប់អាងស្តុក ឬរណ្តៅ និងនៅជនបទមាន ៤៧,២ ភាគរយ។

## ឥន្ធនៈសម្រាប់ចម្អិន

ប្រមាណ ៤៥,៧ ភាគរយនៃគ្រួសារខេត្តឧត្តរមានជ័យបានប្រើប្រាស់ឧសសម្រាប់ចម្អិនអាហារ នៅតំបន់ទីប្រជុំជនមានតែ ៣៩,២ ប៉ុណ្ណោះ ប៉ុន្តែបើនៅតំបន់ជនបទ ៤៩,០ ភាគរយ ច្រើនជាងជាងបីរដងបើប្រៀបធៀបនឹងតំបន់ទីប្រជុំជន។ ប្រមាណ ៨,៤ នៃប្រជាជនខេត្តឧត្តរមានជ័យប្រើប្រាស់ឧស្ម័នហ្គាសសម្រាប់ចម្អិនអាហារ ចំណែកឯនៅតំបន់ទីប្រជុំជនវិញមាន ១៣,៤ ភាគរយ និងតំបន់ជនបទមានតែ ៥,៩ ភាគរយ ប៉ុណ្ណោះ។

## ការប្រើប្រាស់អ៊ីនធឺណិត

៥១,៦ ភាគរយនៃគ្រួសារនៅខេត្តឧត្តរមានជ័យមានប្រើប្រាស់អ៊ីនធឺណិត ក្នុងនោះនៅផ្ទះ ២៧,៦ ភាគរយប្រើប្រាស់ អ៊ីនធឺណិតនៅទីសាធារណៈ ១,៤ ភាគរយ និងប្រើអ៊ីនធឺណិតនៅផ្ទះ និងសាធារណៈ ២២,៦ ភាគរយ។ ភាគរយនៃគ្រួសារនៅតំបន់ទីប្រជុំជនប្រើប្រាស់អ៊ីនធឺណិតខ្ពស់ជាង(៥២,២ ភាគរយ) បើប្រៀបធៀបទៅនឹងភាគរយនៃគ្រួសារនៅតំបន់ជនបទ (៥១,៣ ភាគរយ) ។

## សម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួន

ភាគរយនៃគ្រួសារទូទាំងខេត្តឧត្តរមានជ័យដែលមានទូរទស្សន៍ផ្ទាល់ខ្លួនសម្រាប់ប្រើប្រាស់មាន ៤៨,១ ភាគរយ នៅទីប្រជុំជន មាន ៥៥,៥ ភាគរយ និងនៅជនបទមាន ៤៤,៤ ភាគរយ ។ ទន្ទឹមនឹងនេះ ប្រមាណ ៩០,៩ ភាគរយនៃគ្រួសារមានទូរសព្ទ័ដៃនៅទូទាំងខេត្តឧត្តរមានជ័យខណៈដែលគ្រួសារនៅទីប្រជុំជនមាន ៩១,៨ ភាគរយ និងគ្រួសារនៅជនបទមាន ៩០,៥ ភាគរយ។ នៅទីប្រជុំជនគ្រួសារដែលមានម៉ូតូប្រើប្រាស់ផ្ទាល់ខ្លួនប្រមាណ ៧៦,៦ ភាគរយ និងប្រមាណ ៧៥,៧ ភាគរយនៅជនបទ។ ចំណែកឯគ្រួសារដែលមានរថយន្ត(រថយន្តដឹកទំនិញធុនតូចឬធំ ឬរថយន្តសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន) មានតែ ៧,៣ ភាគរយប៉ុណ្ណោះនៅខេត្តឧត្តរមានជ័យ។ កង់ជាកម្មសិទ្ធិប្រើប្រាស់ផ្ទាល់ខ្លួនមាន ៤៧,៦ ភាគរយនៃគ្រួសារនៅទីប្រជុំជន និងនៅជនបទមាន ៤៥,៦ ភាគរយ។

# សន្ទានុក្រម

*អាគារ*

ជារចនាសម្ព័ន្ធទោលមួយដែលសង់លើដី។ ជួនកាលផ្គុំឡើងដោយវត្ថុធាតុជាច្រើនហើយប្រើប្រាស់សម្រាប់ជាលំនៅដ្ឋានស្នាក់នៅ ឬសហគ្រាស ដូចជាហាងលក់ទំនិញ កន្លែងពាណិជ្ជកម្ម ការិយាល័យ រោងជាង រោងចក្រ សាលារៀន កន្លែងកំសាន្ត កន្លែងធ្វើការ ឃ្លាំង ។ល។ អាគារអាចប្រើប្រាស់ក្នុងគោលបំណងច្រើនប្រភេទ ដូចជាលំនៅដ្ឋានស្នាក់នៅផង និងហាងលក់ទំនិញ ឬអាចជារោងជាងផង ឬជាលំនៅដ្ឋានស្នាក់នៅផង និងកន្លែងធ្វើការផង។

*ទីប្រជុំជន*

ការធ្វើចំណាត់ថ្នាក់តំបន់ទីប្រជុំជនឡើងវិញនៅខេត្តឧត្តរមានជ័យឆ្នាំ២០២០ ត្រូវបានអនុវត្តដោយវិទ្យាស្ថានជាតិស្ថិតិក្នុងអំឡុងខែមិថុនា ដល់ខែកក្កដាឆ្នាំ២០២០ ដោយប្រើប្រាស់សំណុំទិន្នន័យចុងក្រោយនៃជំរឿនប្រជាជនទូទៅនៅព្រះរាជាណាចក្រខេត្តឧត្តរមានជ័យឆ្នាំ២០១៩។ ការសិក្សានេះបានត្រូវបានផ្តល់អនុសាសន៍អំពីចំណាត់ថ្នាក់នៃទីប្រជុំជននេះ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យបីយ៉ាងគឺលើទំហំប្រជាជន ដង់ស៊ីតេប្រជាជន និងអ្នកធ្វើការក្នុងវិស័យមិនមែនកសិកម្មនៅកម្រិតឃុំ។ បន្ទាប់ពីបានគិតគ្រប់ជ្រុងជ្រោយយ៉ាងយកចិត្តទុកដាក់លើគ្រប់ទិដ្ឋភាពពាក់ព័ន្ធក្នុងការសិក្សា និងពិគ្រោះយោបល់ជាមួយអាជ្ញាធថ្នាក់ក្រោមជាតិ ផ្អែកលក្ខណៈវិនិច្ឆ័យដូចខាងក្រោមទៅលើឃុំនីមួយៗ ដើម្បីចាត់ថ្នាក់ជាទីប្រជុំជន ឬជនបទ ៖

### ១. ទិដ្ឋភាពសេដ្ឋកិច្ច និងប្រជាសាស្ត្រ

- ទំហំប្រជាជនសរុបក្នុងឃុំចាប់ពី ២០០០ នាក់ឡើង
- ដង់ស៊ីតេប្រជាជនក្នុងឃុំចាប់ពី ២០០ នាក់ក្នុង ១ គីឡូម៉ែត្រការ៉េ
- អ្នកធ្វើការក្នុងវិស័យមិនមែនវិស័យកសិកម្មលើសពី ៥០ ភាគរយ

### ២. ទិដ្ឋភាពលក្ខខណ្ឌរដ្ឋបាល

ទីប្រជុំជនដែលបានកំណត់ផ្អែកលើមូលដ្ឋាននៃរដ្ឋបាលតាមច្បាប់ ឬត្រូវបានទទួលស្គាល់ដោយអនុក្រឹត និងច្បាប់។ ប្រភេទទី ១ ជាទីប្រជុំជនត្រូវបានគេស្គាល់ថាជាទីប្រជុំជនដែលជាក្រុង។ ទីប្រជុំជនទាំងនេះត្រូវបានទទួលស្គាល់ដោយច្បាប់របស់រាជរដ្ឋាភិបាលដូចជារាជធានី និងក្រុងជាដើម ដោយមិនគិតពីទិដ្ឋភាពសេដ្ឋកិច្ច និងប្រជាសាស្ត្រឡើយ។

### ៣. ទិដ្ឋភាពជាក់ស្តែង និងការពិគ្រោះយោបល់

បន្ទាប់ពីបានគិតគូគ្រប់ជ្រុងជ្រោយយ៉ាងយកចិត្តទុកដាក់ លើគ្រប់ទិដ្ឋភាពពាក់ព័ន្ធក្នុងការសិក្សាខាងលើមន្ត្រីវិទ្យាស្ថានជាតិស្ថិតិបានចុះពិនិត្យស្ថានភាពជាក់ស្តែងលើបណ្តាឃុំដែលចាត់ចូលក្នុងលក្ខណៈវិនិច្ឆ័យ និងបានចូលរួមពិគ្រោះយោបល់ជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិ ជាពិសេសប្រធានមន្ទីរផែនការ និងមន្ត្រីបច្ចេកទេសពាក់ព័ន្ធមួយចំនួនជាពិសេសក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងមហាផ្ទៃ អង្គការ UNICEF អង្គការ UNFPA និង UNHABTAT ។

### *អត្រាកំណើនប្រចាំឆ្នាំបែប Exponential*

$$r_{EXP} = \ln\left(\frac{X_n}{X_0}\right) / n$$

$X_o$ = ចំនួនប្រជាជនឆ្នាំគោល
$X_n$ = ចំនួនប្រជាជនឆ្នាំចុងក្រោ
n = ចំនួនឆ្នាំរវាង $X_o$ and $X_n$

### *ដង់ស៊ីតេប្រជាជន*

ត្រូវបានគណនាដោយផលចែកនៃចំនួនប្រជាជន ទៅនឹងផ្ទៃដីសរុបនៅក្នុងតំបន់ជាក់លាក់មួយ។ ដង់ស៊ីតេប្រជាជន គឺជាសន្ទស្សន៍ដ៏សំខាន់មួយនៃសូចនាករប្រជាសាស្ត្រដែលត្រូវបានវាស់វែង សិក្សាពីការប្រមូលផ្តុំរបស់ប្រជាជន។ សន្ទស្សន៍នេះគិតពីចំនួនមនុស្សរស់ក្នុងបរិវេណដីក្នុងមួយគីឡូម៉ែត្រការ៉េ។

### *សន្ទស្សន៍ Myer*

សន្ទស្សន៍ Myer គឺជារង្វាស់ពិនិត្យលើអាយុ លេខខ្ទង់ចុងក្រោយ។ ការកត់ត្រា ឬរាយការណ៍អាយុជំនួសអ្នកដំទៃត្រូវបានសំដៅទៅលើអាយុដែលជាចំណង់ចំណូលចិត្តនៃអាយុខ្ទង់ (ដូចជាអាយុ ដែលបញ្ចប់នៅលេខ ០ ឬ ៥)។ ទ្រឹស្តីសន្ទស្សន៍ Myer លាតសន្ធឹងពីអប្បបរមា "០" នៅពេលដែលមិនមានចំណូលចិត្ត និងចៀសវាងតួលេខជាក់លាក់ណាមួយដល់ចំនួនអតិបរមា "៩០" នៅពេលដែលមនុស្សគ្រប់រូបត្រូវបានគេរាយការណ៍នៅក្នុងខ្ទង់តែមួយ។

### *តម្លៃសន្ទស្សន៍សន្ទស្សន៍ Myer*

ទិន្នន័យមានភាពត្រឹមត្រូវខ្ពស់បើតូចជាង ១០,០
ទិន្នន័យត្រឹមត្រូវត្រឹមត្រូវ ១០,០ – ១៩,៩
ទិន្នន័យមានគុណភាពទាប ២០,០០ – ៣៩,៩
ទិន្នន័យមិនអាចប្រើការបានបើធំជាង ៤០,០

### *សន្ទស្សន៍ Whipple*

ទិន្នន័យអាយុជាទូទៅមិនមានភាពត្រឹមត្រូវ ១០០ ភាគរយនោះទេ ដោយសារហេតុផលជាច្រើនចាំបាច់ត្រូវវាយតម្លៃវាមុនពេលប្រើប្រាស់។ យោងតាមលទ្ធផលអង្កេតក្រោយជំរឿនមួយចំនួនភាពមិនស៊ីគ្នានៅខេត្តឧត្តរមានជ័យមានកម្រិតទាប។ សន្ទស្សន៍ Whipple ត្រូវបានគណនាសម្រាប់ពិនិត្យគុណភាពទិន្នន័យអាយុ។ សន្ទស្សន៍របស់ Whipple គឺជារង្វាស់ចំណង់ចំណូលចិត្តសម្រាប់អាយុដែលបញ្ចប់នៅក្នុងលេខ ០ និង ៥។ ជួររបស់វាគឺចាប់ពី ១០០ បង្ហាញថាគ្មានចំណូលចិត្ត លេខ ០ និង ៥ ដល់ ៥០០ បង្ហាញថាមានតែ ០ និង ៥ ប៉ុណ្ណោះដែលត្រូវបានគេរាយការណ៍។

### *តម្លៃសន្ទស្សន៍ Whipple*

ទិន្នន័យមានភាពត្រឹមត្រូវខ្ពស់បើតូចជាង ១០៥
ទិន្នន័យត្រឹមត្រូវត្រឹមត្រូវ ១០៥ – ១០៩,៩
ទិន្នន័យប្រហាក់ប្រហែល ១១០ – ១២៤,៩
ទិន្នន័យមានគុណភាពទាប ១២៥ – ១៧៤,៩
ទិន្នន័យមិនអាចប្រើការបានបើធំជាង ១៧៥

### *សន្ទស្សន៍អាយុពិតប្រាកដតាម UN*

ជាការសរុប (i) ផលបូកនៃលំអៀងមធ្យមនៃអត្រាមនុស្សប្រុសពីចំនួន ១០០ (ii) លំអៀងមធ្យមនៃអត្រាអាយុស្រីពីចំនួន ១០០ (iii) បីដងនៃមធ្យមនៃការដកបន្តគ្នាក្នុងអត្រាអាយុទទួលបាន។ នៅក្នុងវិធីសាស្ត្រនេះអត្រាអាយុមាននិយមន័យតាមរូមន្ត ផលចែកប្រជាជននៅក្នុងក្រុមអាយុជាមួយពាក់កណ្តាលនៃផលបូកប្រជាជនក្នុងក្រុមអាយុមុន និងក្រុមអាយុបន្ទាប់។

### *អាយុ*

ជាចំនួនឆ្នាំពេញលេញនៃអាយុគិតដល់ថ្ងៃខួបកំណើតចុងក្រោយ។

### *ពីរ៉ាមីតប្រជាជន*

ពីរ៉ាមីតប្រជាជនបង្ហាញជាលក្ខណៈក្រាហ្វិកតាមក្រុមអាយុ និងភេទប្រជាជន។ ជួរផ្តេកបង្ហាញពីចំនួន ឬសមាមាត្រនៃបុរស និងស្ត្រីសម្រាប់ក្រុមអាយុនីមួយៗ ផលបូកនៃក្រុមអាយុ និងភេទទាំងអស់ ពីរ៉ាមីតប្រជាជនស្មើនឹង ១០០ ភាគរយ។

### *មេដ្យានអាយុ*

មុនពេលគណនាមេដ្យានអាយុ យើងត្រូវបែងចែកចំនួនប្រជាជនជាចំនួនពីរក្រុមដែលមានទំហំស្មើៗគ្នា (៥០ ភាគរយ ទល់នឹង ៥០ភាគរយ) គឺក្រុមដែលអាយុតិចជាង និងក្រុមមួយទៀតមានអាយុច្រើនជាងមេដ្យាន។

$$\text{មេដ្យាន} = L + \frac{(N/2-C)}{F_m} \times I$$

N = ចំនួនប្រជាជនសរុប
L = ដែនកំណត់ទាបនៃថ្នាក់មេដ្យាន
Fm = ចំនួននៃថ្នាក់មេដ្យាន (frequency of median class)
C = ប្រេកង់តគ្នានៃថ្នាក់មុនមេដ្យាន
I = ចន្លោះថ្នាក់

### *ផលធៀបភេទ ឬអត្រាភេទ*

ជាផលចែកនៃចំនួនបុរស និងចំនួនស្ត្រីគុណនឹង ១០០ បកស្រាយពីចំនួនបុរសក្នុងចំណោមស្ត្រី ១០០ នាក់។

### *ផលធៀបអាយុក្នុងបន្ទុក*

ជាភាគរយនៃប្រជាជនក្នុងក្រុមអាយុក្មេង (អាយុ ០-១៤ ឆ្នាំ) និងក្រុមអាយុចាស់ (៦០+) ឆ្នាំធៀបទៅនឹងចំនួនប្រជាជនដែលមានអាយុកម្លាំងពលកម្មពី ១៥-៥៩ ឆ្នាំ។ (ផលធៀបអាយុក្នុងបន្ទុកនេះអាចគណនាដាច់ដោយឡែកពីគ្នារវាងផលធៀបអាយុក្នុងបន្ទុកវ័យក្មេង និងអាយុក្នុងបន្ទុកវ័យចាស់)។

### *អាយុមធ្យមនៃការរៀបការ Singulate Mean Age at Marriage (SMAM)*

អាយុមធ្យមនៃការរៀបការលើកដំបូងត្រូវបានប្រើប្រាស់សម្រាប់ប្រជាជនដែលបានចាត់ថ្នាក់តាមអាយុ និងស្ថានភាពអាពាហ៍ពិពាហ៍ផ្តល់នូវទិន្នន័យតែមួយគត់ស្តីពីស្ថានភាពអាពាហ៍ពិពាហ៍។ វាប្រៀបធៀបសមាមាត្រអាយុជាក់លាក់របស់អ្នកដែលមិនដែលរៀបការជាមួយអ្នកដែលរៀបការហើយ គិតពីអាយុមធ្យមដែលការផ្លាស់ប្តូរត្រូវបានធ្វើឡើង។ សម្រាប់ព័ត៌មានលម្អិតនៃវិធីសាស្ត្រដែលបង្កើតឡើងដោយ John Hajnal ។

$$SMAM = \frac{d + \sum 5_5 S_x - 50 * S_{50}}{1 - S_{50}}$$

d = អាយុរៀបការទាបបំផុត = 15

$\sum 5_5 S_x$ = សរុបសមាមាត្រប្រជាជនមិនដែលរៀបការក្រុមអាយុ 5 ឆ្នាំ

$S_{50}$ = សមាមាត្រប្រជាជនមិនដែលរៀបការនៅអាយុ ៥០ ឆ្នាំ

### *អក្ខរភាព*

មនុស្សម្នាក់ដែលចេះអាន និងសរសេរប៉ុន្តែនៅពេលជំរឿនគាត់មិនអាចអាន និងសរសេរបានទៀតទេ ដោយសារតែមានបញ្ហារាងកាយ ឬជំងឺ ត្រូវបានចាត់ទុកថាជាមនុស្សចេះអក្សរផងដែរ។ មនុស្សត្រូវបានចាត់ទុកថាមិនចេះអក្សរផងដែរ បើមនុស្សនោះមានសមត្ថភាពអានសរសេរតែឈ្មោះ ឬលេខផ្ទាល់ខ្លួន ក៏ដូចជាមនុស្សដែលចេះអានតែមិនចេះសរសេរ ឬក៏ផ្ទុយទៅវិញ។

ជនពិការដែលអាចអាន និងសរសេរតាមរយៈមធ្យោបាយណាមួយ ដូចជាប្រព័ន្ធប្រៃលសម្រាប់អ្នកពិការភ្នែក ត្រូវបានចាត់ទុកថាជាអ្នកចេះអក្សរ។ តាមនិយមន័យកុមារទាំងអស់ដែលមានអាយុតិចជាង ៦ ឆ្នាំទាំងអស់ត្រូវបានចាត់ទុកថាអនក្ខរភាព។ ឧទាហរណ៍ មនុស្សវ័យចំណាស់ដែលចេះអាន និងសរសេរ ប៉ុន្តែមិនអាចអនុវត្តសកម្មភាពទាំងនេះបានទៀតដោយសារបញ្ហាភ្នែកខ្សោយ។

*អត្រាអក្ខរភាពទូទៅ*

ជាភាគរយនៃប្រជាជនចេះអក្សរធៀបទៅនឹងចំនួនសរុបប្រជាជនទាំងអស់ ដោយមិនរាប់បញ្ចូលចំនួនក្មេងដែលមានអាយុ ០-៦ ឆ្នាំ។

*អត្រាអក្ខរភាពមនុស្សពេញវ័យ*

ជាភាគរយប្រជាជនអក្ខរភាពមានអាយុ ១៥ ឆ្នាំឡើង ធៀបនឹងចំនួនសរុបប្រជាជនអាយុ ១៥ ឆ្នាំឡើង។

*កម្រិតសិក្សាអប់រំ*

កម្រិតថ្នាក់ដែលបានបញ្ចប់ពេញលេញត្រូវបានធ្វើចំណាត់ដូចជា ១= មិនបានបញ្ចប់ថ្នាក់ណាមួយ (០ និង ៨៨) ២= មិនបានបញ្ចប់បឋមសិក្សា (ថ្នាក់ទី ១ ដល់ ៥) ៣= បានបញ្ចប់បឋមសិក្សា (ថ្នាក់ទី ៦ ដល់ ៨) ៤= មធ្យមសិក្សាបឋមភូមិ (ថ្នាក់ទី ៩ ដល់ ១៣) ៥= បានបញ្ចប់មធ្យមសិក្សា/មានសញ្ញាបត្រ (បានបញ្ចប់មធ្យមសិក្សា/មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សញ្ញប័ត្រមធ្យមសិក្សាបឋមភូមិមានបច្ចេកទេស/វិជ្ជាជីវៈ សញ្ញប័ត្រមធ្យមសិក្សាទុតិយភូមិមានបច្ចេកទេស/វិជ្ជាជីវៈ ១៤ ដល់ ១៦) ៦= ក្រោយមធ្យមសិក្សា (សញ្ញាបត្រថ្នាក់មហាវិទ្យាល័យ សញ្ញាបត្រថ្នាក់អនុបណ្ឌិត និងសញ្ញាបត្រថ្នាក់បណ្ឌិត ១៧ ដល់ ១៩)។

*ប្រជាជនសកម្មសេដ្ឋកិច្ច*

ជាចំនួនប្រជាជនមានការងារធ្វើ និងប្រជាជនគ្មានការងារធ្វើ ដោយឈរលើមូលដ្ឋានសកម្មភាពសំខាន់ៗរបស់គាត់នៅក្នុងរយៈពេលមួយឆ្នាំមុនពេលជំរឿន។

*ប្រជាជនអសកម្មសេដ្ឋកិច្ច*

ប្រជាជនផ្សេងក្រៅពីប្រជាជនសកម្មសេដ្ឋកិច្ច នៅក្នុងរយៈពេលមួយឆ្នាំមុនជំរឿន។

*អត្រាចូលរួមកម្លាំងពលកម្ម*

អត្រាចូលរួមកម្លាំងពលកម្ម (LFPR) ត្រូវបានកំណត់ជាចំនួនមនុស្សដែលស្ថិតក្នុងកម្លាំងពលកម្ម មានការងារធ្វើ និងគ្មានការងារធ្វើ តាមអាយុ ភេទ និងតំបន់ ចែកនឹងចំនួនមនុស្សសរុបក្នុងចរិតលក្ខណៈដូចគ្នា ហើយគុណនឹង ១០០។

*អត្រាសកម្មជនសេដ្ឋកិច្ចនៃក្រុមអាយុធ្វើការងារ*

ភាគរយប្រជាជនសកម្មសេដ្ឋកិច្ចធៀបទៅនឹងចំនួនសរុបប្រជាជនអាយុ ១៥-៥៩ ឆ្នាំ។

### *អត្រាសកម្មជនសេដ្ឋកិច្ចតាមអាយុ*

ជាភាគរយប្រជាជនដែលជាសកម្មជនសេដ្ឋកិច្ចក្នុងក្រុមអាយុណាមួយ ធៀបទៅនឹងចំនួនប្រជាជនសរុបនៅក្នុងក្រុមអាយុតាមអាយុជាក់លាក់។

### *មានការងារធ្វើ*

រួមមានប្រជាជនដែលដូចនៅក្នុងប្រភេទខាងក្រោមបានធ្វើក្នុងរយៈពេល ៦ ខែ (១៨៣ថ្ងៃ) ឬលើស ក្នុងរយៈពេលមួយឆ្នាំ មុនជំរឿន ៖

(i) ប្រជាជនដែលមានការងារមានប្រាក់ឈ្នួល(ឧទាហរណ៍ ធ្វើការងារនៅផ្នែកសាធារណៈ ឬអង្គភាពឯកជន ជាដើម) (ii) ប្រជាជនដែលនៅក្នុងពេលធ្វើជំរឿន កំពុងមានការងារធ្វើ និងបានធ្វើពីមុនមក ដោយទទួលប្រាក់ឈ្នួល ប្រាក់ខែ ប្រាក់ចំណេញ ឬទទួលបានពីគ្រួសារ ជាប្រាក់ ឬជារបស់។ (iii) ប្រជាជនដែលមិនមានការងារធ្វើ ដើម្បីទទួលប្រាក់ឈ្នួល ឬប្រាក់ចំណេញ នៅក្នុងអំឡុងពេលជំរឿន ទោះបីពួកគេមានការងារធ្វើពីមុន តែអាចត្រឡប់ទៅធ្វើការវិញ (ឧទាហរណ៍ ចប់រដូវ ដូចជាកសិករ ឬអ្នកនេសាទ) ប្រជាជនឈប់សម្រាកដោយមានជំងឺ ឬឈប់សម្រាកដោយគ្មានប្រាក់ ប្រជាជនមិនធ្វើការដោយសារមានបញ្ហាកូដកម្ម ឬអង្គភាពដែលពួកគេធ្វើការត្រូវបានបិទ (iv) ប្រជាជនធ្វើការដោយខ្លួនឯង (ឧទាហរណ៍ បើកហាងលក់ទំនិញដោយខ្លួនឯង លក់គ្រឿងហូបចុក ជាវេជ្ជបណ្ឌិត មេធាវី ជាដើម)។

### *អត្រាមានការងារធ្វើ*

អត្រាមានការងារធ្វើ ជាផលធៀបនៃចំនួនអ្នកមានការងារធ្វើក្នុងចំណោមកម្លាំងពលកម្ម (សកម្មជនសេដ្ឋកិច្ច) សម្រាប់ ១០០នាក់។

### *គ្មានការងារធ្វើ*

ជាមនុស្សដែលគ្មានការងារ ប៉ុន្តែបានស្វែងរកការងារ ឬត្រៀមធ្វើការងារបានរយៈពេល ៦ ខែ ឬលើស (១៨៣ ថ្ងៃ) នៅក្នុងអំឡុងពេលមួយឆ្នាំ មុនពេលជំរឿន។

### *អត្រាគ្មានការងារធ្វើ*

អត្រាគ្មានការងារធ្វើ ជាផលធៀបនៃចំនួនអ្នកគ្មានការងារធ្វើ (បានធ្វើការពីមុនបូកមិនដែលធ្វើការសោះ) ក្នុងចំណោមកម្លាំងពលកម្ម (សកម្មជនសេដ្ឋកិច្ច) សម្រាប់ ១០០នាក់។

### *អាជីពការងារ ឬ វិស័យឧស្សាហកម្ម សេដ្ឋកិច្ច*

